ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំនៅខេត្តកំពង់ចាម

# SITUATION OF FIVE YEARS SCHOOL STRATEGIC DEVELOPMENT PLAN PREPARATION IN KAMPONG CHAM PROVINCE

ដោយ/By

យិន សម្បត្តិ/YIN SAMBATH

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០១៨-២០២០

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំនៅខេត្តកំពង់ចាម

# SITUATION OF FIVE YEARS SCHOOL STRATEGIC DEVELOPMENT PLAN PREPARATION IN KAMPONG CHAM PROVINCE

ដោយ/By

យិន សម្បត្តិ/YIN SAMBATH

ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា២០១៨-២០២០

គ្រូដឹកនាំបង្គោល៖ លោក ម៉ន មុនិន្ទ

គ្រូដឹកនាំរង៖ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំនៅខេត្តកំពង់ចាម**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបាន ស្រាវជ្រាវ និងចងក្រងដោយខ្ញុំបាទពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

**ហត្ថលេខា**

**យិន សម្បត្តិ**

# លិខិតបញ្ជាក់

**លោក** **ម៉ន មុនិន្ទ** ជាគ្រូដឹកនាំបង្គោល

**ឯកឧត្តមបណ្ឌិត** **សៀង សុវណ្ណា** ជាគ្រូដឹកនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **យិន សម្បត្តិ** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវ «**ស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំនៅខេត្តកំពង់ចាម**» ពិតប្រាកដមែន។

ថ្ងៃ ខែ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២០

........................................ ......................................

| | |
|---|---|
| **ម៉ន មុនិន្ទ** | **ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា** |
| ប្រធានដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ.វជអ | នាយកវិទ្យាស្ថានជាតិអប់រំ |

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ៥៧០៧ អយក.ខក

(ការសម្រាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ២៩៥៥ អយក.វជអ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២០។

-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៧ និងទី៨ ឆ្នាំសិក្សា២០១៩-២០២០ ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៩។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារសារណា** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯ.ឧបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | អនុប្រធាន |
| ៣- ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៤-លោក | ទី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-លោកបណ្ឌិត | នុវ រ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកបណ្ឌិត | នី វដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោក | ចាប វតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោកបណ្ឌិត | អាន វ៉ុប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកស្រី | នុ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារសារណា របស់និស្សិតពីថ្ងៃទី២៤-២៥ ខែតុលា ឆ្នាំ២០២០ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ច័ន្ទ ១៣ កើត ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស. ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ តុលា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

កន្លែងទទួល៖

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ

-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជ្រាបជាព័ត៌មាន"

-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"

-សាមីខ្លួន "ដើម្បីអនុវត្ត"

-កាលប្បវត្តិ -ឯកសារ វជអ

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២

អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

# លិខិតថ្លែងអំណរគុណ

ការសិក្សាស្រាវជ្រាវមួយនេះ អាចសម្រេចដល់គោលដៅប្រកបដោយភាពជោគជ័យគឺ ដោយសារមានការចូលរួមយ៉ាងសកម្មពីគ្រប់មជ្ឈដ្ឋានពាក់ព័ន្ធនានា ដែលបានចូលរួមផ្ដល់ឱកាសជួយសម្របសម្រួល និងជ្រោមជ្រែងតាំងពីដើមរហូតដល់ចប់។ ហេតុនេះខ្ញុំបាទដែលជាអ្នកសិក្សាស្រាវជ្រាវ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

លោកឪពុក អ្នកម្ដាយ ដែលបានផ្ដល់កំណើត និងចិញ្ចឹមបីបាច់ថែរក្សា ផ្ដល់ដំបូន្មាន ឧបត្ថម្ភគាំទ្រ និងផ្ដល់ឱកាសឱ្យខ្ញុំបានរៀនសូត្រ ទទួលបានផ្លែផ្កាដូចសព្វថ្ងៃនេះ។ លោកឪពុកក្មេក ម្ដាយក្មេក និងភរិយាជាទីស្រលាញ់ ដែលតែងតែលើកទឹកចិត្ត និងគាំទ្រដល់ការបន្តការសិក្សារបស់ខ្ញុំ ដោយមិនគិតពីការនឿយហត់។

ក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដែលបានរៀបចំថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់សម្រាប់ឱ្យខ្ញុំបាទមានឱកាសបន្តការសិក្សានៅទីនេះ។ គណៈគ្រប់គ្រងការបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកគ្រូ អ្នកគ្រូ ទាំងអស់ដែលបានចំណាយពេលវេលា បង្ហាត់បង្រៀនដល់ខ្ញុំបាទដោយមិនគិតពីការនឿយហត់។

លោក ម៉ន មុនិន្ទ ដែលជាគ្រូដឹកនាំបង្គោល ដែលលោកតែងតែឆ្លៀតពេលដ៏មានតម្លៃក្នុងការផ្ដល់គំនិតណែនាំជាទ្រឹស្ដីល្អៗ និងផ្ដល់កម្លាំងចិត្ត បច្ចេកទេស វិធីសាស្ត្រនានា មិនតែប៉ុណ្ណោះលោកបានផ្ដល់ជាឯកសារដែលទាក់ទងនឹងប្រធានបទ ព្រមទាំងជួយបង្ហាញទិសដៅដល់រូបខ្ញុំរហូតការសិក្សាស្រាវជ្រាវនេះ ទទួលបានជោគជ័យជាស្ថាពរ។ ឯកឧត្តមបណ្ឌិត សៀង សុវណ្ណា ជាគ្រូដឹកនាំរង ដែលឯកឧត្តមតែងតែឆ្លៀតពេលដ៏មានតម្លៃក្នុងការកែសម្រួល ឃ្លាប្រយោគ អក្ខរាវិរុទ្ធ និងរបៀបសរសេរនិក្ខេបបទ ព្រមទាំងជួយកែសម្រួលកម្រងសំណួរផ្សេងៗដែលទាក់ទងនឹងប្រធានបទ និងការវិភាគទិន្នន័យផងដែរ។

មិត្តរួមថ្នាក់ជំនាន់ទី៧ទាំងអស់ដែលតែងតែផ្ដល់កម្លាំងចិត្តដល់រូបខ្ញុំបាទតាមរយៈចែករំលែកចំណេះដឹង បទពិសោធន៍ និងព័ត៌មានទាំងឡាយ ធ្វើឱ្យខ្ញុំបាទមានទឹកចិត្តតស៊ូ និងពុះពាររាល់ការលំបាក និងឧបសគ្គទាំងឡាយដើម្បីសម្រេចគោលដៅនៃការស្រាវជ្រាវសរសេរនិក្ខេបបទនេះ។

លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តកំពង់ចាម លោក លោកស្រីអនុប្រធានមន្ទីរ លោកប្រធាន អនុប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុង លោកលោកស្រី គណៈគ្រប់គ្រងសាលា លោកគ្រូ អ្នកគ្រូ និងបុគ្គលិកពាក់ព័ន្ធភាគសំណាកទាំងអស់ដែលបានចូលរួមឆ្លើយនូវកម្រងសំណួរ និងសហការក្នុងការផ្ដល់ទិន្នន័យធ្វើឱ្យការសិក្សាស្រាវជ្រាវនេះទទួលបានជោគជ័យ។

ជាទីបញ្ចប់នេះខ្ញុំបាទសូមឧទ្ទិសដល់វិញ្ញាណក្ខន្ធលោកអ្នកដ៏មានគុណទាំងឡាយដែលបានចែកឋានទៅកាន់សុគតិភព និងសូមគោរពជូនពរដល់ឯកឧត្ដម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡា តំណាងអង្គការដៃគូអភិវឌ្ឍ គ្រូឧទ្ទេសទាំងអស់នៃវិទ្យាស្ថានជាតិអប់រំ សូមជួបប្រទះតែសេចក្ដីសុខ សេចក្ដីចម្រើនគ្រប់ប្រការមានសុខភាពល្អបរិបូណ៌ សម្រេចជោគជ័យគ្រប់ភារកិច្ច និងទទួលបាននូវពរទាំងឡាយ ៥ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មូលន័យសង្ខេប

យោងតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤របស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦ នៃរដ្ឋសភា ដែលធ្វើឱ្យក្រសួងអប់រំ យុវជន និងកីឡាដាក់ចេញយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាដែលផ្តោតសំខាន់ដល់ថ្នាក់មូលដ្ឋានគឺ សាលារៀន មានន័យថាសាលារៀនទទួលបានភាពជាម្ចាស់ការដោយមានការរៀបចំផែនការ និងស្វ័យវាយតម្លៃសាលាដោយខ្លួនឯង តាមរយៈការយកចិត្តទុកដាក់នេះសាលារៀនត្រូវរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំ ដោយមានការចូលរួមពីភាគីពាក់ព័ន្ធដើម្បីផលិតបាននូវ ផែនការដែលដោះស្រាយបញ្ហាប្រឈម ហើយអាចសម្រេចនូវសូចនាករ ទាក់ទងទៅនឹងការចូលរៀន គុណភាពសិក្សា និងការដឹកនាំគ្រប់គ្រងដែលឆ្លើយតបទៅនឹងគោលនយោបាយអបរំ ក្នុងន័យនេះយើងនឹងធ្វើការសិក្សាស្រាវជ្រាវ ពីស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅខេត្តកំពង់ចាម ក្នុងគោលបំណងស្វែងរកពីដំណើរការរៀបចំ និងបញ្ហាប្រឈម ។

ទិន្នន័យនៃការសិក្សាស្រាវជ្រាវនេះ ត្រូវបានប្រមូលតាមរយៈការប្រើប្រាស់កម្រងសំណួរដើម្បីធ្វើការសម្ភាស នាយក/នាយិកាចំនួន១០នាក់ នាយករង/នាយិការងចំនួន២០នាក់ លេខាធិការចំនួន១០នាក់ គណនេយ្យចំនួន ១០នាក់ ប្រធានក្រុមបច្ចេកទេសចំនួន២០ នាក់ អនុប្រធានក្រុមបច្ចេកទេសចំនួន១០ នាក់ លោកគ្រូ អ្នកគ្រូចំនួន ២០នាក់ ដែលមកពីវិទ្យាល័យចំនួន ១០ក្នុងខេត្តកំពង់ចាម ហើយដើម្បីសិក្សាប្រធានបទទៅលើប្រធានបទនេះបានជោគជ័យ យើងបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យ និងធ្វើការវិភាគទិន្ន័យដោយកម្មវិធី Microsoft Excel ។តាមរយៈការសិក្សានេះបានបង្ហាញឱ្យឃើញថា អ្នកពាក់ព័ន្ធក្នុងការរៀបចំផែនការគឺផ្តោតសំខាន់លើចក្ខុវិស័យ ការវិភាគស្ថានភាពអប់រំ និងបញ្ហាប្រឈម ការបង្កើតយុទ្ធសាស្ត្រ និងសកម្មភាព នៅមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ ដូច្នេះហើយដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ជាផែនការមួយមានគុណភាពអ្នកពាក់ព័ន្ធទាំងអស់ត្រូវយល់ដឹងខ្លឹមសារគ្រប់ចំណុចនៃទម្រង់ផែនការ។ ចំណែកឯលទ្ធផលតាមនៃបញ្ហាប្រឈមបានបង្ហាញឱ្យឃើញថាអ្នកដែលបានចូលរួមរៀបចំផែនការមានភាពលំបាកក្នុងកត្តាប្រឈមសំខាន់ៗ៥ ដែលធ្វើឱ្យមានភាពស្មុកស្មាញនៃដំណើរការរៀបចំ។ ដូច្នេះអ្នករៀបចំផែនការត្រូវទទួលបានការអភិវឌ្ឍសមត្ថភាពនៃខ្លឹមសារនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលាបន្ថែមទៀតដើម្បីឱ្យការរៀបចំមានខ្លឹមសារ និងគុណភាពឆ្លើយតបទៅនឹងចរិកលក្ខណៈផែនការ និងគោលនយោបាយផែនការអប់រំ។

# Abstract

According to the Rectangular Strategy, the fourth phase of the Royal Government of Cambodia, the 6th legislature of the National Assembly, which led the Ministry of Education, Youth and Sports to launch a reform strategy in the field of education, youth and sports that focuses on the grassroots level: schools means schools Ownership By planning and self-evaluating the school Through this focus, the school must develop a five-year school development strategy with the participation of Stakeholders To produce a plan that addresses the challenges and can achieve indicators related to enrollment, quality of education and management leadership that respond to education policy, in this sense, we will study the situation of strategic planning.Develop schools at the upper secondary level in Kampong Cham province in order to explore the organization process and challenges.This research data was collected through the use of questionnaires to interview 10 directors / directors, 20 deputy directors / deputy directors, 10 secretaries, 10 accountants, 20 technical team chairpersons, 20 technical team vice chairmen. 10 teachers, 20 teachers from 10 high schools in Kampong Cham province to study topics

Successfully on this topic, we have used quantitative research methods and analyzed data by Microsoft Excel. Through this study, it is shown that the stakeholders in planning are focused on the vision, analysis of the educational situation and the challenges, the development of strategies and activities are not yet comprehensive, and therefore to the School development of strategic planning As a quality plan, all stakeholders must understand the content of every point of the plan. The results of the challenges show that those involved in planning have difficulty in five key challenges that complicate the planning process. Therefore, planners need to develop the capacity of the content of the school development strategic plan further so that the content and quality of the response to the nature of the plan and policy of the education plan.

# មាតិកា


**សេចក្តីអះអាងរបស់បេក្ខជន** ........ ii

**លិខិតបញ្ជាក់** ........ iii

**លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ** ........ iv

**លិខិតថ្លែងអំណរគុណ** ........ v

**មូលន័យសង្ខេប** ........ vi

Abstract ........ vii

**មាតិកា** ........ viii

**បញ្ជីតារាង** ........ x

**បញ្ជីក្រាប** ........ xi

**បញ្ជីពាក្យអក្សរកាត់ និងការបកប្រែ** ........ xiii

**ជំពូកទី១ សេចក្តីផ្តើម** ........ 1

១.១. លំនាំបញ្ហានៃការស្រាវជ្រាវ ........ 1

១.២.គោលបំណងនៃការស្រាវជ្រាវ ........ 4

១.៣. សំណួរស្រាវជ្រាវ ........ 5

១.៤. សារៈសំខាន់នៃការស្រាវជ្រាវ ........ 5

១.៥. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ 6

១.៦.រចនាសម្ព័ន្ធស្រាវជ្រាវ ........ 6

**ជំពូកទី២ រំលឹកទ្រឹស្តី** ........ 8

២.១.បញ្ញាតិនៃការរៀបចំផែនការ ........ 8

២.២. ប្រភេទផែនការនៅកម្ពុជា ........ 13

២.៣.ប្រភេទផែនការក្នុងវិស័យអប់រំនៅកម្ពុជា ........ 13

២.៤.ទម្រង់ផែនការក្នុងវិស័យអប់រំ ........ 14

២.៥. ចរិតលក្ខណៈរបស់ផែនការ ........ 17

២.៦.គោលបំណង និងសារៈសំខាន់នៃការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀន ........ 17

២.៧.សមាសភាពសំខាន់ៗក្នុងការចូលរួមរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀន ............ 18
២.៨. លំនាំនៃការរៀបចំផែនការអប់រំ ........................................................................ 21
២.៩.ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀន.......................................22
២.១០. បញ្ហាប្រឈមនៃការកសាងផែនការយុទ្ធសាស្រ្តអភិវឌ្ឍសាលារៀន...............................24
**ជំពូកទី៣ វិធីសាស្រ្តសិក្សាស្រាវជ្រាវ** ....................................................................26
៣.១. ដំណើរការនៃការស្រាវជ្រាវ ...........................................................................26
៣.២. ការជ្រើសរើសភាគសំណាក ...........................................................................26
៣.៣. ឧបករណ៍ស្រាវជ្រាវ.....................................................................................27
៣.៤- វិធីប្រមូលទិន្នន័យ .....................................................................................29
៣.៥- វិធីសាស្រ្តវិភាគទិន្នន័យ ...............................................................................30
**ជំពូកទី៤ លទ្ធផលស្រាវជ្រាវ និងការពិភាក្សា** ..........................................................31
៤.១.លទ្ធផលស្រាវជ្រាវ ......................................................................................... 31
៤.២. ការពិភាក្សា .................................................................................................53
**ជំពូកទី៥ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ................................................................56
៥.១.សេចក្តីសន្និដ្ឋាន ............................................................................................. 56
៥.២. សំណូមពរ ..................................................................................................... 57
**ឯកសារយោង**..........................................................................................................59
**ឧបសម្ព័ន្ធ**..............................................................................................................63

# បញ្ជីតារាង


| តារាង | បរិយាយ | ទំព័រ |
|---|---|---|
| ៣.១ | ចំនួនសំណាកដែលត្រូវបំពេញកម្រងសំណួរ | 27 |
| ៤.១ | ព័ត៌មានទូទៅនៃការធ្វើសំណាក | 31 |
| ៤.២ | ការអនុវត្តដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន | 43 |
| ៤.៣ | បញ្ហាប្រឈមការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន | 46 |

# បញ្ជីក្រាប


| ក្រាប | បរិយាយ | ទំព័រ |
|---|---|---|
| ៤.១ | ខ្លឹមសារសំខាន់ៗនៃទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន( ប្រេកង់ ) | 32 |
| ៤.២ | ខ្លឹមសារសំខាន់ៗនៃទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន( សំណាក ) | 33 |
| ៤.៣ | ការរៀបចំផែនការតាមសាលារៀន | 34 |
| ៤.៤ | ការយល់ដឹងពីការសរសេរសេចក្តីផ្តើម | 35 |
| ៤.៥ | ការយល់ដឹងពីការសរសេរប្រវត្តិសាលារៀន | 35 |
| ៤.៦ | ការយល់ដឹងពីការសរសេរចក្ខុវិស័យ | 36 |
| ៤.៧ | ការយល់ដឹងពីការសរសេរបេសកកម្ម | 36 |
| ៤.៨ | ការយល់ដឹងពីការវិភាគស្ថានភាព និងបញ្ហាប្រឈម | 37 |
| ៤.៩ | ការយល់ដឹងពីការសរសេរគោលបំណង | 37 |
| ៤.១០ | ការយល់ដឹងពីការសរសេរសូចនាករ និងចំណុចដៅជាSMART | 38 |
| ៤.១១ | ការយល់ដឹងពីការសរសេរយុទ្ធសាស្ត្រ និងសកម្មភាព | 38 |
| ៤.១២ | ការយល់ដឹងពីការវិភាគតម្រូវការហិរញ្ញប្បទាន | 39 |
| ៤.១៣ | ការយល់ដឹងពីការសរសេរយន្តការពិនិត្យតាមដាន និងវាយតម្លៃ | 39 |
| ៤.១៤ | ការយល់ដឹងពីការដាក់ទិន្នន័យបញ្ចូលក្នុងតារាងឧបសម្ព័ន្ធ | 40 |
| ៤.១៥ | សមាសភាពបំពេញកម្រងសំណួរក្នុងការចូលរួមរៀបចំផែនការយុទ្ធសាស្ត្រ អភិវឌ្ឍសាលា | 41 |
| ៤.១៦ | លក្ខណៈរបស់ផែនការ | 41 |
| ៤.១៧ | ការពិគ្រោះយោបល់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិឌ្ឍសាលារៀន | 42 |
| ៤.១៨ | បញ្ហាប្រឈមចម្បងក្នុងការរៀបចំផែនការយុទ្ធសស្ត្រអភិវឌ្ឍសាលារៀន | 48 |

| | | |
|---|---|---|
| ៤.១៩ | ការផ្សព្វផ្សាយក្រោយពីការរៀបចំផែនការ | 49 |
| ៤.២០ | ការលើកទឹកចិត្តក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន | 49 |
| ៤.២១ | ការលើកទឹកចិត្តក្នុងការរៀបចំផែនការយុទ្ធសស្ត្រអភិវឌ្ឍសាលារៀន | 50 |
| ៤.២២ | យុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនជារឿងសំខាន់ | 50 |
| ៤.២៣ | រង្វាន់លើកទឹកចិត្តក្នុងការរៀបចំផែនការយុទ្ធសស្ត្រអភិវឌ្ឍសាលារៀន | 51 |
| ៤.២៤ | ការវាយតម្លៃលើកទឹកចិត្តក្នុងការរៀបចំផែនការយុទ្ធសស្ត្រអភិវឌ្ឍសាលារៀន | 51 |
| ៤.២៥ | ការទទួលអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន | 52 |
| ៤.២៦ | ការអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសស្ត្រអភិវឌ្ឍសាលារៀន | 52 |

# បញ្ជីពាក្យអក្សរកាត់

D-SDP : District's Strategic Development Plan ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុង/ស្រុក

EFA : Education For All ការអប់រំសម្រាប់ទាំងអស់គ្នា

ESP : Education Strategic Plan ផែនការយុទ្ធសាស្ត្រវិស័យអប់រំ

MDG : Millennium Development Goals គោលដៅអភិវឌ្ឍន៍សហសវត្សរ៍

M-ESP : Ministry's Education Strategic Plan ផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ក្រសួង

P-ESP : Province's Education Strategic Plan ផែនការយុទ្ធសាស្ត្រវិស័យអប់រំរបស់ខេត្ត

SDG : Sustainable Development Goals គោលដៅអភិវឌ្ឍប្រកបដោយចីរភាព

S-SDP : School's Strategic Development Plan ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់សាលារៀន

SDG4 : Sustainable Development Goals 4 គោលដៅអភិវឌ្ឍប្រកបដោយចីរភាពទី៤

# ជំពូកទី១

# សេចក្តីផ្តើម

## ១.១. លំនាំបញ្ហានៃការស្រាវជ្រាវ

យោងតាមនិន្នាការជាសាកល វិស័យអប់រំជាវិស័យមួយដែលចាំបាច់បំផុត ជាថ្នាលសម្រាប់ការផ្តល់ចំណេះដឹង ព្រមទាំងធ្វើឱ្យប្រទេសទាំងអស់ក្នុងពិភពលោកត្រូវតែគិតគូ និងលើកកម្ពស់វិស័យអប់រំដើម្បីឱ្យមានការរីកចម្រើន។ ការអប់រំជាសាកលលោកបានរៀបចំ គោលដៅការអប់រំសម្រាប់ទាំងអស់គ្នា Education For All ទាំងប្រាំមួយ និងគោលដៅអភិវឌ្ឍន៍សហសវត្សរ៍(MDGs)ត្រូវបានបង្កើតឡើង ប៉ុន្តែគោលដៅទាំងនោះមិនបានសម្រេចទាំងអស់ទៅតាមកាលកំណត់ទាំងអស់នៅឡើយទេ។ ដូច្នេះហើយសកម្មភាពជាអាទិភាពច្រើនទៀត ត្រូវបានលើកយកមកបន្ត ដើម្បីសម្រេចសូចនាករបន្តទៀត ដែលជាហេតុធ្វើឱ្យសមាគមន៍អប់រំសាកលលោកបានបង្កើតឡើងនូវគោលដៅមួយទៀតគឺ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដែលគិតគូចំនួន ១៧គោលដៅ ហើយគោលដៅសំខាន់ដែលពាក់ព័ន្ធនឹងការអប់រំគឺគោលដៅទី៤ ការអប់រំសម្រាប់ឆ្នាំ២០៣០ផ្តោតសំខាន់លើការផ្តល់សេវាប្រកបដោយ «គុណភាព សមធម៌ បរិយាប័ន្ន សម្រាប់កុមារតូច បឋមសិក្សា មធ្យមសិក្សា និងឧត្តមសិក្សា រួមទាំងការអប់រំបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេសការសិក្សាពេញមួយជីវិតដើម្បីបង្កើនប្រសិទ្ធិភាព គុណភាព ផលិតភាពការងារ ស្របតាមយុគ្គសម័យបច្ចេកវិទ្យា ក្នុងការបង្កើនសេដ្ឋកិច្ច និងសុខដុមជីវិតបុគ្គល និងសង្គម» (ក្រសួងអប់រំ យុវជន និងកីឡា, ២០២០)។ តាមគោលដៅទី៤ស្តីពីគុណភាពអប់រំ សម្រេចទៅបានអាស្រ័យលើតំបន់ និងប្រទេសនីមួយៗខិតខំដាក់បញ្ចូលក្នុងគោលនយោបាយការរៀបចំផែនការ និងយុទ្ធសាស្រ្តទៅតាមបរិបទប្រទេសរបស់ខ្លួន ហើយនៅក្នុងតំបន់អាស៊ានមានសិក្ខសាលាពិគ្រោះយោបល់ស្តីពី"ការកំណត់គោលដៅសូចនាករ និង យុទ្ធសាស្រ្តដើម្បីធ្វើឱ្យសម្រេចនូវគោលដៅនេះ ។ គោលបំណងសំខាន់របស់អាស៊ានក្នុងធម្មនុញ្ញអាស៊ាន មាត្រាទី១ កថាខណ្ឌទី១០ បានចែងថា «ត្រូវអភិវឌ្ឍធនធានមនុស្សតាមរយៈកិច្ចសហប្រតិបត្តិការក្នុងវិស័យអប់រំ និងការរៀនពេញមួយជីវិតព្រមទាំងសហប្រតិបត្តិការយ៉ាងជិតស្និតលើផ្នែក

វិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ផ្តល់អំណាចឱ្យប្រជាជាតិអាស៊ាន និងសម្រាប់ពង្រឹងសហគមន៍អាស៊ាន» (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៥)។ ដើម្បីសម្រេចបានគោលបំណងនេះ អាស៊ានបានដាក់ចេញនូវគោលដៅ១០ចំណុច ដើម្បីឱ្យប្រទេសនីមួយៗយកមកដាក់ចេញនូវគោលដៅរបស់ខ្លួន។

ចក្ខុវិស័យរយៈពេលវែងរបស់រាជរដ្ឋាភិបាលគឺកសាងសង្គមកម្ពុជាមួយដែលមានសន្តិភាព ស្ថេរភាពនយោបាយសន្តិសុខ សណ្តាប់ធ្នាប់សង្គម កំណើនសេដ្ឋកិច្ចរយៈពេលវែង ការអភិវឌ្ឍប្រកបដោយចីរភាព និងសមធម៌ ការកែលម្អជីវភាព និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ការការពារបរិស្ថាន ការលើកស្ទួយវប្បធម៌ និងអត្តសញ្ញាណជាតិ ការគោរពគោលការណ៍ប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស អប់រំមនុស្សឱ្យមានចំណេះដឹងខ្ពស់ និងវប្បធម៌ជ្រៅជ្រះមានជីវភាពសមរម្យ និងមានការរស់នៅប្រកបដោយសុខដុមរមនាទាំងក្នុងសង្គមជាតិ ទាំងក្នុងសង្គមគ្រួសារ ព្រមទាំងមានកិត្យានុភាពខ្ពស់លើឆាកអន្តរជាតិ ។រាជរដ្ឋាភិបាលបានកសាង មូលដ្ឋានគ្រឹះមួយប្រកបដោយភាពរឹងមាំសម្រាប់គាំទ្រដល់ ដំណើរការអភិវឌ្ឍជាតិ ជាពិសេស គឺនៅក្នុងដំណាក់កាលដែលកម្ពុជាបានក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាប គ.អ.ច.ក នឹងចូលរួមចំណែកកាន់តែសំខាន់ សម្រាប់ផ្តល់ការណែនាំដល់អ្នករៀបចំគោលនយោបាយ និងជាមធ្យោបាយមួយដ៏ទូលំទូលាយសម្រាប់វាស់វែងលទ្ធផលនៃការអនុវត្ត។រាជរដ្ឋាភិបាលកម្ពុជានឹង បន្តកិច្ចខិតខំកែទម្រង់ស៊ីជម្រៅបន្ថែមទៀត ដើម្បីបង្កើនប្រសិទ្ធភាពការងារ និងផលិទ្ធប្រកបដោយគុណភាព ព្រមទាំងជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ រួមទាំងវិស័យឯកជន សង្គមស៊ីវិល អង្គការជាតិ អន្តរជាតិ និងដៃគូអភិវឌ្ឍនានា។ រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តនិងកម្ពុជាសង្ឃឹមថា នឹងក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងឈានទៅជាប្រទេសមានចំណូលខ្ពស់ក្នុងឆ្នាំ២០៥០ (រាជរដ្ឋាភិបាល, ២០១៨)។ ការពង្រឹងគុណភាពសេវាអប់រំ គឺជាអាទិភាពចម្បងមួយរបស់រាជរដ្ឋាភិបាលកម្ពុជា និងជាគន្លឹះចាំបាច់នៃការចូលរួមក្នុងកំណើនសេដ្ឋកិច្ចតាមរយៈការអភិវឌ្ឍធនធានមនុស្ស មូលធនសង្គមនិងមូលធនបញ្ញា។ ដើម្បីឆ្លើយតបនឹងចក្ខុវិស័យជាតិ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ២០១៩-២០២៣ ក្រសួងអប់រំយុវជន និងកីឡា បានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ ផែនការយុទ្ធសាស្ត្រថវិកា ២០២០-

២០២២ និងផែនការប្រតិបត្តិប្រចាំឆ្នាំ២០២០ តាមកម្មវិធី អនុកម្មវិធី តាមអនុវិស័យនីមួយៗ និងផែនការថវិកាប្រចាំឆ្នាំ២០២០លើការអនុវត្តនៅកម្រិតថ្នាក់ជាតិ ។

យោងទៅតាមសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាមបានរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ថ្នាក់ខេត្ត ផែការយុទ្ធសាស្ត្រថវិកា២០២០-២០២២ និងណែនាំបន្តឱ្យការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក និងគ្រឹះស្ថានសិក្សាសាធារណៈ រៀបចំផែនការយុទ្ធសាស្ត្រ និងអនុវត្តសកម្មភាពតាមផែនការ។ តាមរយៈឯកសារគតិយុត្តិទាំងនេះ សាលារៀនមានតួនាទីយ៉ាងសំខាន់ និងត្រូវរៀបចំបង្កើតគណៈកម្មការគ្រប់គ្រង និងអភិវឌ្ឍសាលារៀន ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំ ដើម្បីពង្រឹងការដឹកនាំ គ្រប់គ្រង ការអនុវត្ត ការជ្រើសរើសយុទ្ធសាស្ត្រ កម្មវិធី សកម្មភាពជាអាទិភាព ដែលបានកំណត់កន្លងមក និងធ្វើយ៉ាងណាឱ្យសាលារៀនទទួលបាននូវការចូលរៀនប្រកបដោយគុណភាពសិក្សា និងប្រសិទ្ធភាពក្នុងការផ្តល់សេវាកម្មអប់រំ ដល់សិស្សានុសិស្សគ្រប់រូបឱ្យសម្រេចបាននូវលទ្ធផលសិក្សារបស់សិស្ស ព្រមទាំង ធ្វើឱ្យសម្រេចសូចនាករអប់រំ និងឆ្លើយតមទៅនឹងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា និងយុទ្ធសាស្ត្រចតុកោណចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា។

ដូច្នេះហើយគណៈគ្រប់គ្រងសាលា ដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារយៈពេល៥ឆ្នាំដើម្បីសោះស្រាយបញ្ហាប្រឈម និងធ្វើឱ្យមានភាពរីកចំរើន ។ ក្នុងន័យនេះ នាយក/នាយិកាសាលា និងពាក់ព័ន្ធទាំងអស់ត្រូវមានសមត្ថភាពក្នុងការរៀបចំផែនការ ស្វែងយល់ពីខ្លឹមសារសំខាន់ៗនៃទម្រង់ផែនការជាមុនសិនទើបអាចចាត់ចែងអ្នកមានសក្តានុពល ផ្តល់ជាគន្លឹះសំខាន់ក្នុងការបង្កើនការចូលរៀន គុណភាពអប់រំ ការដឹកនាំគ្រប់គ្រង ដែលអាចកំណត់នូវចក្ខុវិស័យ បេសកកម្ម សូចនាករ គោលបំណង យុទ្ធសាស្ត្រ និងសកម្មភាពជាអាទិភាពសម្រាប់អនុវត្ត នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន។ នាយកសាលាមិនត្រឹមតែចេះបច្ចេកទេសរៀបចំតែមួយមុខនោះទេ គឺត្រូវតែមានកិច្ចសហការជិតស្និទ្ធ ជាមួយសហគមន៍ អាជ្ញាធរដែនដី មាតាបិតាសិស្ស អាណាព្យាបាលសិស្ស ដៃគូអភិវឌ្ឍ និងស្ថាប័នពាក់ព័ន្ធដទៃទៀតក្នុងការរៀបចំផែនការយុទ្ធសាស្ត្រ និងបង្ហាញសញ្ញាជាត្រីវិស័យ

គោលដៅដើម្បីសម្រេចសូចនាករ ឈានទៅរកការអភិវឌ្ឍសង្គម និងធ្វើឱ្យសិស្សានុសិស្សទទួលបាននូវចំណេះដឹង ចំណេះធ្វើ និងឥរិយាបថ ព្រមទាំងទទួលបាននូវការគិតថ្មីៗ តាមវិធីរិះរក ច្នៃប្រឌិត បង្កើតថ្មី ឆ្លើយតបនឹងការអប់រំសតវត្សទី២១ ហើយឆ្លើយតបនឹងពាក្យស្លោកមួយឃ្លាថា **រេះគឺជាប់**។ ជាមួយគ្នានេះដែរក្រសួងអប់រំ យុវជន និងកីឡាបានចេញប្រកាសស្តីពីការកំណត់គោលការណ៍លក្ខណៈវិនិច្ឆ័យ និងនិតិវិធីនៃការវាយតម្លៃនាយក/នាយិកាសាលារៀនល្អ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៦) និងគ្រូបង្រៀនល្អសម្រាប់ផ្តល់ពានរង្វាន់ និងថវិកាអមពានរង្វាន់លើកទឹកចិត្ត ក្នុងសន្និបាតអប់រំ ដោយកំណត់លក្ខណៈវិនិច្ឆ័យនៃការវាយតម្លៃលើការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀន ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដែលជាសូចនាករសំខាន់មួយក្នុងចំណោមសូចនាករដទៃទៀតលើការវាយតម្លៃនាយក/នាយិកាសាលារៀនល្អ និងចេញអនុក្រឹតស្តីពីការវាយតម្លៃ និងទទួលស្គាល់អង្គភាពផ្តល់សេវាកម្មគំរូសម្រាប់វិស័យអប់រំ និងវិស័យសុខាភិបាលហើយយោងតាម (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩) ស្តីពីការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំ និងដោយកំណត់លើការបើកទូលាយ ឱ្យមានការចូលរួមរៀបចំជាលក្ខណៈវិនិច្ឆ័យសំខាន់មួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យទាំងអស់ដែលបញ្ជាក់ពីស្តង់ដាគំរូរបស់សាលារៀនល្អ។

## ១.២.គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងផ្តោតលើចំណុចសំខាន់ដូចខាងក្រោម៖

១. សិក្សាអំពីស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនានាក្នុងខេត្តកំពង់ចាម។

២. រកឱ្យនូវបញ្ហាប្រឈមចម្បងៗក្នុងដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនានាក្នុងខេត្តកំពង់ចាម។

## ១.៣. សំណួរស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងខាងលើ អ្នកស្រាវជ្រាវមានសំណួរចំនួន០២ សម្រាប់ធ្វើការស្រាវជ្រាវ៖

១.តើស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀននៅតាមវិទ្យាល័យនានាក្នុងខេត្តកំពង់ចាមដំណើរការយ៉ាងដូចម្ដេច?

២.តើការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនានាក្នុងខេត្តកំពង់ចាមមានបញ្ហាប្រឈមអ្វីខ្លះ?

## ១.៤. សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទខាងលើនេះ នឹងផ្ដល់អត្ថប្រយោជន៍ និងអាចឆ្លើយតបទៅនឹងគោលបំណងដែលបានកំណត់ចំពោះ ១)ចំពោះអង្គភាព អាចយល់ដឹងច្បាស់លាស់ពីដំណើរការនៃការរៀបចំផែនការ និងរកឃើញពីបញ្ហាប្រឈមចម្បងៗដែលជាឧបសគ្គរាំងស្ទះដល់ការរៀបចំផែនការយុទ្ធសាស្ត្ររបស់អង្គភាព យល់ដឹងពីចំណុចដែលត្រូវកែលម្អរបស់សាលារៀន អាចពិនិត្យឡើងវិញ និងកែសម្រួលការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលា ឱ្យកាន់តែល្អប្រសើរប្រកបដោយសង្គតិភាព និងសុខដុមនីកម្មស្របតាមបរិបទនៃកំណែទម្រង់វិស័យអប់រំ ២)សម្រាប់អ្នកស្រាវជ្រាវ មានបទពិសោធន៍កាន់តែច្បាស់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ទុកជាឯកសារសម្រាប់គ្រប់មជ្ឈដ្ឋានអ្នកសិក្សា ពិសេសសម្រាប់និស្សិត និងអង្គភាព ទុកជាបទពិសោធន៍ដល់អ្នកធ្វើ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ៣)សម្រាប់អ្នកអាន យល់ដឹងបន្ថែមទៀតពីរបៀបនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ជាប្រទីបមួយយ៉ាងសំខាន់សម្រាប់អ្នកគ្រប់គ្រងទូទៅដើម្បីរៀបចំផែនការ ជាឯសារយោងសម្រាប់ធ្វើការស្រាវជ្រាវក្នុងការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលា ៤)ចំពោះសង្គមជាតិ ទុកជាគំរូ និងបទពិសោធមួយដល់ស្ថាប័នផ្សេងៗក្នុងសង្គម តម្កល់ជាឯកសារសម្រាប់អ្នកស្រាវជ្រាវជំនាន់ក្រោយៗទៀត។

## ១.៥. ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

ក. **ដែនកំណត់នៃការស្រាវជ្រាវ៖** ការសិក្សាស្រាវជ្រាវលើប្រធានបទ **"ស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារយៈពេល៥ឆ្នាំ"** ដែលធ្វើឡើងដោយផ្តោតលើកម្រិតវិទ្យាល័យ នៅខេត្តកំពង់ចាមសម្រាប់ឆ្នាំសិក្សា ២០១៩-២០២០ រួមមានតំបន់ទីក្រុងចំនួន០២វិទ្យាល័យ និងតំបន់ជនបទចំនួន០៨វិទ្យាល័យ ក្នុងចំណោមវិទ្យាល័យទាំង៤៣ទូទាំងខេត្ត។

ខ. **វិសាលភាពនៃការស្រាវជ្រាវ៖** អ្នកស្រាវជ្រាវនឹងធ្វើការសិក្សាអំពី **"ស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារយៈពេល៥ឆ្នាំ"** ដោយផ្តោតលើតែស្ថានភាពដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន និងស្វែងរកបញ្ហាប្រឈមចម្បងៗដែលកើតមានក្នុងដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀននោះ ដើម្បីលើកជាសំណូមពរជាយុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈមទាំងនោះ ដើម្បីជំរុញឱ្យដំណើរការរៀបចំមានប្រសិទ្ធភាពខ្ពស់ នៅឆ្នាំបន្តបន្ទាប់ទៀត។

## ១.៦.រចនាសម្ព័ន្ធស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការស្រាវជ្រាវត្រូវបានចែកជា ៥ ជំពូក គឺ៖

**ជំពូកទី១៖ សេចក្តីផ្តើម** ជំពូកនេះបានបង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ និងការផ្តល់នូវនិយមន័យពាក្យគន្លឹះមួយចំនួន។

**ជំពូកទី២៖រំលឹកទ្រឹស្តី** នៅក្នុងជំពូកនេះលើកឡើងពីទ្រឹស្តីនានាដែលទាក់ទងនឹងចំណុចទាំងអស់ដែលបានចោទក្នុងចំណោទបញ្ហា ជាពិសេសបានបង្ហាញពីការពាក្យគន្លឹះ គោលបំណង សារៈសំខាន់នៃការរៀបចំផែនការយុទ្ធសាស្ត្រ និងពីចរឹកលក្ខណៈ ប្រភេទនៃផែនការដែលជាសញ្ញាមួយបញ្ជាក់ពីការចូលរួមបង្កើន គុណភាពអប់រំ និងប្រព័ន្ធអប់រំនៅកម្ពុជា។

**ជំពូកទី៣៖វិធីសាស្ត្រស្រាវជ្រាវ:** បង្ហាញពីវិធីសាស្ត្រជ្រើសរើសភាគសំណាក វិធីសាស្ត្រក្នុងការប្រមូលទិន្នន័យ និងវិភាគទិន្នន័យដែលអាចនាំទៅដល់ការបកស្រាយទិន្នន័យ។

**ជំពូកទី៤៖លទ្ធផលនិងការពិភាក្សា:**ក្នុងជំពូកនេះលើកឡើងពីលក្ខណៈជាក់ស្តែងនៃលទ្ធផលដែលយើងបានធ្វើការសិក្សាស្រាវជ្រាវតាមរយៈ ឯកសារស្រាវជ្រាវនានា លទ្ធផលនៃការសម្ភាស ចម្លើយតបក្នុងកម្រងសំណួរ និងលទ្ធផលនៃការធ្វើតេស្តសិស្ស ដើម្បីធ្វើការប្រៀបធៀបទៅនឹងទ្រឹស្តីហើយឆ្លើយតបទៅនឹងចំ ណោទបញ្ហាដែលបានចោទសួរ ក្នុងគោលបំណងវិភាគរកឱ្យឃើញចំនុចខ្វះខាត ដើម្បីធ្វើការកែលម្អនូវខ្លឹមសារនៃសៀវភៅសិក្សាគោលមុខវិជ្ជាសេដ្ឋកិច្ចនៅមធ្យមសិក្សាទុតិយភូមិ។

**ជំពូកទី៥៖សន្និដ្ឋាននិងសំណូមពរ:** ជំពូកនេះនឹងធ្វើការសន្និដ្ឋានទៅលើគ្រប់ចំនុចទាំងអស់ដែលបានរកឃើញនៅក្នុងជំពូកទី៤និងលើកជាសំណូមពរទៅលើចំណុចដែលត្រូវកែលម្អឬចំណុចខ្វះខាតនានា។

# ជំពូកទី២

# រំលឹកទ្រឹស្តី

## ២.១.បញ្ញត្តិនៃការរៀបចំផែនការ

### ២.១.១. និយមន័យពាក្យគន្លឹះ

**ចក្ខុវិស័យ៖** ជាអ្វីមួយដែលគេមិនអាចសម្រេចបានដោយខ្លួនឯងទេ។ វាគឺជាអ្វីមួយសម្រាប់នាំផ្លូវពួកគេធ្វើការងារ ហើយពួកគេជឿថាអាចសម្រេចបានប្រសិនបើមានគម្រោងហើយពួកគេជឿថាអាចសម្រេចបានប្រសិនបើគេមានគម្រោងហើយអង្គភាពចែករំលែកក្តីស្រមៃ និងធ្វើការសំដៅឆ្ពោះទៅរកវា (Per Dalin, 1998)។

**បេសកកម្ម៖** សេចក្តីថ្លែងចក្ខុវិស័យ គឺមើលឆ្ពោះទៅអនាគត ប៉ុន្តែសេចក្តីថ្លែងបេសកកម្មគឺនិយាយអំពីអ្វីដែលក្រុមហ៊ុនកំពុងធ្វើនាពេលបច្ចុប្បន្ន។ បេសកកម្មរបស់អ្នករាប់បញ្ចូលទាំងមធ្យោបាយជាក់លាក់ដែលអង្គភាពអ្នកមានបំណងចូលរួមវិភាគទានដល់ចក្ខុវិស័យរបស់អ្នក។ សេចក្តីថ្លែងការបេសកកម្មពិពណ៌នាពីអ្វីដែលអង្គភាពនេះធ្វើ ធ្វើជាមួយនណា ឬនណាធ្វើវា និងនិយាយទូលំទូលាយ តើវាធ្វើយ៉ាងម៉េច។ ដូច្នេះសេចក្តីថ្លែងបេសកកម្មមួយនឹងមានសមាសធាតុ៤យ៉ាង ១)ជាប្រភេទអង្គភាព ឬគម្រោងអ្វី? ២)គោលបំណងដែលអង្គភាពឬគម្រោងចង់សម្រេចបាន? ៣)តើការងារនេះធ្វើជាមួយក្រុមគោលដៅឬជាមួយអ្នកណា? ៤)របៀបធ្វើការឬដំណើរការងាររបស់ខ្លួន(វិធីសាស្ត្រណាខ្លះ) (Per Dalin, 1998)។

**គោលដៅ៖** ១)ជាលទ្ធផលដែលចង់បានក្នុងរយៈពេលវែង រីឯការកំណត់គោលដៅវិញជាសេចក្តីប្រាថ្នាសេដ្ឋកិច្ចសង្គមចុងក្រោយនៃកម្មវិធី ដែលបញ្ជាក់នៅក្នុងពាក្យដ៏ទូលំទូលាយមួយ។ គោលដៅបាន សម្តែងនូវលទ្ធផលសរុបដែលមានវត្ថុបំណងនៅក្នុងទស្សនៈវិស័យរយៈពេលវែង (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។

**វត្ថុបំណង៖**(វត្ថុបំណងយុទ្ធសាស្ត្រ)ជាលទ្ធផលលម្អិត ជាក់លាក់ដែលទាញចេញពីគោលដៅក្នុងរយៈពេលកំណត់មួយ និងមានភាពជាក់លាក់ជាងគោលដៅ។ វត្ថុបំណងជាច្រើនពាក់ព័ន្ធនឹងគោលដៅមួយ។

**ចំណុចដៅ៖** ជាលទ្ធផលគ្រោងទុក ជាក់លាក់ និងអាចវាស់វែងបានក្នុងក្របខណ្ឌពេលវេលារបស់ផែនការ (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។

**សូចនាករ៖**គឺជា១)សញ្ញាចង្អុលបង្ហាញ(Indicator) ទាំងឡាយត្រូវបានប្រើប្រាស់ជាសញ្ញាសំរាប់ចង្អុលប្រាប់ ឬសំរាប់ផ្តល់ព័ត៌មានអំពីស្ថានភាព ឬការវិវត្តន៍នៃអ្វីដែលត្រូវធ្វើរួចហើយ ឬអ្វីដែលកំពុងតែត្រូវបានធ្វើ។ គោលបំណងនេះគឺដើម្បីត្រួតពិនិត្យការអនុវត្តន៍ផែនការមួយតាមមធ្យោបាសំយោគ និងសំខាន់បំផុត។ជានិច្ចជាកាលសញ្ញាចង្អុលបង្ហាញអប់រំជាតួលេខដែលទាក់ទងគ្នាសន្ទស្សន៍(indices) អត្រា ឬផលធៀបដែលត្រូវបានគេគណនាដោយការប្រើប្រាស់ស្ថិតិអប់រំហើយបើមិនមានការចាំ បាច់ត្រូវប្រើទិន្ន័យប្រជាសាស្រ្ត(Demographic) ទិន្ន័យសេដ្ឋកិច្ចនិងទិន្ន័យប្រភេទផ្សេងទៀត (ក្រសួងអប់រំ យុវជន និងកីឡា, ១៩៩៩)។ ២)កត្តា ឬអញ្ញតជាបរិមាណឬជាគុណភាពដែលផ្តល់នូវមធ្យោបាយនានាមានលក្ខណៈសាមញ្ញ និងអាចជឿទុកចិត្តបានសម្រាប់ការវាស់វែងសមិទ្ធផលដែលឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរនានាកើតចេញពី អន្តរាគមន៍ណាមួយ ឬក៏ជួយក្នុងការវាយតម្លៃពីការបំពេញការងាររបស់ភ្នាក់ងារអភិវឌ្ឍន៍ណាមួយ (រាជរដ្ឋាភិបាល, ២០១៦)។

**យុទ្ធសាស្រ្ត៖**គឺជា ១)ក្របខណ្ឌការងាររួមដែលនឹងត្រូវសម្រេច និងរបៀបដែលនឹងត្រូវអនុវត្ត ជាសេចក្តីថ្លែងការណ៍សង្ខេបនៃអ្វីដែលអ្នកចង់ធ្វើ សម្រាប់នរណា ជាមួយនរណា និងធ្វើរបៀបណា ២)ជាសំណុំគំនិតជាក់ស្តែងលើរបៀបបង្កើតការប្រើប្រាស់ធនធានដ៏ល្អបំផុត ដើម្បីសម្រេចបាននូវគោលដៅរបស់អ្នក (IDWF-ILO, ២០១៧) ៣)ជាមធ្យោបាយ ឬ វិធីមួយសម្រាប់សម្រេចគោលនយោបាយ ឬ វត្ថុបំណងអប់រំ ឬឆ្លើយតបទៅនឹងតម្រូវការអប់រំ ជាយុទ្ធវិធីក្នុងការដោះស្រាយបញ្ហា ដើម្បីសម្រេចចំណុចដៅ (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។

**សកម្មភាព៖** កិច្ចការដែលត្រូវតែអនុវត្ត ក្នុងអំឡុងពេលជាក់លាក់ណាមួយនៃផែនការដើម្បីសម្រេចកម្មវិធី (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។

### ២.១.២.និយមន័យការរៀបចំផែនការអប់រំ

**ផែនការការកម្មគឺជា៖** មធ្យោបាយជាប្រព័ន្ធមួយដើម្បីដោះស្រាយបញ្ហានាពេលអនាគត់។មធ្យោបាយជាប្រព័ន្ធមានន័យថា "ធ្វើជាជំហានៗ" ដោយគិតគូរយ៉ាងប្រុងប្រយ័ត្នអំពី ធនធានដែលមាន។ដោះស្រាយបញ្ហាមួយមានន័យថា ធ្វើអោយមានបំរែបំរួល(changes) ដែលនឹងអាចកាត់បន្ថយ ឬលុបបំបាត់នូវឧបសគ្គ ឬបញ្ហានោះ។បញ្ហាមួយគឺជាឧបសគ្គធ្ងន់ធ្ងរឬលក្ខខ័ណ្ឌដែលរាំងស្ទះនូវការសម្រេចវត្ថុបំណងមួយ (ក្រសួងអប់រំ យុវជន និងកីឡា, ១៩៩៨)។

**ការរៀបចំផែនការគឺជា៖** ១)ការប្រមើលមើលប្រកបដោយបញ្ញាញាណលើសភាពការណ៍នាពេលអនាគតដែលអាចកើតមាឡើង២)ការជ្រើសរើសស្ថានភាពដែលចង់បានដើម្បីសម្រេចនូវវត្ថុបំណង៣)ការប្តេជ្ញាចិត្តក្នុងការជ្រើសរើសសកម្មភាពត្រឹមត្រូវដើម្បីសម្រេចនូវគោលបំណងទាំងអស់នោះ៤)កាចំណាយថវិកាតិចបំផុតតាមដែលអាចធ្វើទៅបាន៥)ការគិតអំពីអនាគត និងជាការព្យាយាមគ្រប់គ្រងព្រឹត្តិការណ៍អនាគតតាមរយៈការរៀបចំ និងគ្រប់គ្រងធនធានរហូតដល់ពួកគេសម្រេចបានដោយជោគជ័យនូវវត្ថុបំណងដែលបានដាក់ចុះ (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។

### ២.១.៣.និយមន័យផែនការអប់រំ

**ផែនការអប់រំគឺជា៖** ១)ការវិភាគប្រព័ន្ធនៃមជ្ឈដ្ឋានជុំវិញអប់រំ ការតាក់តែង និងជំរើសសំរាំងយុទ្ធវិធីហើយ និងការអនុវត្តផែនការប្រតិបត្តិមួយដោយមានការពិនិត្យតាមដាន និងវង្វាយតំលៃ ហើយ និងការរៀបចំថវិកាសំរាប់ផែនការ ព្រមទាំងការពាក់ព័ន្ធជារឿយៗនៃមន្រ្តីផែនការ មន្រ្តីថ្នាក់ក្រសួង គ្រូបង្រៀន មាតាបិតាសិស្ស និងសហគមន៍ (ក្រសួងអប់រំ យុវជន និងកីឡា, ១៩៩៨)។ ២)ការវិភាគប្រព័ន្ធនូវបញ្ហានៃមជ្ឈដ្ឋានអប់រំ(ដោយប្រើប្រាស់សូចនាករអប់រំ)ការតាក់តែង និងជ្រើសរើសយុទ្ធវិធី ព្រមទាំការអនុវត្តផែនការប្រតិបត្តិមួយដោយមានការពិនិត្យតាមដានវាយតម្លៃ និងការរៀបចំថវិកាដើម្បីអនុវត្តផែនការឱ្យបានជោគជ័យ (ក្រសួងអប់រំ យុវជន និងកីឡា, ២០០៩)។

### ២.១.៤.និយមន័យផែនការ

**ផែនការគឺជា៖**១)ឯកសារមូលដ្ឋានរបស់អង្គភាព ឬការងារដែលបានកើតចេញពីការចងក្រងជាប្រព័ន្ធស្តីពី ព័ត៌មានពាក់ព័ន្ធទៅនឹងលទ្ធផល នៃការសម្រេចចិត្តរបស់មន្ត្រីគ្រប់គ្រងអង្គភាពការកំណត់ចក្ខុវិស័យ បេសកកម្ម គោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីការងារដែលត្រូវអនុវត្តតាមដំណាក់កាល និងឆ្នាំនីមួយៗដើម្បីសម្រេចនូវគោលដៅ ការងារ និងកម្មវិធីរបស់អង្គភាព (ក្រសួងអប់រំ យុវជន និងកីឡា, ២០១០) ២)ការបង្ហាញពី ព័ត៌មានដែលមានលក្ខណៈវិទ្យាសាស្ត្រពាក់ព័ន្ធនឹង ការគ្រប់គ្រង ដំណើរការកម្មវិធីការងារលទ្ធផលរំពឹងទុក ទីកន្លែង ពេលវេលា អ្នកទទួលខុសត្រូវ និងថវិកាគាំទ្រផងដែរ។៣)មូលដ្ឋាននៃដំណើរការគ្រប់គ្រងដែលអ្នកគ្រប់គ្រងគ្រប់រូប បានកំណត់គោលដៅការងារ ជ្រើសរើសសកម្មភាពដើម្បីឈានទៅសម្រេចគោលដៅនោះ ៤)ត្រីវិស័យដែលគេប្រើសម្រាប់ចង្អុលទិសដៅ និងដែនកំណត់ការងារដែលវិស័យ និងផ្នែកនីមួយៗត្រូវធ្វើ។ ផ្អែកលើមូលដ្ឋានទិន្នន័យដែលបានកំណត់ក្នុងផែនការ អ្នកគ្រប់គ្រងគ្រប់លំដាប់ថ្នាក់ អាចទទួលបានឱកាសបង្កើតការច្នៃប្រឌិតសម្រាប់ដំណើរការឈានទៅសម្រេចគោលដៅនៃការងារតាមភារកិច្ចរបស់ខ្លួន (ក្រសួងអប់រំ យុវជន និងកីឡា, ២០១០)។ ៥)មធ្យោបាយជាប្រព័ន្ធមួយដើម្បីដោះស្រាយបញ្ហានាពេលអនាគត។ មធ្យោបាយជាប្រព័ន្ធមានន័យថាធ្វើជាជំហានៗ ដោយគិតគូរយ៉ាងប្រុងប្រយ័ត្នអំពីធនធាន និងពេលវេលាដែលមាន។ ដោះស្រាយបញ្ហាគឺធ្វើឱ្យមានការប្រែប្រួលដែលមានលក្ខណៈកាន់តែល្អប្រសើរឡើងឬអាចនិយាយម្យ៉ាងទៀត ថាដើម្បីលុបបំបាត់ ឬកាត់បន្ថយគម្លាតរវាងស្ថានភាពបច្ចុប្បន្ន និងស្ថានភាពដែលយើងចង់បានស្ថានភាពពេលអនាគត។បញ្ហាគឺជាឧបសគ្គដែលធ្វើឱ្យរាំងស្ទះដល់ការរីចម្រើន (ក្រសួងអប់រំ យុវជន និងកីឡា, ២០០៦) ។

### ២.១.៥.និយមន័យផែនការកែលម្អសាលារៀន

ផែនការកែលម្អសាលារៀនគឺជា៖ ផ្លូវមួយដែលបានកំណត់ពីការផ្លាស់ប្តូរសាលារៀនដើម្បីឱ្យប្រសើរឡើងនូវកម្រិតនៃលទ្ធផលសិក្សារបស់សិស្ស និងបង្ហាញពីរបៀប និងពេលវេលាដែលការផ្លាស់ប្តូរទាំងនោះនឹងត្រូវបានធ្វើឡើង (BrainFidler, 2002)។ ការធ្វើផែនការកែលម្អរសាលារៀនមានពីរប្រភេទ១)ផល

សម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ និង២) ផែនការកែលម្អសាលារៀន និងថវិកាប្រចាំឆ្នាំ។ផលសម្រេច និងក្រុមគោលដៅរយៈពេល៣ឆ្នាំ ត្រូវប្រើជាក្របខ័ណ្ឌសម្រាប់រៀបចំផែនការកែលម្អសាលារៀនប្រចាំឆ្នាំ។ទិន្នន័យដែលបានមកពីការធ្វើស្វ័យវាយតម្លៃពីការអនុវត្តរបស់សាលារៀន ការវាយតម្លៃឬធ្វើតេស្តសិស្ស ការវាយតម្លៃគ្រូបង្រៀន និងការធ្វើផែនការថ្នាក់រៀននិងសាលារៀនផ្តល់នូវព័ត៌មានសម្រាប់ការធ្វើផែនការកែលម្អសាលារៀនបានសព្វគ្រប់ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

### ២.១.៦.និយមន័យផែនការអភិវឌ្ឍន៍សាលារៀន

**ការអភិវឌ្ឍគឺជា៖**ដំណើរការមួយដែលបង្កើតឱ្យមានកំណើន វឌ្ឍនភាព ការផ្លាស់ប្តូរវិជ្ជមាន ឬការបន្ថែមផ្នែករូបវន្ត សេដ្ឋកិច្ច បរិស្ថាន សង្គម និងប្រជាសាស្ត្រ (Per Dalin, 1998)។ រីឯផែនការអភិវឌ្ឍសាលារៀនគឺជា១)ដំណើរការរៀនសូត្រដ៏ស្មុគស្មាញ ដែលក្នុងនោះការផ្លាស់ប្តូរលើសលុបលើលក្ខណៈវប្បធម៌សាលា។ (Per Dalin, 1998)។ ២)ផែនការមួយដែលចាប់យកចក្ខុវិស័យវែងឆ្ងាយសម្រាប់សាលារៀន ដែលក្នុងនោះគោលដៅខ្លីត្រូវបានកំណត់ និងអាចគ្រប់គ្រងបាន (BrainFidler, 2002)។

### ២.១.៧.និយមន័យផែនការយុទ្ធសាស្ត្រ

**ផែនការយុទ្ធសាស្ត្រគឺជា៖** ដំណើរការនៃការកំណត់យុទ្ធសាស្ត្រ ទិសដៅ និងសម្រេចចិត្តរបស់ស្ថាប័នលើការប្រើប្រាស់ធនធានដើម្បីអនុវត្តយុទ្ធសាស្ត្រទាំងនេះ។ ជាការវាយតម្លៃលើបេសកម្មរបស់ស្ថាប័ន និងបញ្ហាយុទ្ធសាស្ត្រដើម្បីពង្រឹងការអនុវត្តនាពេលបច្ចុប្បន្ននិងកំណត់តម្រូវការថ្មី។ ជាការពិនិត្យបរិយាកាសជុំវិញស្ថានភាពប្រកួតប្រជែង គោលនយោបាយដែលគាំទ្រ និងគោលបំណងដែលស្ថាប័នចង់សម្រេច។តាមលោក Dalin (1998) ជាតុសំខាន់ៗក្នុងផែនការយុទ្ធសាស្ត្ររួមមាន (១) ចក្ខុវិស័យ (២) បេសកម្ម និងគុណតម្លៃ (៣) វិភាគបរិបទ និងសមត្ថភាពស្ថាប័ន (៤)ចំណុចដៅជាយុទ្ធសាស្ត្រ (៥) ការប្រមើលមើលលទ្ធផល(ផលជះ ផលសម្រេចពេលមធ្យម លទ្ធផលភ្លាមៗ) និង (៦) ការកំណត់ក្របខ័ណ្ឌវាស់វែង និងសូចនាករ (Dalin, 1998)។ រីឯការរៀបចំផែនការយុទ្ធសាស្ត្រគឺជាដំណើរការសម្រាប់កំណត់ស្ថានភាពជាទីគាប់ប្រសើរដែលត្រូវតែសម្រេចឱ្យបាន និងការងារពាក់ព័ន្ធដែលត្រូវអនុវត្តដើម្បីសម្រេចបានគោលដៅចំណាយសមស្របមួយ។ ការរៀបចំផែនការយុទ្ធសាស្ត្រ ក៏ជាឧបករណ៍គ្រប់គ្រងដែលប្រើប្រាស់ឡើង

ដើម្បីជួយឱ្យអង្គភាពមួយអាចលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តការងាររបស់ខ្លួន ដោយធានាថា សមាជិករបស់ខ្លួនធ្វើការឆ្ពោះទៅរកការសម្រេចបានគោលដៅតែមួយ និងកែសម្រួលទិសដៅរបស់អង្គភាពជាបន្តបន្ទាប់ ដើម្បីសម្របតាមស្ថានភាពប្រែប្រួលដោយផ្អែកលើលទ្ធផលសម្រេចបាន (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។

### ២.១.៨.និយមន័យផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

**ផែនការយុទ្ធស្ត្រអភិវឌ្ឍសាលារៀនគឺជា៖**គម្រោងមួយដែលមានយុទ្ធសាស្ត្រនិងសកម្មភាពជាក់លាក់សម្រាប់អនុវត្តដើម្បីធ្វើឱ្យអ្នកទទួលខុសត្រូវសម្រេចបាននូវលទ្ធផលរយៈពេលវែងណាមួយ (ក្រសួងអប់រំ យុវជន និងកីឡា, ១៩៩៩)

## ២.២. ប្រភេទផែនការនៅកម្ពុជា

យោងតាមចក្ខុវិស័យកម្ពុជាឆ្នាំ២០៣០ ចក្ខុវិស័យឆ្នាំ២០៥០ កម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៦នៃរដ្ឋសភា ក្របខ័ណ្ឌគោលដៅអភិវឌ្ឍប្រកបដោយចីរភាពកម្ពុជា២០១៦-២០៣០ សំដៅប្រែក្លាយកម្ពុជា ជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នាឆ្នាំ២០៣០ និងប្រទេសមានចំណូលខ្ពស់នាឆ្នាំ២០៥០ ដែរធ្វើឱ្យរាជរដ្ឋាភិបាលបានបង្កើតឡើងនូវផែនការជាច្រើនដែលមានរយៈពេលវែង រយៈពេលមធ្យម និងរយៈពេលខ្លី (រាជរដ្ឋាភិបាលកម្ពុជា, ២០១៩)។ ផែនការរយៈពេលវែង រួមមាន ផែនការជាតិអប់រំសេរាប់ទាំងអស់គ្នា គោលដៅអភិវឌ្ឍន៍សហសវត្សរ៍(MDGs) និងគោលដៅអភិវឌ្ឍប្រកបដោយចីរភាព(SDGs)។ ផែនការរយៈពេលមធ្យមរួមមានផែនការផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) និងផែនការយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ(PRSP)។ រីឯផែនការរយៈពេលខ្លី រួមមាន ផែនការថវិកាប្រចាំឆ្នាំ និងផែនការក្របខណ្ឌប្រចាំឆ្នាំ។

## ២.៣.ប្រភេទផែនការក្នុងវិស័យអប់រំនៅកម្ពុជា

ផែនការមានប្រភេទផ្សេងៗគ្នា ដែលអាស្រ័យទៅលើរយៈពេល វិសាលភាព ប្រភេទបញ្ហាដែលត្រូវដោះស្រាយ និងថ្នាក់រៀបចំផែនការ។វិធីសាស្ត្រនៃការធ្វើផែនការ ផ្លាស់ប្តូរ ឬខុសគ្នាទៅតាមកត្តាខាងលើ

នេះ។ ផែនការទាំងអស់មានរយៈពេលខុសៗគ្នា សំរាប់ធ្វើអោយបានសម្រេចវត្ថុបំណង។ពាក្យផ្សេងៗគ្នាដែលគេប្រើដើម្បីពិពណ៌នា និងធ្វើចំណាត់ប្រភេទផែនការដោយអនុលោមតាមពេលវេលាដើម្បីសម្រេចវត្ថុបំណងនានា ៖ផែនការរយៈពេលតិចជាង៣ឆ្នាំ ត្រូវបានចាត់ទុកជាផែនការរយៈពេលខ្លី ពី៣ទៅ៥ឆ្នាំត្រូវបានចាត់ទុកជាផែនការរយៈពេលមធ្យម និងច្រើនជាង ៥ឆ្នាំ (១០ឆ្នាំ ទៅ២៥ឆ្នាំ)ត្រូវបានចាត់ទុកជាផែការរយៈពេលវែង។ (ក្រសួងអប់រំ យុវជន និងកីឡា, ១៩៩៩)។ផែនការរយៈពេលវែងថ្នាក់ជាតិ និងក្រោមជាតិរួមមានផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ជាតិ(ESP) ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី/ខេត្ត(ESP) ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ក្រុង/ស្រុក/ខ័ណ្ឌ(ESP) និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន(SDSP)។ ផែនការរយៈពេលមធ្យមថ្នាក់ជាតិ និងក្រោមជាតិរួមមានផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ជាតិ(BSP) ផែនការយុទ្ធសាស្ត្រថវិកាថ្នាក់រាជធានី/ខេត្ត(BSP) ផែនការយុទ្ធសាស្ត្រថវិកាថ្នាក់ក្រុង/ស្រុក/ខ័ណ្ឌ(BSP) និងផែនការយុទ្ធសាស្ត្រថវិកាថ្នាក់សាលារៀន(BSP) ។រីឯផែនការរយៈពេលខ្លីថ្នាក់ជាតិ និងក្រោមជាតិរួមមាន ផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ជាតិ (AOP) ផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ខេត្ត (AOP) ផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ក្រុង/ស្រុក/ខ័ណ្ឌ (AOP) ផែនការប្រតិបត្តិប្រចាំឆ្នាំថ្នាក់ជាតិ (AOP) និងផែនការប្រតិបត្តិថ្នាក់សាលារៀន (AOP) ។

## ២.៤.ទម្រង់ផែនការក្នុងវិស័យអប់រំ

### ២.៤.១.ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់ក្រសួង (M-ESP)

**ផែនការយុទ្ធសាស្ត្រអប់រំ (M-ESP)** បង្កើតនូវក្របខ័ណ្ឌ និងសារចរណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដើម្បីកំណែទម្រង់អប់រំសម្រាប់រយៈពេលប្រាំឆ្នាំបន្ទាប់។ ផែនការយុទ្ធសាស្ត្រអប់រំថ្នាក់ជាតិដំបូងត្រូវបានបង្កើនឡើងនៅឆ្នាំ២០០១ ហើយបញ្ហាប្រឈមនៅឆ្នាំបន្តបន្ទាប់ គឺការបង្កើតផែនការយុទ្ធសាស្ត្រអប់រំនៅគ្រប់រាជធានី-ខេត្ត (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។ ទម្រង់ផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩)គឺត្រូវបានផ្តោតលើខ្លឹមសារសំខាន់ចំនួនប្រាំមួយរួមមាន១)សេចក្តីផ្តើម និងការវិភាគការបំពេញការងារ ២០១៤-២០១៨ ២)ក្របខ័ណ្ឌនៃការ

អភិវឌ្ឍជាតិ ៣)ផែនការតាមអនុវិស័យឆ្នាំ២០១៩-២០២៣ ៤)យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា៥)ផែនការហិរញ្ញប្បទានឆ្នាំ២០១៩-២០២៣ ៦)ការពិនិត្យតាមដាន និងវាយតម្លៃ។

### ២.៤.២.ផែនការយុទ្ធសាស្ត្រវិស័យអប់រំថ្នាក់រាជធានី ខេត្ត (P-ESP)

**មន្ទីរអប់រំខេត្ត (POE)** រៀបចំ និងតាមដានផែនការយុទ្ធសាស្ត្រអប់រំរបស់ខេត្ត។ ការវិវឌ្ឍន៍នៃផែនការយុទ្ធសាស្ត្រអប់រំរបស់ខេត្ត (ដែលនឹងត្រូវបានរៀបចំ ដោយយកតាមគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា) ត្រូវបានគេរាយការណ៍នៅក្នុងសន្និបាតអប់រំខេត្ត។ ខេត្តមានតួនាទីគ្រប់គ្រងសាលាមធ្យមសិក្សា និងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ដោយរាប់បញ្ចូលការប្រគល់ភារកិច្ចក្រោមរូបភាពវិមជ្ឈការ។ អភិបាលខេត្ត នៃក្រុមប្រឹក្សាភិបាលខេត្ត ធ្វើជាអធិបតីភាពនៃគណកម្មការការអប់រំសម្រាប់ទាំងអស់គ្នារបស់ខេត្ត។ មន្ទីរអប់រំខេត្ត (POE) រៀបចំនូវថវិកាអប់រំរបស់ខេត្តសម្រាប់ដាក់ជូនអភិបាលខេត្ត (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។ ទម្រង់នៃការធ្វើបច្ចុប្បន្នភាពផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ (P-ESP) គឺត្រូវបានផ្តោតលើខ្លឹមសារសំខាន់ចំនួនប្រាំមួយរួមមាន ១)សេចក្តីផ្តើម និងការវិភាគការបំពេញការងារ ២០១៤-២០១៨ ២)ក្របខ័ណ្ឌនៃការអភិវឌ្ឍជាតិ ៣)ផែនការតាមអនុវិស័យឆ្នាំ២០១៩-២០២៣ ៤)យុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ៥)ផែនការហិរញ្ញប្បទានឆ្នាំ២០១៩-២០២៣ ៦)ការពិនិត្យតាមដាន និងវាយតម្លៃដូចថ្នាក់ជាតិដែរតែការវិភាគ និងរៀបចំគឺត្រឹមកម្រិតថ្នាក់ខេត្តតែប៉ុណ្ណោះ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨)។

### ២.៤.៣.ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក/ខ័ណ្ឌ (D-SDP)

**ការិយាល័យអប់រំស្រុក** (DOE) រៀបចំផែនការការងារប្រចាំឆ្នាំដោយផ្អែកទៅលើផែនការយុទ្ធសាស្ត្រអប់រំរបស់ខេត្ត និងរៀបចំរបាយការណ៍ស្តីពីការរីកចំរើនប្រចាំត្រីមាស។ ការិយាល័យអប់រំស្រុក មានតួនាទីគ្រប់គ្រងសាលាបឋមសិក្សាដោយរាប់បញ្ចូលការប្រគល់ភារកិច្ចក្រោមរូបភាពវិមជ្ឈការ ការិយាល័យអប់រំស្រុក (DOE) រៀបចំថវិកាអប់រំរបស់ស្រុក សម្រាប់ដាក់ជូនមន្ទីរអប់រំខេត្ត (PEO)។ អភិបាលស្រុក នៃក្រុមប្រឹក្សាភិបាលស្រុក ធ្វើជាអធិបតីភាពនៃគណកម្មការការអប់រំសម្រាប់ទាំងអស់គ្នារបស់ស្រុក។ ក្រុមពិនិត្យតាមដានបច្ចេកទេសថ្នាក់ស្រុក District Technical Monitoring Team (DTMT) គាំទ្រការអនុវត្ត

តាមដាន និងការធ្វើរបាយការណ៍ពីផែនការរបស់ស្រុកនៅកម្រិតសាលារៀន។ (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។ ទម្រង់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ការិយាល័យអប់រំយុវជននិងកីឡាក្រុង/ស្រុក(៥ឆ្នាំ) (D-SDP) គឺត្រូវបានផ្តោតលើខ្លឹមសារសំខាន់ចំនួនប្រាំមួយរួមមាន១) សេចក្តីផ្តើមនិងការវិភាគការបំពេញការងារ ២០១៥-២០១៩២)អាទិភាពនៃការអភិវឌ្ឍរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងគោលនយោបាយអប់រំ ២០១៩-២០២៣ និងចក្ខុវិស័យឆ្នាំ២០៣០ ស្តីពីការអប់រំនៅកម្ពុជា និងផែនការអភិវឌ្ឍន៍/កម្មវិធីវិនិយោគរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ (៣-៥ឆ្នាំ) ៣)ផែនការតាមអនុវិស័យឆ្នាំ ២០១៩-២០២៣ ៤)ការគ្រប់គ្រង និងការអភិវឌ្ឍសមត្ថភាពនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ៥)ផែនការហិរញ្ញប្បទាន ២០១៩-២០២៣ និង ៦)ការពិនិត្យតាមដាន និងវាយតម្លៃផែនការយុទ្ធសាស្រ្តវិស័យអប់រំនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ (ក្រសួងអប់រំ យុវជន និងកីឡា, ២០២០)។

### ២.៤.៤.ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀន (SDSP) OR (S-ESP)

**គណកម្មការគាំទ្រសាលា** (LSSC)៖ សាលារៀនដោយមានការគាំទ្រពីគណកម្មការគាំទ្រសាលា (LSSC) រៀបចំផែនការអភិវឌ្ឍសាលា និងរៀបចំចំណាយ និងធ្វើរបាយការពីថវិការសាលា សម្រាប់ការផ្តល់ថវិកាតាមផ្នែកនីមួយៗ (ថវិការកម្មវិធី) និងប្រភពថវិកា សម្រាប់ការកែលម្អសាលាដ៏ទៃទៀត តាមដានការរីកចំរើន និងរៀបចំរបាយការណ៍សម្រាប់ការិយាល័យអប់រំស្រុក (DOE) (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។ ទម្រង់ផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារយៈពេល៥ឆ្នាំ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩) គឺត្រូវបានផ្តោតលើខ្លឹមសារសំខាន់ចំនួនដប់មួយរួមមាន ១)សេចក្តីផ្តើម ២)ប្រវត្តិសាលារៀន ៣)ចក្ខុវិស័យ៤)បេសកកម្ម ៥)ស្ថានភាពបច្ចុប្បន្ន ៦)គោលបំណង ៧)ចំណុចដៅប្រចាំឆ្នាំរបស់សាលារៀន ៨)យុទ្ធសាស្រ្ត និងសកម្មភាព (ដើម្បីសម្រេចគោលបំណង និងដោះស្រាយបញ្ហាប្រឈម) ៩) តម្រូវការហិរញ្ញប្បទាន (តាមឆ្នាំនីមួយៗ សម្រាប់រយៈពេល៥ឆ្នាំ) ១០)យន្តការពិនិត្យតាមដាន និងវាយតម្លៃ និងតារាងឧបសម្ព័ន្ធ។

## ២.៥. ចរិតលក្ខណៈរបស់ផែនការ

អ្នកគ្រប់គ្រង មានការគិតគូរអំពីដំណើរការនៃការធ្វើផែនការ ដើម្បីធ្វើឱ្យសម្រេចគោលដៅរបស់អង្គភាព។ គេចាត់ទុកថាផែនការល្អ គឺជាផែនការដែលជួយឱ្យអ្នកដឹកនាំសម្រេចសូចនាករ ចំណុចដៅ និងគោលដៅរបស់អង្គភាព។ ដូចនេះ ផែនការដែលល្អ គួរមានចរិតលក្ខណៈ ១)មានការកំណត់វត្ថុបំណងច្បាស់លាស់ ២)មានលក្ខណៈសាមញ្ញ ងាយយល់ ៣)ផ្តល់នូវការវិភាគ និងការបែងចែកសកម្មភាពសមស្រប ៤)មានភាពបត់បែនបាន ៥)មានតុល្យភាព អាចអនុវត្តបាន និងសមស្របតាមទំហំ និងទម្រង់អង្គភាព ៦)កំណត់ពេលវេលាច្បាស់លាស់ ៧)ប្រើប្រាស់ធនធានដែលអាចរកបាន ៨)មានការចូលរួមពីបុគ្គលិក ៩)មានការឯកភាពគ្នា ១០)ពិចារណាបានគ្រប់ជ្រុងជ្រោយ ១១)សន្សំសំចៃ (Economical Planning)។ម្យ៉ាងវិញទៀតយើងអាចសង្ខេបចរឹតលក្ខណៈរបស់ផែនការមានបីសំខាន់ គឺ ប្រជាធិបតេយ្យ (មានការចូលរួម) វិទ្យាសាស្ត្រ និងច្បាប់ (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។

## ២.៦.គោលបំណង និងសារៈសំខាន់នៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

យោងតាមផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ របស់ក្រសួងអប់រំ យុវជន និងកីឡា ការងារចាំបាច់ គឺការធ្វើសុខដុមនីយកម្មផែនការថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ។ ចំណុចនេះមានសារៈសំខាន់ក្នុងការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដើម្បីផ្សាភ្ជាប់គោលនយោបាយ និងផែនការ ។ ដូច្នេះហើយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនក៏ត្រូវតែមានសង្គតភាពជាមួយផែនការថ្នាក់ជាតិ ថ្នាក់ខេត្ត ថ្នាក់ស្រុកដែរដោកត្តាធ្វើឱ្យការរៀបចំផែនការត្រូវឆ្លើយតបទៅនឹងសូចនាករ គោលដៅ យុទ្ធសាស្ត្រ និងគោលនយោបាយរបស់ក្រសួង ហើយការរៀបចំផែនការនេះគឺវាមានសារៈសំខាន់ណាស់ក្នុងការជួយឱ្យសាលារៀន និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋាន និងវិស័យអប់រំឱ្យទទួលបាននូវ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩) ១) ដោះស្រាយបញ្ហាប្រឈមសំខាន់ៗ និងចម្បងដែលសាលារៀនបានរកឃើញតាមរយៈស្វ័យវាយតម្លៃសាលារៀន និងធ្វើការអភិវឌ្ឍសាលាឱ្យរីកចម្រើន ២)ទស្សនៈ និងចំណេះដឹងទូលំទូលាយក្នុងការអនុវត្តការងារគ្រប់គ្រងសាលារៀនដោយផ្អែកលើផលសម្រេច និងផ្តោតជាចម្បងលើគុណភាពលទ្ធផលសិក្សារបស់សិស្ស

៣)លទ្ធភាពបកស្រាយបញ្ញត្តិ និងគោលការណ៍របស់ឯកសារគោលនយោបាយ សេចក្តីណែនាំ និងលិខិតបទដ្ឋានគតិយុទ្ធនានា ដែលបានដាក់ឱ្យអនុវត្ត និងផ្សព្វផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍពាក់ព័ន្ធនានាទៅជាសកម្មភាពអនុវត្តជាក់ស្តែងនៅតាមសាលារៀននីមួយៗ ដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍសាលារៀនឱ្យឆ្លើយតបទៅនឹងផែនការយុទ្ធសាស្ត្រវិស័យអប់រំ និងគោលនយោបាយអប់រំ របស់ក្រសួងអប់រំ យុវជន និងកីឡា ៤)បំណិនក្នុងការចលនា និងសម្របសម្រួលទាក់ទាញការចូលរួមពីសំណាក់សិស្សានុសិស្ស គ្រូបង្រៀន ឪពុកម្តាយ គណៈកម្មការគ្រប់គ្រងសាលារៀន អជ្ញាធរដែនដី សហគមន៍ និងអ្នកពាក់ព័ន្ធក្នុងមូលដ្ឋានលើការអនុវត្តសកម្មភាពប្រចាំឆ្នាំនីមួយៗ ៥)ស្វ័យវាយតម្លៃសាលារៀនដើម្បីឱ្យបានដឹងពីចំណុចជោគជ័យ និងចំណុចត្រូវកែលម្អដោយបានកំណត់មុខសញ្ញាទទួលខុសត្រូវ ក្នុងការអនុវត្តសកម្មភាពជាក់ស្តែងក្នុងដំណើរការប្រចាំថ្ងៃក្នុងថ្នាក់រៀន សាលារៀន និងសហគមន៍ ៦)ធ្វើផែនការអភិវឌ្ឍសាលារៀនដោយផ្អែកលើចំណុចដែលត្រូវកែលម្អដែលបានមកពីលទ្ធផលស្វ័យវាយតម្លៃសាលារៀន លទ្ធផលនៃការងារអធិការកិច្ចផ្ទៃក្រៅ ដោយកំណត់មុខសញ្ញាទទួលខុសត្រូវលើការអនុវត្តសកម្មភាពជាក់ស្តែងទៅក្នុងផែនការអភិវឌ្ឍន៍សាលារៀនដើម្បីក្លាយទៅជាសកម្មភាពនៃដំណើរការប្រចាំថ្ងៃក្នុងថ្នាក់រៀន សាលារៀន និងសហគមន៍ ៧)ពិនិត្យតាមដាននិងវាយតម្លៃសាលារៀននៅដើមឆ្នាំសិក្សា និងដំណើរការអនុវត្តសកម្មភាពក្នុងឆ្នាំសិក្សាដោយប្រើប្រាស់បញ្ជីពិនិត្យតាមដាន និងវាយតម្លៃសមិទ្ធផលការងាររបស់សាលារៀន (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។

## ២.៧.សមាសភាពសំខាន់ៗក្នុងការចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

ជាទូទៅការរៀបចំគម្រោង ឬការធ្វើផែនការផ្សេងៗទាមទារឱ្យមានព័ត៌មានជាក់លាក់ និងមានភាពទាក់ទង ពាក់ព័ន្ធជាច្រើនដូចជា ការព្រមព្រៀងពីអ្នកបង្កើតគម្រោង និងអ្នកអនុវត្តគម្រោងព្រោះការព្រមព្រៀងនេះគឺត្រូវបានផ្តល់មូលនិធិសម្រាប់គម្រោង និងម្ចាស់ផ្តល់ជំនួយឬអង្គភាពថវិកា រដ្ឋ ជាតិ ដៃគូអភិវឌ្ឍ សមាគមន៍ សហគមន៍ និងសប្បុរសជន ហើយធ្វើយ៉ាងណាឱ្យប្រាកដថា មូលនិធិ ឬថវិកាត្រូវបានយកមកប្រើប្រាស់ និងអនុវត្តសកម្មភាពបានល្អប្រសើរ ។ ក្នុងការអនុវត្តធ្វើផែនការ ត្រូវធ្វើឡើងដោយចរឹក

លក្ខណៈរបស់ផែនការ លទ្ធិប្រជាធិបតេយ្យ (មានការចូលរួម) មានលក្ខណៈវិទ្យាសាស្ត្រ និងច្បាប់។ ការធ្វើផែនការរួមគ្នា ឬធ្វើផែនការដោយមានការចូលរួម គឺធ្វើឱ្យអ្នកជាប់ពាក់ព័ន្ធក្នុងការងារបញ្ចេញមតិយោបល់ និងព្រមព្រៀងគ្នាទាំងអស់ក្នុងការដាក់ចេញសកម្មភាពអ្វីមួយដែលត្រូវធ្វើ ។តាមទម្លាប់ចាស់ការធ្វើផែនការពីសម័យមុនគេធ្វើទៅតាមការរៀបចំបែបបុរាណ (ធ្វើពីលើចុះក្រោម កំណត់សកម្មភាព និងថវិកាស្រាប់ ) ការធ្វើរបៀបនេះធ្វើឱ្យការកំណត់សកម្មភាពមិនចំតាមគោលដៅរបស់សាលានីមួយៗ និងពុំសូវអភិវឌ្ឍលឿនទេ។ បើនិយាយអំពីការរៀបចំផែនការតាមរបៀបថ្មីឬតាមបែបយុទ្ធសាស្ត្រ គឺក្រុមអ្នករៀបចំត្រូវធ្វើការងារជាមួយគ្នា និងធ្វើការស្វ័យវាយតម្លៃសាលារៀនរបស់ខ្លួន រកបញ្ហាប្រឈមចម្បងៗហើយជជែកគ្នា ប្រឹក្សាមតិយោបល់ និងដាក់ចេញនូវយុទ្ធសាស្ត្រ និងសកម្មភាពដើម្បីឱ្យអង្គភាព ឬសាលារៀនមានការអភិវឌ្ឍ និងរីកចំរើន ប្រកបដោយប្រសិទ្ធភាព និងគុណភាពទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធដូចជា គណៈគ្រប់គ្រងសាលា នាយក នាយិកា សាលា នាយករង នាយិការង មន្ត្រីរដ្ឋបាល លោកគ្រូ អ្នកគ្រូ សហគមន៍ មាតាបិតាសិស្ស អាណាព្យាបាលសិស្ស និងសិស្ស ព្រមទាំងដៃគូអភិវឌ្ឍ និងអង្គភាពពាក់ព័ន្ធទាំងអស់ (ក្រសួងអប់រំ យុវជន និងកីឡា, ២០០៩)។ ដូច្នេះហើយគណៈគ្រប់គ្រងត្រូវបែងការ តួនាទី និងភារកិច្ចដូចជា ១)គណៈគ្រប់គ្រងសាលា នាយកសាលាដើរតួនាទីយ៉ាងសំខាន់ក្នុងការដឹកនាំ និងការគ្រប់គ្រងដំណើរការរៀបចំផែនការ ព្រមទាំងផ្តល់ការពន្យល់ណែនាំច្បាស់លាស់ពីដំណើរការរៀបចំ និងជួយដល់ភាគីពាក់ព័ន្ធយល់ដឹងច្បាស់ពីតួនាទីក្នុងដំណើរការ ២)មានតួនាទីក្នុងការផ្តួចផ្តើមដំណើរការរៀបចំបង្កើតបរិយាកាសអំណោយផល ដល់កិច្ចសហការលើកទឹកចិត្តបុគ្គលិកឱ្យមានការចូលរួមរៀបចំផែនការ និងធនធាន រៀបចំនិតិវិធីពិគ្រោះយោបល់ ទំនាក់ទំនង និងវាយតម្លៃផែនការ ៣)ថ្នាក់ដឹកនាំក្រុមបច្ចេកទេស តំណាងឱ្យក្រុមគ្រូបង្រៀនតាមមុខវិជ្ជា ដែលដើរតួនាទីសំខាន់ក្នុងការរៀបចំផែនការ និងជួយឱ្យប្រសើរឡើងនូវការបង្រៀន និងរៀនតាមមុខវិជ្ជានីមួយៗ ៤)គ្រូបង្រៀនជាអ្នកផ្តល់នូវព័ត៌មានចាំបាច់ទាក់ទងនឹងដំណើរការបង្រៀន និងរៀនចូលរួមយ៉ាងសំខាន់អំឡុងពេលរៀបចំផែនការអភិវឌ្ឍសាលារៀនក្នុងការកំណត់កត្តាអាទិភាព គោលដៅនិងបង្កើតយុទ្ធសាស្ត្រអនុវត្តសម្រាប់ផែនការ និងចូលរួមយ៉ាងសកម្មក្នុងការបំភ្លឺចក្ខុវិស័យ បេសកកម្ម និងគោលបំណងរបស់សាលារៀននៅក្នុងការពិនិត្យ

ឡើងវិញនូវស្ថានភាពបច្ចុប្បន្នរបស់សាលារៀន និងចូលរួមចំណែកយ៉ាងសំខាន់សម្រាប់ការអភិវឌ្ឍព្រម ទាំងចូលរួមក្នុងការពិភាក្សា និងធ្វើការសម្រេចចិត្ត ៥)មាតាបិតាសិស្ស ចែករំលែកទស្សនៈយល់ឃើញ ទាក់ទងនឹងតម្រូវការរបស់កុមារក្នុងការសិក្សា និងការលំបាកដែលពួកគេជួបប្រទះនៅក្នុងសាលារៀន បង្ហាញពីបំណងប្រាថ្នាចំពោះសាលារៀន និងកូនៗរបស់ពួកគេពីកង្វល់ផ្សេងៗ និងចូលរួមក្នុងការកំណត់គោលដៅ យុទ្ធសាស្ត្រនិងកក្តាអាទិភាពសម្រាប់សាលារៀន ៦)សហគមន៍ និងអជ្ញាធរមូលដ្ឋាន សហគមន៍ និងអជ្ញាធរមូលដ្ឋានអាចចូលរួមក្នុងដំណើរការធ្វើផែនការតាមកម្មវិធីមួយចំនួន។ ដំណើរការពិនិត្យឡើងវិញរួមបញ្ចូលទាំងការពិចារណានៃកត្តាបរិបទក្នុងស្រុក ដែលប៉ះពាល់ដល់សាលារៀនហើយអាចតម្រូវឱ្យមានការស្ទង់មតិមួយចំនួន ស្តីអំពីសហគមន៍មូលដ្ឋានដើម្បីបង្កើតទស្សនៈតម្រូវការ ឬឱកាសហើយសាលារៀនអាចទាញយកចំណេះដឹង និងធនធានរបស់សមាជិកពាក់ព័ន្ធរបស់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន ក្នុងការរៀបចំផែនការដើម្បីដោះស្រាយបញ្ហាជាក់លាក់ណាមួយ។

ម្យ៉ាងវិញទៀតបើយើងពិនិត្យទៅមើលការអនុវត្ត និងគ្រប់គ្រងផ្នែកមធ្យមសិក្សាគណៈកម្មការគ្រប់គ្រងសាលារៀន និងនាយក ឬនាយិកាសាលារៀនមានតួនាទី និងភារកិច្ចយ៉ាងសំខាន់ក្នុងរៀបចំផែនការ និងអភិវឌ្ឍសាលា (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៨) ១)តួនាទី និងភារកិច្ចរបស់គណៈកម្មការគ្រប់គ្រងសាលារៀនការ ធ្វើផែនការនិងការគ្រប់គ្រងថវិកាសាលារៀន អនុម័តសូចនាករផលសម្រេច និងក្រុមគោលដៅសម្រាប់៣ឆ្នាំ អនុម័តផែនការកែលម្អសាលារៀន ថវិកា និងផ្តល់ការព្រមព្រៀងលើការវាយតម្លៃការអនុវត្តរបស់សាលារៀនធៀបជាមួយនឹងស្តង់ដាសាលារៀនមានប្រសិទ្ធភាព ២)ការគ្រប់គ្រងមន្ត្រីរួមមាន ការអនុម័តរង្វាន់ដល់មន្ត្រីដែលបានបំពេញការងារបានល្អប្រសើរ ការស្នើវិធានការរដ្ឋបាលសម្រាប់មន្ត្រីមិនអនុវត្តភារកិច្ចដល់ថ្នាក់ក្រោមជាតិ និងការអនុម័តរង្វាន់សម្រាប់នាយក ឬនាយិកាដែលបានបំពេញការងារល្អប្រសើរ ៣)ការវាយតម្លៃសាលារៀន និងសិស្សរួមមាន អនុម័តលទ្ធផលវាយតម្លៃការអនុវត្តរបស់សាលារៀន ទទួលស្គាល់របាយការណ៍រីកចម្រើនប្រចាំត្រីមាសពីការអនុវត្តផែនការកែលម្អសាលារៀន និងទទួលស្គាល់របាយការណ៍ចម្រើនប្រចាំឆ្នាំពីការសម្រេចសូចនាករនិងក្រុមគោលដៅផលសម្រេច ៤)តួនាទីសហគមន៍ និងអភិបាលកិច្ចសាលារៀនរួមមាន ការគាំទ្រក្នុងការដោះស្រាយបញ្ហា

ដែលលើកឡើងដោយមាតាបិតា និងសិស្សពីការពិនិត្យតាមដានសាលារៀន និងថ្នាក់រៀន និងធានាតម្លាភាពក្នុងការចូលរួមរបស់សហគមន៍។

## ២.៨. លំនាំនៃការរៀបចំផែនការអប់រំ

ផែនការមិនសំដៅតែទៅលើលទ្ធផលតែមួយមុខប៉ុណ្ណោះទេ។ លំនាំនៃការធ្វើផែនការ ក៏ជាកត្តាសំខាន់ណាស់ដែរដើម្បីសម្រេចបាននូវលទ្ធផលជាវិជ្ជមាន និងអាចវ៉ាប់រងបាន លំនាំនេះចាំបាច់ត្រូវអនុវត្តដោយមានការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធ។ ដូចនេះលំនាំនៃការធ្វើផែនការ ត្រូវគោរពតាមជំហានធំៗរួមមាន១)ការស្វែងយល់បញ្ហាផែនការចាប់ផ្តើមដោយការវិភាគស្ថានភាព។ ការវិភាគនេះនាំឆ្ពោះទៅរកការកំណត់ឱ្យឃើញនូវបញ្ហាឬតម្រូវការដែលត្រូវដោះស្រាយ។ ដើម្បីទទួលបាននូវបញ្ហា និងតម្រូវការឱ្យបានសព្វគ្រប់ វាចាំបាច់ត្រូវពិភាក្សាជាមួយមនុស្សទាំងអស់ដែលមានផលប៉ះពាល់ពីបញ្ហាទាំងនោះ និងអ្នកដែលមានចំណាប់អារម្មណ៍ចំពោះលទ្ធផលនៃផែនការនោះ។២)ការធ្វើការជ្រើសរើស ត្រូវរកឱ្យឃើញនូវជម្រើសផ្សេងៗដែលអាចដោះស្រាយបញ្ហាបាន។ ត្រូវកំណត់ឱ្យបាននូវចំណុចខ្លាំងនិងចំណុចខ្សោយឧបសគ្គនានាដែលជាប់ជំពាក់ និងជាផលវិបាកនៃជម្រើសនីមួយៗ។ តម្លៃ(ផលកម្រៃសុទ្ធ) ត្រូវបានប៉ាន់ស្មានសម្រាប់ជម្រើសនីមួយៗ ហើយប្រៀបធៀបជាមួយអត្ថប្រយោជន៍ដែលរំពឹងទុក ឬប្រសិទ្ធភាពនៃលទ្ធផល បន្ទាប់មកត្រូវជ្រើសរើស ជម្រើសដែលប្រសើរបំផុត។ ពេលនោះហើយវត្ថុបំណងច្បាស់លាស់ត្រូវបានបង្កើតឡើង គឺជាការល្អប្រសើរដែលមានមនុស្សជាច្រើនចូលរួម (ទាំងខាងក្នុង និងខាងក្រៅអង្គភាព)នៅក្នុងជំហានពីរដំបូងនៃការធ្វើផែនការនោះ។ គេនឹងចូលរួមវិភាគទានដើម្បីវិភាគនូវបញ្ហា និងផ្តល់យោបល់អំពីជម្រើសផ្សេងៗដើម្បីដោះស្រាយបញ្ហានោះ។ គេនឹងជួយកំណត់នូវវត្ថុបំណងនៃផែនការឱ្យកាន់តែច្បាស់លាស់ថែមទៀត។ ប្រសិនបើគេចូលរួមនៅក្នុងលំនាំនៃការធ្វើផែនការនេះ គេពេញចិត្តនឹងជួយគាំទ្រក្នុងការអនុវត្តផែនការនេះ។៣)ការត្រួតពិនិត្យ និងវង្វាយតម្លៃលើផែនការជំហានទាំងឡាយក្នុងការអនុវត្តផែនការ ត្រូវបានកំណត់ ហើយធនធានដែលចាំបាច់ត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់។ ការប៉ាន់ស្មានថវិកាត្រូវបានរៀបចំឡើង។ ទំនួលខុសត្រូវ គម្រោងពេលវេលា ការគ្រប់គ្រងនិងការពិនិត្យតាមដាន (ការទូទាត់បញ្ជី) ត្រូវបានកំណត់។ ហើយលក្ខណៈវិនិច្ឆ័យអំពីភាពជោគជ័យសម្រាប់វង្វាយតម្លៃនូវជំហាន

នានា និងផលសម្រេច ក៏ត្រូវបានកំណត់ដែរ។ ដូចនេះលំនាំនៃផែនការ មានជំហានដូចតទៅ ១)ការស្វែងយល់បញ្ហា(កំណត់ឱ្យឃើញនូវបញ្ហានិងតម្រូវការទាំងឡាយ) ២)ការធ្វើការជ្រើសរើស(ការបង្កើតជម្រើសផ្សេងៗដើម្បីគិតគូរដោះស្រាយបញ្ហានានានិងតម្រូវការទាំងឡាយ ការព្យាករណ៍ទុកមុនគ្រប់ការណ៍ជាប់ទាក់ទិននិងផលវិបាកនៃជម្រើសនីមួយៗ ការគណនាផលកម្រៃពិតនៃជម្រើសនីមួយៗហើយប្រៀបធៀបការជ្រើសជម្រើសដែលប្រសើរបំផុត ហើយរៀបចំវត្ថុបំណងនៃផែនការ)។ រីឯការរៀបចំផែនការ ការអនុវត្តការពនិត្យតាមដាន និងការវាយតម្លៃត្រូវបានកំណត់រួមមាន១)កំណត់ជំហាននៃការអនុវត្ត (តាមសកម្មភាពជាលំដាប់លំដោយ)២)បញ្ជាក់ច្បាស់លាស់មធ្យោបាយ និងទម្រង់បែបបទឡាំងឡាយ ៣)បញ្ជាក់ច្បាស់លាស់នូវគម្រោងពេលវេលា ៤)រៀបចំការប៉ាន់ស្មានតម្លៃ ៥)បញ្ជាក់យ៉ាងច្បាស់លាស់នូវជាតុផ្សំសម្រាប់វាយតម្លៃនិងលក្ខណៈវិនិច្ឆ័យ (ក្រសួងអប់រំ យុវជន និងកីឡា, ២០០៩)។

ក្នុងរយៈពេលនៃការអនុវត្ត គេអាចកែសម្រួលផែនការនិងសកម្មភាពនានាឱ្យបានសមស្រប។ មធ្យោបាយ ទម្រង់បែបបទ កាលបរិច្ឆេទ និងការលៃលកទុកថវិកាទាំងអស់នោះ គប្បីបញ្ជាក់ដោយល្អិតល្អន់ម្តងទៀតនូវដំណាក់កាលនីមួយៗនៃលំនាំក្នុងការអនុវត្តផែនការនោះ។

ការពិនិត្យតាមដានចំពោះការអនុវត្តផែនការ ទាក់ទងគ្រប់សកម្មភាព និងការចំណាយទាំងអស់។ នៅចុងបញ្ចប់នៃការអនុវត្ត ឬពាក់កណ្តាលអាណត្តិសំខាន់ៗខ្លះ ប្រសិទ្ធភាពនៃដំណើរការ និងលទ្ធផលគប្បីត្រូវបានវាយតម្លៃដោយធ្វើការពិចារណាទៅលើលទ្ធផលនៃការវាយតម្លៃ បន្ទាប់មកគេត្រូវធ្វើការកែលម្អផែនការឡើងវិញ។ (វិទ្យាស្ថានជាតិអប់រំ, ២០១៧)។

## ២.៩.ដំណើរការនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

ដើម្បីរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំ គឺនៅពេលចាប់ផ្តើមរៀបចំត្រូវមានសហាសភាពចូលរួមពីគណៈគ្រប់គ្រងសាលារៀន ថ្នាក់ដឹកនាំសាលា គ្រូបង្រៀន សិស្សានុសិស្ស សហគមន៍ ដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធត្រូវមកជួបជុំគ្នា ពិភាក្សាគ្នា ពិបញ្ហាដែលកើតឡើងក្នុងសាលារៀនដោយផ្អែកលើផទ្ធផលស្វ័យវាយតម្លៃសាលារៀន ហើយត្រូវអនុវត្ត៧ជំហាន (វិទ្យាស្ថានជាតិអប់រំ,

២០១៧) ១)វិភាគស្ថានភាព(ការធ្វើហេតុវិនិច្ឆ័យសាលារៀនតាមរយៈការវិភាគដើមឈើបញ្ហា និងការវិភាគលើ SWORT រួមមាន (ភាពងាយទទួលរងគ្រោះ គឺវិភាគទៅលើហានិភ័យ ដូចជាគ្រោះមហន្តរាយធម្មជាតិ ទឹកជំនន់ ខ្យល់ព្យុះ បាក់ដី...) ការវិភាគតម្លៃចំណាយ និងហិរញ្ញវត្ថុ គឺវិភាគទៅលើការចំណាយជាប្រចាំ និងការស្វែងរកប្រភពចំណូល) (វិភាគការចូលរៀន គឺវិភាគទៅលើអត្រាពិតនៃការចូលរៀនថ្មី អត្រាពិតនៃការសិក្សា អត្រារួមនៃការចូលរៀនថ្មី អត្រារួមនៃការសិក្សា) វិភាគប្រសិទ្ធភាពផ្ទៃក្នុងគឺ វិភាគទៅលើអត្រាឡើងថ្នាក់ អត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សា) វិភាគសមធម៌ វិភាគទៅលើ យេនឌ័រក្នុងឱកាសទទួលបានការចូលរៀន) វិភាគការដឹកនាំ និងគ្រប់គ្រងគឺវិភាគទៅលើសមត្ថភាព និងភាពជាអ្នកដឹកនាំ ២)ជម្រើសគោលនយោបាយ (សាលារៀនត្រូវអនុវត្តទៅតាមគោលនយោបាយទាំងពីររបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានស្រាប់ដូចជា ធានាឱ្យការអប់រំមានគុណភាព ប្រកបដោយសមធម៌ និងបរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា និងធានាភាពស័ក្តិសិទ្ធិនៃភាពជាអ្នកដឹកនាំ និងគ្រប់គ្រងរបស់មន្ត្រីអប់រំ គ្រប់លំដាប់ថ្នាក់។ ៣)ជម្រើសយុទ្ធសាស្ត្រ (កំណត់យុទ្ធសាស្ត្រសំខាន់ៗ សម្រាប់សម្រេចបាននូវសូចនាករ និងគោលដៅ) ៤)ការកំណត់កម្មវិធី និងសកម្មភាពកម្មវិធីជាបណ្តុំនៃសកម្មភាព និងការជ្រើសរើសកម្មវិធីអាទិភាពនីមួយៗ គួរមានចំណុចដៅ និងលទ្ធផលជាក់លាក់ ហើយប្រសិនបើអាចធ្វើទៅបាន ត្រូវតែធ្វើឱ្យទៅជាសកម្មភាពគន្លឹះជាមួយនិងចំណុចដៅសកម្មភាព ៥) ការធ្វើចំណោល គឺត្រូវសរសេរអំពីតម្រូវការហិរញ្ញប្បទានតាមឆ្នាំនីមួយៗដែលបានកំណត់ក្នុងរយៈពេល ៥ ឆ្នាំ។ តម្រូវការហិរញ្ញប្បទាន ត្រូវកំណត់ពីប្រភពនៃហិរញ្ញប្បទានដូចជា ប្រភពថវិការដ្ឋ និងប្រភពថវិកាពីដៃគូអភិវឌ្ឍ សហគមន៍ និងសប្បុរសជន ឬប្រភពថវិកាផ្សេងៗទៀត ដែលទទួលបាន ដើម្បីគាំទ្រដល់ការងារបង្រៀន និងរៀន ឬក្នុងដំណើរការសាលារៀនទាំងមូល ៦)ការគណនាចំណាយសាលារៀនសាធារណៈត្រូវអនុវត្តសិទ្ធិចំណាយរបស់ខ្លួនក្នុងការអនុត្ត មូលនិធិដំណើរការសាលារៀនសាធារណៈក្នុងក្របខ័ណ្ឌនៃសកម្មភាពដែលបានកំណត់ទាំង ២គោលការណ៍ចំណាយ (គាំទ្រកិច្ចដំណើរការកិច្ចដំណើរការរដ្ឋបាល ការថែទាំ និងជួសជុលផ្សេងៗ និងកែលម្អគុណភាពអប់រំការចូលរៀនដោយសមធម៌ និងបង្ការសិស្សបោះបង់ សម្ភារៈរៀន និងបង្រៀន ការកែលម្អបរិស្ថាន និងទីធ្លាកម្សាន្ត) ៧)ការគ្រប់គ្រង និងការ

ពិនិត្យតាមដាន (ការពិនិត្យតាមដានជាការប្រមូលទិន្នន័យជាប្រព័ន្ធ និងបន្តបន្ទាប់គ្នា ទៅលើសូចនាករជាក់លាក់នានា ដើម្បីបង្ហាញអ្នកអនុវត្តអំពីដំណើរការវិវឌ្ឍ និងការសម្រេចបានវត្ថុបំណងដែលបានកំណត់ និងការវាយតម្លៃជាការវាយតម្លៃវត្ថុបំណងជាប្រព័ន្ធនៃដំណើរការ ឬគោលនយោបាយ ឬផែនការដែលបានអនុវត្ត រួមបញ្ចូលទាំងដំណើរការរៀបចំ ការអនុវត្ត និងលទ្ធផលសម្រេចបាន។ វាក៏ជាការវាយតម្លៃផងដែរលើទំនាក់ទំនងរវាងការសម្រេចបាននៃវត្ថុបំណង និងយុទ្ធសាស្ត្រជាមួយនឹងគោលបំណងនៃការធ្វើសេចក្ដីសម្រេចចិត្ត)។

## ២.១០. បញ្ហាប្រឈមនៃការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន

ក្រសួងអប់រំយុវជន និងកីឡាបានរៀបចំផែនការយុទ្ធសាស្ត្រ និងការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យអប់រំ ២០១៩-២០២៣ ដោយសង្កេតឃើញថាទទួលបានវឌ្ឍនភាពកើនឡើងគួរឱ្យកត់សម្គាល់ ក្នុងការឆ្ពោះទៅសម្រេចបាននូវវត្ថុបំណងគោលនយោបាយ ដែលបានកំណត់នៅក្នុងផែនការយុទ្ធសាស្ត្រវិស័យអប់រំ២០១៩-២០២៣ ក៏នៅមានចំណុចមួយចំនួនត្រូវបន្តពង្រឹងនិងកែលម្អថែមទៀត ដើម្បីសម្រេចគោលដៅនានាខាងមុខ ហើយអ្វីដែលជាបញ្ហាសម្រាប់វិស័យអប់រំបច្ចុប្បន្ន ការចូលរៀនរបស់កុមារតូចនៅតាមតំបន់ជនបទ កុមារងាយរងគ្រោះ និងកុមារដែលមានកម្រិតស្ថានភាពសេដ្ឋកិច្ច-សង្គមទាបមិនទាន់បានឆ្លើយតប និងការផ្ដល់សេវាអប់រំកុមារតូចមិនទាន់ស្របតាមស្តង់ដាអប្បបរមា ដូចជា គុណវុឌ្ឍិគ្រូអប់រំកុមារតូចនៅមានកម្រិត និងកង្វះគ្រូអប់រំកុមារតូច ការរក្សាសិស្សមិនទាន់ឱ្យបាននៅគង់វង្ស និងបញ្ចប់ការសិក្សា ជាពិសេសក្រុមកុមារជួបការលំបាក ក្រុមកុមារបាត់បង់ឱកាសនៅថ្នាក់បឋមសិក្សា។ ចំនួនសមាមាត្រកុមារដែលទទួលបានបំណិនជាមូលដ្ឋានក្នុងការអាន ការសរសេរ និងការគិតនៅមានគម្លាតនៅឡើយ។ ការបោះបង់ការសិក្សានៅមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិនៅមានកម្រិតខ្ពស់នៅឡើយ។ កង្វះសម្ភារបរិក្ខារតាមសាលារៀនជាកត្តាធ្វើឱ្យមានអត្រារួមនៃការសិក្សាចុះទាប ក៏ដូចជាកង្វះគ្រូបង្រៀន ជាពិសេស កង្វះគ្រូបង្រៀនឯកទេសតាមមុខវិជ្ជា ដូចជាមុខវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា បច្ចេកវិទ្យា ព័ត៌មាននិងសារគមនាគមន៍ និងមុខវិជ្ជាភាសាបរទេស គម្លាតរវាងជំនាញដែលផ្ដល់ឱ្យសិស្សនៅតាមសាលាចំណេះទូទៅនិងអប់រំបច្ចេកទេស មិនឆ្លើយតប នឹងតម្រូវការទីផ្សារការងារ។ វិសម

ភាពក្នុងការសិក្សារបស់និស្សិតមកពីគ្រួសារដែលមានចំណូលទាប។ ការសិក្សាលើផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម សិល្បៈច្នៃប្រឌិត និងគណិតវិទ្យានៅមានកម្រិតទាបនៅឡើយ។ កង្វះមធ្យោបាយដើម្បីលើកទឹកចិត្តក្នុងសកម្មភាព ការងារស្រាវជ្រាវ តាមគ្រឹះស្ថានឧត្តមសិក្សា។បុគ្គលិកខ្វះជំនាញ និងធនធានសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍នៅមានកម្រិតកម្មវិធីបណ្តុះបណ្តាលជំនាញទន់ ការអប់រំបណ្តុះបណ្តាលសហគ្រិនភាព ការបណ្តុះបណ្តាលជំនាញបច្ចេកទេសមិនទាន់មានសម្ភារបរិក្ខារគ្រប់គ្រាន់សម្រាប់គាំទ្រ។ ធនធានមនុស្ស និងមជ្ឈមណ្ឌលគ្រប់គ្រងយុវជនគ្របដណ្តប់ទូទាំងប្រទេសនៅមានកម្រិត។ ក្រុមប្រឹក្សាកុមារ និងក្រុមប្រឹក្សាយុវជនមិនទាន់ដំណើរការសមស្រប និងខ្វះការគាំទ្រពីអ្នកពាក់ព័ន្ធ។ ការអនុវត្តផែនការយុទ្ធសាស្ត្រពង្រីកសមាជិកកាយរិទ្ធមិនទាន់គ្រប់តាមផែនការ។ ហេដ្ឋារចនាសម្ព័ន្ធកីឡានៅមានកម្រិត។ សមត្ថភាពមន្ត្រីអប់រំកាយនិងកីឡាកីឡាករ គ្រូបង្វឹក និងអាជ្ញាកណ្តាលនៅមានកម្រិត។ កង្វះធនធានសម្រាប់អនុវត្តផែនការគោលឆ្ពោះទៅជាម្ចាស់ផ្ទះនៃការប្រកួតកីឡាអាស៊ីអាគ្នេយ៍ លើកទី៣២ ឆ្នាំ ២០២៣។កត្តាទាំងអស់ខាងលើនេះហើយដែលធ្វើឱ្យសាលារៀនថ្នាក់មូលដ្ឋានត្រូវជួបប្រទះបញ្ហាប្រឈមក្នុងការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន២០១៩-២០២៣ ឱ្យមានវឌ្ឍនភាពក្នុងការអនុវត្តសកម្មភាព សម្រេចបាននូវសូចនាករ និងចក្ខុវិស័យរបស់សាលារៀនផងដែរ (ក្រសួងអប់រំ យុវជន និងកីឡា, ២០១៩-២០២៣)។

# ជំពូកទី៣

# វិធីសាស្ត្រសិក្សាស្រាវជ្រាវ

## ៣.១. ដំណើរការនៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងសំណួរស្រាវជ្រាវខាងលើ និងសម្រេចទៅតាមវត្ថុបំណងនៃការស្រាវជ្រាវ ការសិក្សានេះនឹងប្រើប្រាស់វិធីសាស្ត្រតាមបែបបរិមាណវិស័យ ដោយប្រើកម្រងសំណួរសម្រាប់បំពេញតាមលំដាប់លំដោយ។ ការប្រើប្រាស់វិធីស្រាវជ្រាវតាមបែបបរិមាណវិស័យនេះ គឺដើម្បីរកឱ្យឃើញនូវលទ្ធផលជាចំនួនជាក់លាក់ ទិន្នន័យច្បាស់លាស់ និងគិតជាភាគរយតាមចំនួនអ្នកពាក់ព័ន្ធនឹងស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំរបស់វិទ្យាល័យទាំង១០ តំបន់ទីក្រុងចំនួន០២ និងតំបន់ជនបទចំនួន០៨នៃខេត្តកំពង់ចាម។ វិធីសាស្ត្រនេះ នឹងបង្ហាញលទ្ធផលនៃការរៀបចំផែនការ និងកម្រិតយល់ដឹងរបស់ក្រុមគោលដៅដែលពាក់ព័ន្ធនឹងផែនការ ការលើកទឹកចិត្ត និងការអភិវឌ្ឍសមត្ថភាព។ ម្យ៉ាងវិញទៀត ការស្រាវជ្រាវតាមបែបបរិមាណវិស័យ ធ្វើឱ្យអ្នកស្រាវជ្រាវយល់ដឹងច្បាស់ពីការវិភាគទិន្នន័យ សូចនាករ តម្រូវការហិរញ្ញប្បទាន អ្នកទទួលខុសត្រូវ និងលទ្ធផលដែលទទួលបាន។

## ៣.២. ការជ្រើសរើសភាគសំណាក

ការសិក្សាស្រាវជ្រាវនេះ នឹងធ្វើឡើងនៅវិទ្យាល័យចំនួន១០ក្នុងខេត្តកំពង់ចាម តំបន់ទីក្រុងចំនួន០២ និងតំបន់ជនបទចំនួន០៨ ដោយជ្រើសរើសភាគសំណាកចំនួន១០០នាក់ សម្រាប់ការសិក្សាស្រាវជ្រាវរួមមានសមាសភាពគណៈគ្រប់គ្រងសាលា(នាយក/នាយិកា នាយករង/នាយិការង) ចំនួន៣០នាក់ លេខាធិការចំនួន១០នាក់ គណនេយ្យចំនួន១០ នាក់ ប្រធានក្រុមបច្ចេកទេសចំនួន ២០នាក់ អនុប្រធានក្រុមបច្ចេកទេសចំនួន ១០នាក់ លោកគ្រូ អ្នកគ្រូចំនួន ២០នាក់ ។

**តារាង៣.១៖ ចំនួនសំណាកដែលត្រូវបំពេញកម្រងសំណួរ**

| ល.រ | ប្រភេទអ្នកចូលរួមបំពេញកម្រងសំណួរ | ចំនួន | ចំនួនវិ.ល័យ | សរុប |
|---|---|---|---|---|
| ១ | គណៈគ្រប់គ្រងសាលា( នាយក/នាយិកា ) | ១ | ១០ | ១០ |
| ២ | គណៈគ្រប់គ្រងសាលា( នាយករង/នាយិការង ) | ២ | ១០ | ២០ |
| ៣ | លេខាធិការ | ១ | ១០ | ១០ |
| ៤ | គណនេយ្យ | ១ | ១០ | ១០ |
| ៥ | ប្រធានក្រុមបច្ចេកទេស | ២ | ១០ | ២០ |
| ៦ | អនុប្រធានក្រុមបច្ចេកទេស | ១ | ១០ | ១០ |
| ៧ | លោកគ្រូ អ្នកគ្រូ | ២ | ១០ | ២០ |
|  | **សរុបរួម** | **១០** | **១០** | **១០០** |

## ៣.៣. ឧបករណ៍ស្រាវជ្រាវ

ចំពោះឧបករណ៍ស្រាវជ្រាវដែលបានបង្កើត និងយកមកប្រើក្នុងការប្រមូលទិន្នន័យមានកម្រងសំណួរដែលមានលក្ខណៈកម្រិតចម្លើយ (ទម្រង់បិទ និងបើក) បួនប្រភេទសម្រាប់អ្នកពាក់ព័ន្ធទាំងអស់ចំណាយពេលប្រហែល២០នាទីក្នុងការបំពេញ និងកម្រងសំណួរនេះត្រូវបានរៀបចំឡើងតែមួយប្រភេទប៉ុណ្ណោះសម្រាប់គណៈគ្រប់គ្រងសាលា( នាយក/នាយិកា នាយករង/នាយិការង ) លេខាធិកា គណនេយ្យ ប្រធានក្រុមបច្ចេកទេស អនុប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូ ដោយប្រើកម្រងសំណួរចំនួន៣ផ្នែកស្មើនឹង២៩សំណួរ និងចែកជូន១វិទ្យាល័យ១០ច្បាប់។ វិធីសាស្ត្រក្នុងការជ្រើសរើសនៅក្នុងការសិក្សានេះគឺជាការស្ទង់មតិ និងសិក្សាពីស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនកម្រិតមធ្យមសិក្សានៃវិទ្យាល័យទាំង១០ តំបន់ទីក្រុងចំនួន០២ និងតំបន់ទីជនបទចំនួន០៨ នៃខេត្តកំពង់ចាម។

ក្នុងការបង្កើតកម្រងសំណួរទាំងនេះគឺ បានពីឯកសារអប់រំមួយចំនួនដែលទាក់ទងទៅនឹងការងារផែនការរបស់ក្រសួងអប់រំ យុវជន និងកីឡា រួមមាន៖ (១) ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៩-២០២៣ (២) ផែនការអភិវឌ្ឍន៍សាលារៀនរបស់នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ សម្រាប់បំប៉ន

នាយកសាលារៀនបឋមសិក្សា និងមធ្យមសិក្សាឆ្នាំ២០០៩ (៣) មូលដ្ឋានគ្រឹះនៃការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០១៧ (៤) ទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំ ២០១៩-២០២៣ (៥) ស្វ័យវាយតម្លៃសាលារៀនរបស់ក្រសួងអប់រំ យុវជន និងកីឡា និង(៦) សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងសាលារៀនគម្រោងកែលម្អការអប់រំនៅមធ្យមសិក្សាឆ្នាំ២០១៨។

## ក.កម្រងសំណួរ និងគោលបំណង

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

ក្នុងផ្នែកនេះមាន ៣សំណួរ អ្នកស្រាវជ្រាវមានគោលបំណងចង់ដឹងអំពី ភេទ តួនាទី និងទីតាំងវិទ្យាល័យរបស់អ្នកបំពេញ។

**ផ្នែកទី២៖ការយល់ដឹងពីរទម្រង់ ខ្លឹមសារនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន**

ក្នុងផ្នែកនេះមាន ១៣សំណួរ អ្នកស្រាវជ្រាវមានគោលបំណងចង់ដឹងអំពីទម្រង់នៃផែនការ ប្រភេទផែនការ និងកម្រិតយល់ដឹងពីខ្លឹមសារនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន។

**ផ្នែកទី៣៖ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន**

ក្នុងផ្នែកនេះមាន១៣សំណួរ អ្នកស្រាវជ្រាវមានគោលបំណងចង់ដឹងអំពីស្ថានភាពនៃការរៀបចំបញ្ហាប្រឈមចម្បងៗដែលសាលាជួបប្រទះ។

## ខ.កម្រងសំណួរសម្រាប់បំពេញ

**ក្រុមគោលដៅ៖** គណៈគ្រប់គ្រងសាលា( នាយក/នាយិកា នាយករង/នាយិការង ) លេខាធិការ គណនេយ្យ ប្រធានក្រុមបច្ចេកទេស អនុប្រធានក្រុមបច្ចេកទេស លោកគ្រូ អ្នកគ្រូ សរុបចំនួន១០នាក់ក្នុង១វិទ្យាល័យសម្រាប់១០វិទ្យាល័យក្នុងខេត្តកំពង់ចាម។

១.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា( នាយក/នាយិកា ) បំពេញមានចំនួន១០ច្បាប់

២.កម្រងសំណួរសម្រាប់គណៈគ្រប់គ្រងសាលា( នាយករង/នាយិការង )បំពេញមានចំនួន២០ច្បាប់

៣.កម្រងសំណួរសម្រាប់លេខាធិការ បំពេញ មានចំនួន១០ច្បាប់

៤.កម្រងសំណួរសម្រាប់គណនេយ្យ បំពេញមានចំនួន១០ច្បាប់

៥.កម្រងសំណួរសម្រាប់ប្រធានក្រុមបច្ចេកទេស បំពេញ មានចំនួន២០ច្បាប់

៦.កម្រងសំណួរសម្រាប់អនុប្រធានក្រុមបច្ចេកទេស បំពេញ មានចំនួន១០ច្បាប់

៧.កម្រងសំណួរសម្រាប់លោកគ្រូ អ្នកគ្រូ បំពេញ មានចំនួន២០ច្បាប់។

## ៣.៤- វិធីប្រមូលទិន្នន័យ

និតិវិធីនៃការប្រមូលទិន្នន័យជាក់ស្តែងនៅតាមសាលាគោលដៅទាំង១០ គឺត្រូវបានចុះទៅប្រមូលទិន្នន័យបឋម និងយកមកវិភាគក្នុងការសិក្សាស្រាវជ្រាវនេះ ហើយក្នុងការស្រាវជ្រាវនេះគឺយើងប្រើប្រាស់រយៈពេល២សប្តាហ៍ ដែលចាប់ពីថ្ងៃទី១៧ ខែកក្កដា ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ នឹងស្ថិតក្នុងសាលាគោលដៅទាំង១០ រួមមាន វិទ្យាល័យក្នុងតំបន់ទីក្រុងចំនួន០២ និងវិទ្យាល័យតំបន់ជនបទចំនួន០៨នៃខេត្តកំពង់ចាម។ មុននឹងធ្វើការផ្តល់កម្រងសំណួរទាំងនេះដល់អ្នកចូលរួមក្នុងការបំពេញកម្រងសំណួរ និងផ្តល់ព័ត៌មាន ជាដំបូងត្រូវធ្វើលិខិតស្នើសុំប្រមូលទិន្នន័យតាមរយៈវិទ្យាស្ថានជាតិអប់រំ បន្ទាប់មកយកទៅមន្ទីរ អប់រំ យុវជន និងកីឡាខេត្តដើម្បីសុំលិខិតអនុញ្ញាតចុះប្រមូលទិន្នន័យស្រាវជ្រាវនៅតាមសាលាគោលដៅ និងដាក់ជូនសាលាខេត្តកំពង់ចាមដើម្បីជ្រាបជាព័ត៌មាន។ បន្ទាប់ពីបានលិខិតអនុញ្ញាតពីលោកប្រធានមន្ទីរអប់រំ យុវជន និងកីឡារួចរាល់ហើយអ្នកស្រាវជ្រាវបានយកលិខិតជូនលោកប្រធានការិយាល័យអប់រំ យុវជន និងកីឡាក្រុងកំពង់ចាម ដើម្បីទទួលស្គាល់ ក្រោយមកអ្នកស្រាវជ្រាវបានចុះទៅសាលាគោលដៅជួបជាមួយនាយក/នាយិកាសាលា ដើម្បីជម្រាបពួកគាត់ពីគោលបំណងនៃការចុះស្រាវជ្រាវក្រមសីលធម៌ និងប្រយោជន៍នៃការស្រាវជ្រាវដើម្បីទទួលបានការចូលរួម និងរកឃើញនូវចំណុចខ្វះខាតព្រមទាំងសុំការអនុញ្ញាតដើម្បីនាយក/នាយិកា នាយករង/នាយិការង លេខាធិការ គណនេយ្យ ប្រធានក្រុមបច្ចេកទេស អនុប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូ ដើម្បីបំពេញកម្រងសំណួរក្នុង១នាក់ ១ច្បាប់ និងមានរយៈពេល២០នាទីដោយមិនពិភាក្សាគ្នាក្នុងការបំពេញកម្រងសំណួរ និងចុងក្រោយបានប្រមូលកម្រងសំណួរទាំងអស់ដើម្បីទុកបូកសរុប និងធ្វើការវិភាគ។

## ៣.៥- វិធីសាស្ត្រវិភាគទិន្នន័យ

ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការស្រាវជ្រាវ និងស្ថានភាពជាក់ស្តែងរបស់សាលារៀន អ្នកស្រាវជ្រាវ នឹងវិភាគអំពីស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនតាមរយៈការបំពេញកម្រងសំណួរ និងវិភាគដោយប្រើប្រាស់កម្មវិធី SPSS ដើម្បីរកប្រេកង់នៃជម្រើសរបស់ចម្លើយអ្នកឆ្លើយកម្រងសំណួរ និងកម្មវិធី Microsoft Excel ដើម្បីបង្កើតក្រាភិច។ ដូច្នេះហើយរាល់ទិន្នន័យទាំងអស់មុននឹងបញ្ចូលទៅក្នុងកម្មវីធីវិភាគ ត្រូវពិនិត្យឡើងវិញតើមានលក្ខណៈសមស្រប ត្រឹមត្រូវ ច្បាស់លាស់ ពិតប្រាកដមុននឹងបញ្ចូលក្នុងកម្មវិធីSPSS។

រាល់ទិន្នន័យទាំងអស់ដែលបានធ្វើការវិភាគរួច នឹងត្រូវទាញយកមកប្រើប្រាស់ក្នុងការឆ្លើយតបទៅនឹងគោលបំណងសំខាន់ៗនៃការស្រាវជ្រាវ ដើម្បីងាយស្រួលក្នុងការបង្ហាញ និងធ្វើសេចក្តីសន្និដ្ឋានពីលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ ហើយធ្វើការវាយតម្លៃទៅលើស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងលើកជាសំណូមពរមួយចំនួនដល់សាលារៀន ព្រមទាំងភាគីពាក់ព័ន្ធនានាក្នុងដំណើរការរៀបចំផែនការនេះដើម្បីទទួលបាននូវគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនឱ្យមានប្រសិទ្ធភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលារៀន និងការកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ។

# ជំពូកទី៤

# លទ្ធផលស្រាវជ្រាវ និងការពិភាក្សា

## ៤.១.លទ្ធផលស្រាវជ្រាវ

ក្នុងជំពូកទី៤នេះ បង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយ និងពិភាក្សានូវអ្វីដែលត្រូវបានរកឃើញតាមរយៈការបំពេញកម្រងសំណួររបស់ក្រុមគោលដៅដែលពាក់ព័ន្ធរួមមាន៖ គណៈគ្រប់គ្រងសាលារៀន លេខាធិការ គណនេយ្យ ប្រធានក្រុមបច្ចេកទេស អនុប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូ ដោយផ្តោតលើកត្តាធំៗចំនួនបីផ្នែកគឺ៖

**ផ្នែកទី១៖** ព័ត៌មានទូទៅ

**ផ្នែកទី២៖** ការយល់ដឹងពីទម្រង់ខ្លឹមសារនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

**ផ្នែកទី៣៖** ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

## ផ្នែកទី១៖ ព័ត៌មានទូទៅ

**តារាង៤.១.ផ្នែកព័ត៌មានទូទៅ**

| ភេទ | ចំនួន | ភាគរយ | ទីតាំងសាលារៀន | ចំនួន | តួនាទីអ្នកឆ្លើយ | ចំនួន |
|---|---|---|---|---|---|---|
| ប្រុស | ៧៧ | ៧៧% | តំបន់ទីក្រុង | ០២ | ១.នាយក/នាយិកា | ១០នាក់ |
| | | | | | ២.នាយករង/នាយិការង | ២០នាក់ |
| | | | | | ៣.លេខាធិការ | ១០នាក់ |
| ស្រី | ២៣ | ២៣% | តំបន់ជនបទ | ០៨ | ៤.គណនេយ្យ | ១០នាក់ |
| | | | | | ៥.ប្រធានក្រុមបច្ចេកទេស | ២០នាក់ |
| សរុប | ១០០ | ១០០% | សរុបចំនួនសាលា | ១០ | ៦.អនុប្រធានក្រុមបច្ចេកទេស | ១០នាក់ |
| | | | | | ៧.លោកគ្រូ-អ្នកគ្រូ | ២០នាក់ |
| សរុបសមាសភាពបំពេញកម្រងសំណួរ | | | | | | ១០០នាក់ |

យោងតាមផ្នែកទី១ ខាងលើឃើញថាអ្នកចូលរួមបំពេញកម្រងសំណួរប្រធានបទស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំ នៅខេត្តកំពង់ចាមសរុបចំនួន១០០នាក់ ដែលជាបុរសចំនួន៧៧នាក់ត្រូវជា៧៧% និងជាស្ត្រីចំនួន២៣នាក់ត្រូវជា២៣% ហើយបានបែងចែកជា ០២តំបន់គឺ តំបន់ទីក្រុងចំនួន០២វិទ្យាល័យ មានចំនួន២០នាក់ត្រូវជា២០% និងតំបន់ទីជនបទចំនួន០៨ វិទ្យាល័យ មានចំនួន៨០នាក់ត្រូវជា៨០% ម្យ៉ាងវិញទៀតស្ថិតិដែលបានបំពេញកម្រងសំណួរចំនួន១០០ នាក់ដោយមានសមាសភាពបំពេញកម្រងសំណួររួមមាន៖ នាយក/នាយិកាចំនួន១០នាក់ត្រូវជា១០% នាយករង/នាយិការងចំនួន២០នាក់ត្រូវជា២០% លេខាធិការចំនួន១០នាក់ត្រូវជា១០% គណនេយ្យ ចំនួន១០នាក់ត្រូវជា១០% ប្រធានក្រុមបច្ចេកទេសចំនួន២០នាក់ត្រូវជា២០% អនុប្រធានក្រុមបច្ចេកទេសចំនួន១០នាក់ត្រូវជា១០% លោកគ្រូ អ្នកគ្រូចំនួន២០នាក់ត្រូវជា២០% ។

## ផ្នែកទី២៖ ការយល់ដឹងពីទម្រង់ខ្លឹមសារនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

ក្រាប ៤.១៖ ខ្លឹមសារសំខាន់ៗនៃទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន



**បំណកស្រាយទិន្ន័យ៖** តាមក្រាបខាងលើអ្នកចូលរួមទាំងអស់បានបង្ហាញពីកម្រិតយល់ដឹងពីខ្លឹមសារសំខាន់នៃទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនតាមវិទ្យាល័យ បានបង្ហាញឱ្យឃើញថាក្នុងចំណោមអ្នកបានបំពេញកម្រងសំណួរចំនួន១០០នាក់ត្រូវជា៩២២ការជ្រើសរើសចម្លើយ បានគិតថាខ្លឹមសារសំខាន់ៗនៃទម្រង់ផែនការមាន សេចក្តីផ្តើម ស្មើនឹង៧.១៧% ប្រវត្តិសាលារៀន ស្មើនឹង៩.២៤% ចក្ខុវិស័យ ស្មើនឹង១០.៤៣% បេសកកម្ម ស្មើនឹង៨.៣៧% ការវិភាគស្ថានភាពអប់រំ និងបញ្ហាប្រឈមចម្បងៗ ស្មើនឹង៩.៨៩% គោលបំណង ស្មើនឹង៨.២៦% សូចនាករ និងចំណុចដៅ ស្មើនឹង៨.១៥% យុទ្ធសាស្ត្រ និងសកម្មភាព ស្មើនឹង៩.៤៦% តម្រូវការហិរញ្ញប្បទាន ស្មើនឹង៧.២៨% យន្តការពិនិត្យតាមដាន និងវាយតម្លៃ ស្មើនឹង៨.៧% ឧបសម្ព័ន្ធ ស្មើនឹង៥.៤៣% និងអ្នកដែលបានឆ្លើយថាខ្លឹមសារសំខាន់របស់ទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនគ្រប់ចំណុចទាំងអស់ខាងលើ ស្មើនឹង៧.៦១% ។

**ក្រាប ៤.២៖ ខ្លឹមសារសំខាន់ៗនៃទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន(សំណាក)**



**បំណកស្រាយទិន្នន័យ៖** តាមក្រាបខាងលើអ្នកចូលរួមទាំងអស់បានបង្ហាញពីកម្រិតយល់ដឹងពីខ្លឹមសារសំខាន់នៃទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនតាមវិទ្យាល័យ បានបង្ហាញឱ្យឃើញថាក្នុងចំណោមអ្នកបានបំពេញកម្រងសំណួរចំនួន១០០នាក់បានគិតថាខ្លឹមសារសំខាន់ៗនៃទម្រង់ផែនការ មានសេចក្តីផ្តើម ចំនួន៦៦នាក់ ប្រវត្តិសាលារៀនចំនួន៨៥នាក់ ចក្ខុវិស័យចំនួន៩៦នាក់ បេសកកម្មចំនួន៧៧នាក់ ការវិភាគស្ថានភាពអប់រំ និងបញ្ហាប្រឈមចម្បងៗចំនួន៩១នាក់ គោលបំណងចំនួន៧៦នាក់ សូចនាករ និងចំណុចដៅចំនួន៧៥នាក់ យុទ្ធសាស្ត្រ និងសកម្មភាពចំនួន៨៧នាក់ តម្រូវការហិរញ្ញប្បទានចំនួន៦៧នាក់ យន្តការពិនិត្យតាមដាន និងវាយតម្លៃចំនួន៨០នាក់ ឧបសម្ព័ន្ធចំនួន៥០នាក់ និងអ្នកដែលបានឆ្លើយថាខ្លឹមសារសំខាន់របស់ទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនគ្រប់ចំណុចទាំងអស់ខាងលើចំនួន៧០នាក់ នោះបានបង្ហាញឱ្យឃើញថាក្នុងចំណោមអ្នកបំពេញកម្រងសំណួរ១០០នាក់មាន៧០នាក់បានដឹងថាខ្លឹមសារសំខាន់របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ដូច្នេះដើម្បីឱ្យការរៀបចំផែនការនេះបានត្រឹមត្រូវ លុះត្រាតែអ្នកបានចូលរួមរៀបចំត្រូវយល់ដឹងពីទម្រង់ទាំងអស់ឱ្យបានច្បាស់គ្រប់ៗគ្នា។

**ក្រាប ៤.៣៖ ការរៀបចំផែនការតាមសាលារៀន**



**បំណកស្រាយទិន្នន័យ៖** តាមក្រាបសមាសភាពចំនួន១០០នាក់ និងបំពេញកម្រងសំណួរបានជ្រើសរើសចម្លើយសរុបចំនួន២៩៨ ដែលបង្ហាញឱ្យឃើញថាវិទ្យាល័យដែលបានរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀន ស្មើនឹង២៤.៥០% បានរៀបចំផែនការយុទ្ធសាស្រ្តថវិកា ស្មើនឹង១៩.៤៦% បានរៀបចំផែនការប្រតិបត្តិ ស្មើនឹង២៦.១៧% បានរៀបចំផែនការថវិកាប្រចាំឆ្នាំ ស្មើនឹង២៣.១៥% និងបានឆ្លើយថាមានការរៀបចំផែនការផ្សេង ស្មើនឹង៦.៧១%។

## ក្រាប ៤.៤៖ ការយល់ដឹងពីការសរសេរសេចក្តីផ្តើម




**បំណកស្រាយទិន្នន័យ៖** តាមក្រាបខាងលើបានបង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការសរសេរសេចក្តីផ្តើម កម្រិតក្រោមមធ្យមចំនួន០៥នាក់ត្រូវជា៧.៩% កម្រិតមធ្យមចំនួន៤៥នាក់ត្រូវជា៤៤.៣% កម្រិតល្អបង្គួរចំនួន៣២នាក់ត្រូវជា៣២.៩% កម្រិតល្អចំនួន១៨នាក់ត្រូវជា១៤.៧% និងកម្រិតល្អណាស់ចំនួន០០នាក់ត្រូវជា០០%។

## ក្រាប ៤.៥៖ ការយល់ដឹងពីការសរសេរប្រវត្តិសាលារៀន



**បំណកស្រាយទិន្ន័យ៖** តាមក្រាបបានបង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការសរសេរប្រវត្តិសាលារៀនកម្រិតក្រោមមធ្យមចំនួន១២នាក់ត្រូវជា១០.៧% កម្រិតមធ្យមចំនួន៣០នាក់ត្រូវជា៣៦.៤% កម្រិតល្អបង្គួរចំនួន៤២នាក់ត្រូវជា៣៨.៦% កម្រិតល្អចំនួន១៦នាក់ត្រូវជា១៤.៣% និងកម្រិតល្អណាស់ចំនួន០០នាក់ត្រូវជា០០%។

## ក្រាប ៤.៦៖ ការយល់ដឹងពីការសរសេរចក្ខុវិស័យ




**បំណកស្រាយទិន្ន័យ៖** តាមក្រាបបានបង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការសរសេរចក្ខុវិស័យកម្រិតក្រោមមធ្យមចំនួន៦នាក់ត្រូវជា៧.៩% កម្រិតមធ្យមចំនួន៤៨នាក់ត្រូវជា៤៤.៣% កម្រិតល្អបង្គួរចំនួន៣៦នាក់ត្រូវជា៣២.៩% កម្រិតល្អចំនួន០៩នាក់ត្រូវជា១៤.៧% និងកម្រិតល្អណាស់ចំនួន០១នាក់ត្រូវជា០.៧%។

## ក្រាប ៤.៧៖ ការយល់ដឹងពីការសរសេរបេសកកម្ម



**បំណកស្រាយទិន្ន័យ៖**បង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការសរសេរ បេសកកម្មកម្រិតក្រោមមធ្យមចំនួន៨នាក់ត្រូវជា១២.១% កម្រិតមធ្យមចំនួន៥៣នាក់ត្រូវជា៤៩.៣% កម្រិតល្អបង្គួរចំនួន២៤នាក់ត្រូវជា២៤.៣% កម្រិតល្អចំនួន១៤នាក់ត្រូវជា១៣.៦% និងកម្រិតល្អណាស់ ចំនួន០១នាក់ត្រូវជា០.៧%។

## ក្រាប ៤.៨៖ ការយល់ដឹងពីការវិភាគស្ថានភាព និងបញ្ហាប្រឈម




**បំណកស្រាយទិន្ន័យ៖** បង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការវិភាគស្ថានភាព និងបញ្ហាប្រឈមចម្បងៗ កម្រិតក្រោមមធ្យមចំនួន០៥នាក់ត្រូវជា៥.៧% កម្រិតមធ្យមចំនួន៤៧ នាក់ត្រូវជា៤០.៧% កម្រិតល្អបង្គួរចំនួន៣៩នាក់ត្រូវជា៤២.១% កម្រិតល្អចំនួន១៦នាក់ត្រូវជា១១.៤% និងកម្រិតល្អណាស់ចំនួន០០នាក់ត្រូវជា០០%។

## ក្រាប ៤.៩៖ ការយល់ដឹងពីការសរសេរគោលបំណង



**បំណកស្រាយទិន្នន័យ៖** បង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការសរសេរគោលបំណង កម្រិតក្រោមមធ្យមចំនួន០៩នាក់ត្រូវជា៧.៩% កម្រិតមធ្យមចំនួន៥១នាក់ត្រូវជា ៤៧.៩% កម្រិតល្អបង្គួរចំនួន២៣នាក់ត្រូវជា៣២.១% កម្រិតល្អចំនួន១៦នាក់ត្រូវជា១១.៤% និងកម្រិតល្អណាស់ចំនួន០១នាក់ត្រូវជា០.៧%។

## ក្រាប ៤.១០៖ ការយល់ដឹងពីការសរសេរសូចនាករ និងចំណុចដៅជាSMART




**បំណកស្រាយទិន្នន័យ៖** បង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការសរសេរសូចនាករ និងចំណុចដៅមានលក្ខណៈSMART កម្រិតក្រោមមធ្យមចំនួន១២នាក់ត្រូវជា១៤.៣% កម្រិតមធ្យមចំនួន៦៤នាក់ត្រូវជា៥៨.៦% កម្រិតល្អបង្គួរចំនួន២១នាក់ត្រូវជា២២.១% កម្រិតល្អចំនួន០៣នាក់ត្រូវជា៥% និងកម្រិតល្អណាស់ចំនួន០០នាក់ត្រូវជា០.០%។

## ក្រាប ៤.១១៖ ការយល់ដឹងពីការសរសេរយុទ្ធសាស្ត្រ និងសកម្មភាព



**បំណកស្រាយទិន្ន័យៈ** បានបង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការសរសេរយុទ្ធសាស្ត្រ និងសកម្មភាព កម្រិតក្រោមមធ្យមចំនួន១៦នាក់ត្រូវជា១១.៤% កម្រិតមធ្យមចំនួន៥៦នាក់ត្រូវជា៤៧.១% កម្រិតល្អបង្គួរចំនួន២៣នាក់ត្រូវជា៣២.៩% កម្រិតល្អចំនួន៥នាក់ត្រូវជា៨.៦% និងកម្រិតល្អណាស់ចំនួន០០នាក់ត្រូវជា០.០%។

## ក្រាប ៤.១២ ៖ការយល់ដឹងពីការវិភាគតម្រូវការហិរញ្ញប្បទាន




**បំណកស្រាយទិន្ន័យៈ** បង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការវិភាគតម្រូវការហិរញ្ញប្បទាន កម្រិតក្រោមមធ្យមចំនួន១៩នាក់ត្រូវជា១៣.៦% កម្រិតមធ្យមចំនួន៥៧នាក់ត្រូវជា៤៧.៩% កម្រិតល្អបង្គួរចំនួន១៨នាក់ត្រូវជា២៥% កម្រិតល្អចំនួន៦នាក់ត្រូវជា១៣.៦% និងកម្រិតល្អណាស់ចំនួន០០នាក់ត្រូវជា០.០%។

## ក្រាប ៤.១៣៖ ការយល់ដឹងពីការសរសេរយន្តការពិនិត្យតាមដាន និងវាយតម្លៃ



**បំណកស្រាយទិន្ន័យៈ** បង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការបង្កើតយន្តការពិនិត្យតាមដាន និងវាយតម្លៃ កម្រិតក្រោមមធ្យមចំនួន១៧នាក់ត្រូវជា១២.៩% កម្រិតមធ្យមចំនួន៥៤នាក់ត្រូវជា៤៥% កម្រិតល្អបង្គួរចំនួន២០នាក់ត្រូវជា៣០% កម្រិតល្អចំនួន៨នាក់ត្រូវជា១២.១% និងកម្រិតល្អណាស់ចំនួន០១នាក់ត្រូវជា០.៧%។

**ក្រាប ៤.១៤ ៖ការយល់ដឹងពីការដាក់ទិន្ន័យបញ្ចូលក្នុងតារាង៩បសម្ព័ន្ធ**




**បំណកស្រាយទិន្ន័យៈ** បង្ហាញឱ្យឃើញថាក្នុងចំណោម១០០នាក់បានយល់ដឹងពីការបញ្ចូលទិន្ន័យក្នុងតារាង៩បសម្ព័ន្ធ កម្រិតក្រោមមធ្យមចំនួន១០នាក់ត្រូវជា១២.១% កម្រិតមធ្យមចំនួន៥៨នាក់ត្រូវជា៥២.៩% កម្រិតល្អបង្គួរចំនួន២៣នាក់ត្រូវជា២៨.៦% កម្រិតល្អចំនួន០៨នាក់ត្រូវជា៥.៧% និងកម្រិតល្អណាស់ចំនួន០១នាក់ត្រូវជា០.៧%។

## ផ្នែកទី៣៖ ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

ក្រាប៤.១៥៖សមាសភាពបំពេញកម្រងសំណួរក្នុងការចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលា




**បំណកស្រាយទិន្នន័យ៖** បង្ហាញឱ្យឃើញថាក្នុងចំណោមអ្នកបំពេញកម្រងសំណួរ១០សាលាគោលដៅ និងចំនួន១០០នាក់មានចំនួន៨៨នាក់បានចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងមានចំនួន១២នាក់ឆ្លើយថាមិនបានចូលរួមក្នុងការរៀបចំ។

ក្រាប៤.១៦៖ លក្ខណៈរបស់ផែនការ




**បំណកស្រាយទិន្នន័យ៖** សមាសភាពចំនួន១០០នាក់ បានបំពេញកម្រងសំណួរនិងជ្រើសរើសចម្លើយចំនួន ១៩១បានបង្ហាញឱ្យឃើញថាកាលយល់ដឹងពីចរឹកលក្ខណៈទាំងបីរបស់ផែនការដោយយល់

ថាផែនការមានលក្ខណៈលទ្ធិប្រជាធិបតេយ្យ(ការចូលរួម)ស្មើនឹង ៥៤.៥% ផែនការមានលក្ខណៈវិទ្យាសាស្ត្រស្មើនឹង ២៥.៧% និងផែនការមានលក្ខណៈច្បាប់ស្មើនឹង ១៩.៩% ។

**ក្រាប ៤.១៧ ៖ការពិគ្រោះយោបល់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន**




**បំណកស្រាយទិន្នន័យ៖** ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនដើម្បីឱ្យសាលារៀនមួយមានផែនការទទួលបានប្រសិទ្ធិភាព និងគុណភាពគឺទាមទារឱ្យមានការចូលរួមពិគ្រោះយ៉ាងទូលំទូលាយពីអ្នកពាក់ព័ន្ធរួមមាន៖គណៈគ្រប់គ្រងសាលា(នាយក/នាយិកា) នាយករង/នាយិការង លេខាធិកា គណនេយ្យ ប្រធានក្រុមបច្ចេកទេស អនុប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន សិស្សានុសិស្ស សហគមន៍ ក្រុមប្រឹក្សា ឬគណៈគ្រប់គ្រងសាលារៀន អជ្ញាធរមូលដ្ឋាន មាតាបិតា ឬអាណាព្យាបាលសិស្ស និងអ្នកពាក់ព័ន្ធផ្សេងៗ ។ការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់បែបនេះត្រូវបានផ្តល់អត្ថប្រយោជន៍ច្រើនក្នុងការរៀបចំផែនការដែលអាចប្រមូលបានព័ត៌មានគ្រប់ជ្រុងជ្រោយ កំណត់បានបញ្ហាប្រឈមជាអាទិភាព និងរួមគ្នាស្វែងរកដំណោះស្រាយសមស្របដែលឆ្លើយតបនឹងតម្រូវការ និងធនធានជាក់ស្តែង។ម្យ៉ាងវិញទៀត

ផែនការអភិវឌ្ឍសាលារៀនដែលរៀបចំឡើងដោយមានការចូលរួមពិគ្រោះយោបល់យ៉ាងទូលំទូលាយបែបនេះនឹងទទួលបានការគាំទ្រពីអ្នកពាក់ព័ន្ធទាំងនោះដែលជាកត្តាសំខាន់ក្នុងការធ្វើឱ្យការអនុវត្តទទួលបានជោគជ័យ។ជាមួយគ្នានេះដែរវាក៏ចូលរួមចំណែកចម្បងផងដែរក្នុងការកសាងទំនាក់ទំនងល្អ និងកិច្ចសហការណ៍ធ្វើការរួមគ្នាដើម្បីឱ្យស្ថាបនមានការរីកចំរើន ជាពិសេសឆ្លើយតបទៅនឹងបរិបទអប់រំ ជានាគុណភាពសមធម៌ បរិយាបន្ន ពេលបច្ចុប្បន្នក៏ដូចនាពេលអនាគត ដែលក្រសួងបានកំពុងយកចិត្តទុកដាក់តាមរយៈការជំរុញឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំ ។តាមក្រាប៤.៣.៣ បានបង្ហាញពីការចូលរួមពិគ្រោះយោបល់ឱ្យឃើញថា ក្នុងការបំពេញកម្រងសំណួរចំនួន១០០នាក់បានជ្រើសរើសចម្លើយចំនួន ៨៣៥ និងបានឆ្លើយថា ការពិគ្រោះយោបល់ក្នុងការរៀបចំផែនការដោយនាយក/នាយិកាស្មើនឹង ១១.៩៨% ដោយនាយករង/នាយិការងស្មើនឹង ១១.៦២% ដោយលេខាធិកាស្មើនឹង ១១.០២% ដោយគណនេយ្យស្មើនឹង ១១.២៦% ដោយប្រធានក្រុមបច្ចេកទេសស្មើនឹង ១០.៣០% ដោយអនុប្រធានក្រុមបច្ចេកទេសស្មើនឹង ៧.៥៤% ដោយគ្រូបង្រៀនស្មើនឹង ៨.១៤% ដោយសិស្សានុសិស្សស្មើនឹង ១.៦៨% ដោយសហគមន៍ស្មើនឹង ៩.៥៨% ដោយក្រុមប្រឹក្សា ឬគណៈគ្រប់គ្រងសាលារៀនស្មើនឹង ៩.៩៤% ដោយអាជ្ញាធរមូលដ្ឋានស្មើនឹង ៣.៥៩% ដោយមាតាបិតា ឬអាណាព្យាបាលសិស្សស្មើនឹង ២.៩៩% ដោយអ្នកពាក់ព័ន្ធផ្សេងៗស្មើនឹង ០.៣៦% ។តាមរយៈលទ្ធផលនេះបង្ហាញជារួមថាការពិគ្រោះយោបល់នៅតាមវិទ្យាល័យទាំងអស់នេះគឺផ្តោតសំខាន់ទៅលើថ្នាក់គ្រប់គ្រងសាលារៀនតែប៉ុណ្ណោះ រីឯអ្នកពាក់ព័ន្ធពុំសូវទទួលបានការពិគ្រោះយោបល់ច្រើនទេ។

**តារាង ៤.២ ៖ការអនុវត្តដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន**

| ការរៀបចំ | ចំនួន | ភាគរយ |
|---|---|---|
| រៀបចំដោយនាយក/នាយិកាជាអ្នករៀបចំទាំងស្រុង | 22 | 7.8% |
| រៀបចំដោយនាយករង/នាយិការងជាអ្នករៀបចំទាំងស្រុង | 13 | 4.6% |
| រៀបចំដោយលេខាធិការជាអ្នករៀបចំទាំងស្រុង | 2 | 0.7% |

| | | |
|---|---|---|
| រៀបចំដោយគណនេយ្យជាអ្នករៀបចំទាំងស្រុង | 91 | 32.4% |
| រៀបចំដោយគណៈគ្រប់គ្រងសាលា(នាយក/នាយករង) ជាអ្នករៀបចំរួចប្រជុំផ្សព្វផ្សាយដល់គ្រូបង្រៀន | 21 | 7.5% |
| រៀបចំដោយគណៈគ្រប់គ្រងសាលា(រដ្ឋបាលឃុំ/សង្កាត់) និង នាយក/នាយិកា | 100 | 35.6% |
| រៀបចំដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ (នាយក/នាយិកា នាយករង/នាយិការង លេខាធិការ គណនេយ្យ គ្រូបង្រៀន មាតាបិតាសិស្ស អាណាព្យាបាលសិស្ស សហគមន៍ អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស ...) | 13 | 4.6% |
| រៀបចំដោយថ្នាក់មន្ទីរ អប់រំ យុវជន និងកីឡាខេត្ត | 10 | 3.6% |
| រៀបចំដោយថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក | 7 | 2.5% |
| រៀបចំដោយយកតាមគំរូវិទ្យាល័យផ្សេង | 1 | 0.4% |
| រៀបចំដោយយកលំនាំតាមផែនការចាស់ដដែល | 1 | 0.4% |
| ចម្លើយផ្សេងទៀត(បើមាន) | 0 | 0% |
| **សរុប** | **281** | **100%** |

**បំណកស្រាយទិន្ន័យ៖** សម្រាប់ការអនុវត្តនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន យើងបានសិក្សាស្រាវជ្រាវពីរបៀបរៀបចំផែនការសាលានៅតាមវិទ្យាល័យគោលដៅទាំង១០ ថាតើវាសមស្របទៅនឹងនិតិវិធីដែលក្រសួងអប់រំ យុវជន និងកីឡាបានកំណត់ដែរឬទេ។យើងធ្វើការរាប់ចម្លើយរបស់អ្នកចូលរួមទាំងអស់រួចធ្វើការគណនា វិភាគក្នុងប្រព័ន្ធSPSS ជាភាគរយ ចំពោះវិទ្យាល័យនីមួយៗបានអនុវត្តសម្រាប់រៀបចំផែនការ ហើយចុងក្រោយយើងធ្វើការវិភាគលើចម្លើយទាំងអស់នោះ។ជាមួយគ្នានោះដែរ យើងបានបង្កើតកម្រងសំណួរ និងជម្រើសចម្លើយជាច្រើនសម្រាប់អ្នកចូលរួមធ្វើការជ្រើសរើសលើនិតិវិធីនៃការរៀបចំផែនការអភិវឌ្ឍសាលារៀន ដែលជាជម្រើសទាំងអស់នោះរួមមាន ១)រៀបចំដោយនាយក/នា

យិកាជាអ្នករៀបចំទាំងស្រុង ២)រៀបចំដោយនាយករង/នាយិការងជាអ្នករៀបចំទាំងស្រុង ៣)រៀបចំដោយលេខាធិការជាអ្នករៀបចំទាំងស្រុង ៤)រៀបចំដោយគណនេយ្យជាអ្នករៀបចំទាំងស្រុង ៥)រៀបចំដោយគណៈគ្រប់គ្រងសាលា(នាយក/នាយករង) ជាអ្នករៀបចំរួចប្រជុំផ្សព្វផ្សាយដល់គ្រូបង្រៀន ៦)រៀបចំដោយគណៈគ្រប់គ្រងសាលា(រដ្ឋបាលឃុំ/សង្កាត់) និងនាយក/នាយិកា ៧)រៀបចំដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ (នាយក/នាយិកា នាយករង/នាយិការង លេខាធិការ គណនេយ្យ គ្រូបង្រៀន មាតាបិតាសិស្ស អាណាព្យាបាលសិស្ស សហគមន៍ អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស ...) ៨)រៀបចំដោយថ្នាក់មន្ទីរ អប់រំ យុវជន និងកីឡាខេត្ត ៩)រៀបចំដោយថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក ៩)រៀបចំដោយយកតាមគំរូវិទ្យាល័យផ្សេង ១០)រៀបចំដោយយកលំនាំតាមផែនការចាស់ដដែល ១១)ចម្លើយផ្សេងទៀត(បើមាន)

យោងតាមតារាង បានបង្ហាញឱ្យឃើញថាផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនត្រូវបានរៀបចំតាមបែបផ្សេងៗគ្នា ក្នុងនោះចំនួនអ្នកបំពេញកម្រង១០០នាក់ បានឆ្លើយថាបានរៀបចំតាមរយៈពហុចម្លើយបានមកពីការជ្រើសរើសចម្លើយចំនួន២២២ ក្នុងនោះអ្នកបានឆ្លើយថាការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍសាលាដោយនាយក/នាយិកាទាំងស្រុងស្មើនឹង១១.៧១% រៀបចំដោយនាយករង/នាយិការងទាំងស្រុងស្មើនឹង៥.៨៦% រៀបចំដោយលេខាធិកាទាំងស្រុងស្មើនឹង៦.៧៦% រៀបចំដោយគណនេយ្យទាំងស្រុងស្មើនឹង៩.៤៦% រៀបចំដោយគណៈគ្រប់គ្រងសាលា(នាយក/នាយករង)ជាអ្នករៀបចំរួចប្រជុំផ្សព្វផ្សាយដល់គ្រូបង្រៀន ស្មើនឹង៣៧.៣៩% រៀបចំដោយគណៈគ្រប់គ្រងសាលា(រដ្ឋបាលឃុំ/សង្កាត់) និងនាយក/នាយិកាស្មើនឹង៨.១១% រៀបចំដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ (នាយក/នាយិកា នាយករង/នាយិការង លេខាធិការ គណនេយ្យ គ្រូបង្រៀន មាតាបិតាសិស្ស អាណាព្យាបាលសិស្ស សហគមន៍ អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស ...)ស្មើនឹង៥.៨៦% រៀបចំដោយថ្នាក់មន្ទីរ អប់រំ យុវជន និងកីឡាខេត្តស្មើនឹង៨.១១% រៀបចំដោយថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកស្មើនឹង៨.១១% រៀបចំដោយយកតាមគំរូវិទ្យាល័យផ្សេងស្មើនឹង១.៣៥% រៀបចំដោយយកលំនាំតាមផែនការចាស់ដដែលស្មើ

នឹង០.៩% ចម្លើយផ្សេងទៀត(បើមាន)ស្មើនឹង០% ។តាមរយៈលទ្ធផលជារួមនេះយើងអាចសន្និដ្ឋានបានថាដើម្បីឱ្យការរៀបចំផែនការមួយប្រកបដោយគុណភាពគឺទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ។

**តារាង៤.៣ ៖បញ្ហាប្រឈមការរៀបចំផែនការយុទ្ធសស្ត្រអភិវឌ្ឍសាលារៀន**

| បញ្ហាប្រឈម | ចំនួន | ភាគរយ |
|---|---|---|
| មិននយល់ពីគោលនយោបាយអប់រំនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ | 36 | 6.2% |
| មិនសូវយល់ពីគោលនយោបាយអប់រំនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ | 43 | 7.4% |
| មិនទាន់យល់ច្បាស់ពីខ្លឹមសារពាក្យគន្លឹះនៃទម្រង់របស់ផែនការ | 67 | 11.5% |
| មិនអាចគណនាសូចនាករអប់រំសំខាន់ៗ | 45 | 7.7% |
| មិនសូវយល់ច្បាស់ក្នុងគណនាសូចនាករអប់រំសំខាន់ៗ | 51 | 8.7% |
| មិនអាចធ្វើចំណោលសិស្ស តម្រូវការហិរញ្ញប្បទាន និងចំណុចដៅនៃសូចនាករបាន | 32 | 5.5% |
| មិនសូវយល់ច្បាស់ការធ្វើចំណោលសិស្ស ចំណោលតម្រូវការហិរញ្ញប្បទាន និង ចំណោលចំណុចដៅនៃសូចនាករបាន | 84 | 14.4% |
| មិនមានប្រភពថវិកាដៃគូអភិវឌ្ឍចូលរួមក្នុងការអភិវឌ្ឍសាលារៀន | 40 | 6.8% |
| មិនមានប្រភពថវិកាសប្បុរសជនចូលរួមក្នុងការអភិវឌ្ឍសាលារៀន | 31 | 5.3% |
| មិនមានប្រភពថវិកាអជ្ញាធរដែនដីនិងសហគមន៍ចូលរួមក្នុងការអភិវឌ្ឍសាលារៀន | 18 | 3.1% |
| មិនចុះសម្រុងគ្នាក្នុងពេលរៀបចំ | 8 | 1.4% |
| អ្នកចូលរួមមានសមត្ថភាពមិនទាន់គ្រប់គ្រាន់ក្នុងការរៀបចំ | | |
| សកម្មភាពដែលបានរៀបចំក្នុងផែនការការិយាល័យក្រុង/ស្រុក/មន្ទីរ មិនគាំទ្រ | 31 | 5.3% |
| មូលនិធិដំណើរការគ្រឹះស្ថានសាធារណៈទម្លាក់មិនទាន់ | 2 | 0.3% |
| មូលនិធិដំណើរការគ្រឹះស្ថានសាធារណៈមានកម្រិតតិចតួចនៅឡើយ | 11 | 1.9% |
| គ្រោងសកម្មភាពក្នុងផែនការចាស់មិនបានដាក់បញ្ចូលក្នុងផែនការថ្មី | 10 | 1.7% |

| | | |
|---|---|---|
| គ្រោងសកម្មភាពថ្មីមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលា | 7 | 1.2% |
| កង្វះធនធានមនុស្សដែលមានសមត្ថភាពដើម្បីរៀបចំផែនការប្រកបដោយប្រសិទ្ធភាព | 19 | 3.2% |
| ការចូលរួម និងបញ្ចេញមតិយោបល់ពីអ្នកពាក់ព័ន្ធពុំទាន់បានពេញលេញ | 33 | 5.6% |
| បញ្ហាផ្សេងៗទៀតបើមាន | 17 | 2.9% |
| **សរុប** | **585** | **100%** |

**បំណកស្រាយទិន្ន័យៈ** សម្រាប់ការអនុវត្តនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន យើងបានសិក្សាស្រាវជ្រាវពីបញ្ហាប្រឈមនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលានៅតាមវិទ្យាល័យគោលដៅទាំង១០ គឺចង់រកឱ្យឃើញថាវិទ្យាល័យទាំង១០កំពុងមានបញ្ហាប្រឈមអ្វីខ្លះក្នុងការរៀបចំ។ យោងតាមតារាង៤.៣. បានបង្ហាញឱ្យឃើញថាអ្នកចូលរួមចំនួន១០០នាក់បាន ជ្រើសរើសចម្លើយចំនួន ៥៨៥ ក្នុងនោះអ្នកបានឆ្លើយថាការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនមានបញ្ហាប្រឈមមិនយល់ពីគោលនយោបាយអប់រំនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំស្មើនឹង៦.២% មិនសូវយល់ពីគោលនយោបាយអប់រំនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំស្មើនឹង៧.៤% មិនទាន់យល់ច្បាស់ពីខ្លឹមសារពាក្យគន្លឹះនៃទម្រង់របស់ផែនការស្មើនឹង១១.៥% មិនអាចគណនាសូចនាករអប់រំសំខាន់ៗស្មើនឹង៧.៧% មិនសូវយល់ច្បាស់ក្នុងគណនាសូចនាករអប់រំសំខាន់ៗស្មើនឹង៨.៧% មិនសូវយល់ច្បាស់ការធ្វើចំណោលសិស្ស ចំណោលតម្រូវការហិរញ្ញប្បទាន និងចំណោលចំណុចដៅនៃសូចនាករបានស្មើនឹង៥.៥%

មិនសូវយល់ច្បាស់ការធ្វើចំណោលសិស្ស ចំណោលតម្រូវការហិរញ្ញប្បទាន និងចំណោលចំណុចដៅនៃសូចនាករបានស្មើនឹង១៤.៤% មិនមានប្រភពថវិកាដៃគូអភិវឌ្ឍចូលរួមក្នុងការអភិវឌ្ឍសាលារៀនស្មនឹង ៦.៨% មិនមានប្រភពថវិកាសប្បុរសជនចូលរួមក្នុងការអភិវឌ្ឍសាលារៀនស្មើនឹង៥.៣% មិនមានប្រភពថវិកាអជ្ញាធរដែនដីនិងសហគមន៍ចូលរួមក្នុងការអភិវឌ្ឍសាលារៀនស្មើនឹង៣.១% មិនចុះសម្រុងគ្នាក្នុងពេលរៀបចំអ្នកចូលរួមមានសមត្ថភាពមិនទាន់គ្រប់គ្រាន់ក្នុងការរៀបចំស្មើនឹង១.៤% សកម្មភាពដែលបានរៀបចំក្នុងផែនការការិយាល័យក្រុង/ស្រុក/មន្ទីរ មិនគាំទ្រស្មើនឹង៥.៣% មូលនិធិដំណើរការគ្រឹះស្ថានសាធារណៈទម្លាក់មិនទាន់ស្មើនឹង០.៣% មូលនិធិដំណើរការគ្រឹះស្ថានសាធារណៈមានកម្រិតតិចតួចនៅ

ឡើយស្មើនឹង១.៩% គ្រោងសកម្មភាពក្នុងផែនការចាស់មិនបានដាក់បញ្ចូលក្នុងផែនការថ្មីស្មើនឹង១.៧% គ្រោងសកម្មភាពថ្មីមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលាស្មើនឹង១.២% កង្វះធនធានមនុស្សដែលមានសមត្ថភាពដើម្បីរៀបចំផែនការប្រកបដោយប្រសិទ្ធភាពស្មើនឹង៣.២% ការចូលរួម និងបញ្ចេញមតិយោបល់ពីអ្នកពាក់ព័ន្ធពុំទាន់បានពេញលេញស្មើនឹង៥.៦% បញ្ហាផ្សេងៗទៀតបើមានស្មើនឹង ២.៩%។

## ក្រាប ៤.១៨ ៖ បញ្ហាប្រឈមចម្បងក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន




**បំណកស្រាយទិន្ន័យ៖** តាមក្រាមខាងលើនេះ យើងឃើញថាបញ្ហាប្រឈមជាអាទិភាពបំផុតដែលអ្នកចូលរួមទាំងអស់បានជ្រើសរើសតាមលំដាប់លំដោយសំខាន់ចំនួន៣(បី)នោះគឺ ១)មិនសូវយល់ច្បាស់ការធ្វើចំណោលសិស្ស ចំណោលតម្រូវការហិរញ្ញប្បទាន និងចំណោលចំណុចដៅនៃសូចនាករបានស្មើនឹង ១៤.៤% ២)មិនទាន់យល់ច្បាស់ពីខ្លឹមសារពាក្យគន្លឹះនៃទម្រង់របស់ផែនការស្មើនឹង១១.៥% ៣)មិនសូវយល់ច្បាស់ក្នុងគណនាសូចនាករអប់រំសំខាន់ៗស្មើនឹង៨.៧%។ តាមរយៈលទ្ធផលនេះយើងអាចសន្និដ្ឋានបានថាវិទ្យាល័យទាំងអស់នេះពុំយល់ដឹងបច្ចេកទេសផែនការ ការគណនាសូចនាករអប់រំ និងគណនាចំណោលហិរញ្ញប្បទានបានល្អនៅឡើយទេ។

### ក្រាប ៤.១៩៖ ការផ្សព្វផ្សាយក្រោយពីការរៀបចំផែនការ




កម្រងសំណួរ១០០នាក់ អ្នកបានឆ្លើយថាក្រោយពីបានរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរួច ហើយបានបែងចែកជា៥កម្រិត១) សាលាមិនបានផ្សព្វផ្សាយសោះស្មើនឹង០% ២)បានតិចតួច៥.៧% ៣)មធ្យមស្មើនឹង៣៨.៦% ៤)ច្រើនស្មើនឹង៥០% ៥)ច្រើនណាស់ស្មើនឹង៥.៧% ។

### ក្រាប ៤.២០៖ ការលើកទឹកចិត្តក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន




គឺមានការលើកទឹកចិត្តក្នុងការរៀបចំផែនការដល់អ្នកចូលរួមស្មើនឹង៩៦.៤% និងបានឆ្លើយថាមិនបានលើកទឹកចិត្តស្មើនឹង៣.៦%។

ក្រាប ៤.២១ ៖ការលើកទឹកចិត្តក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន




**បំណកស្រាយទិន្នន័យ៖** បង្ហាញឱ្យឃើញថាក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន គឺទទួលបានការលើកទឹកចិត្តពីសាលារៀនស្មើនឹង៦៤.៣% ពីការិយាល័យអប់រំ យុជន និងកីឡាក្រុង/ស្រុកស្មើនឹង១៦.៩% ពីមន្ទីរអប់រំ យុវជន និងកីឡាខេត្តស្មើនឹង១៤.៣% ពីក្រសួងអប់រំ យុវជន និងកីឡាស្មើនឹង៤.៥% ។

ក្រាប៤.២២ ៖ យុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនជារឿងសំខាន់




**បំណកស្រាយទិន្នន័យ៖** បង្ហាញឱ្យឃើញថាក្នុងចំណោមអ្នកបំពេញកម្រងសំណួរគិតថាការលើកទឹកចិត្តក្នុងការរៀបចំផែនការគឺជារឿងសំខាន់ស្មើនឹង៩៦.៤% និងអ្នកគិតថាមិនសំខាន់ស្មើនឹង៣.៦% ។

### ក្រាប ៤.២៣ រង្វាន់លើកទឹកចិត្តក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន




**បំណកស្រាយទិន្នន័យ៖** បង្ហាញឱ្យឃើញថាការលើកទឹកចិត្តពិតជាសំខាន់តែអ្វីដែលអ្នកចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនគឺ ចង់បានការលើកទឹកចិត្តដោយការផ្តល់ជាប័ណ្ណសរសើរស្មើនឹង៦០.៨% ដោយថវិកាស្មើនឹង១៤.៧% ដោយសម្ភារៈស្មើនឹង១២.៦% ដោយការតម្លើងឋានៈស្មើនឹង ១១.៩% ។

### ក្រាប៤.២៤ ៖ការវាយតម្លៃលើកទឹកចិត្តក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន




**បំណកស្រាយទិន្នន័យ៖** បង្ហាញឱ្យឃើញថាការផ្តល់រង្វាន់នៃការលើកទឹកចិត្តត្រូវបានធ្វើការវាយតម្លៃតាមរយៈបក្សពួកស្មើនឹង០.៧% តាមរយៈកិច្ចព្រមព្រៀងការងារស្មើនឹង១៣.២% តាមរយៈលទ្ធផលការងារស្មើនឹង៧៨.១% និងតាមរយៈរបាយការណ៍សមិទ្ធកម្មស្មើនឹង៧.៩% ។

ក្រាប ៤.២៥៖ ការទទួលអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន




**បំណកស្រាយទិន្នន័យ៖** បង្ហាញឱ្យឃើញថាអ្នកដែលបានធ្លាប់ចូលរួមនងទទួលការអភិវឌ្ឍសមត្ថភាពផ្នែកផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនស្មើនឹង៧៧.៩% និងឆ្លើយថាមិនដែរបានចូលរួមអភិវឌ្ឍសមត្ថភាពផ្នែកផែនការស្មើនឹង២២.១%។

ក្រាប៤.២៦៖ ការអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន




**បំណកស្រាយទិន្នន័យ៖** បង្ហាញឱ្យឃើញថាអ្នកដែលបានចូលរួម និងបានទទួលអភិវឌ្ឍសមត្ថភាពនៃខ្លឹមសារនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនរួមមាន ១)ពាក្យគន្លឹះផែនការស្មើនឹង១២.៤% ២)ការវិភាគបញ្ហាស្មើនឹង១២.៩% ៣)ការគណនាសូចនាករស្មើនឹង៨.៤% ៤)ការធ្វើចំណោលស្មើនឹង

៤.៨% ៥)ការគ្រោងចំណាយស្មើនឹង១៤.១% ៦)ការវិភាគហិរញ្ញប្បទានស្មើនឹង៨% ៧)ការជ្រើសរើសយុទ្ធសាស្ត្រស្មើនឹង១៣.៧% ៨)ការពិនិត្យតាមដាន និងវាយតម្លៃស្មើនឹង២២.១% ៩)ការរៀបចំផែនការទាំងស្រុងស្មើនឹង៣.២% ១០)ផ្សេងៗស្មើនឹង០.៤%។

## ៤.២. ការពិភាក្សា

***សំណួរស្រាវជ្រាវទី១៖*** តើស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀននៅតាមវិទ្យាល័យនានាក្នុងខេត្តកំពង់ចាមដំណើរការយ៉ាងដូចម្តេច?

យោងតាមលទ្ធផលស្រាវជ្រាវនៃស្ថានភាពដំណើរការរៀបចំបានបង្ហាញឱ្យឃើញថា អ្នកពាក់ព័ន្ធក្នុងការរៀបចំផែនការគឺផ្តោតសំខាន់លើចក្ខុវិស័យ ការវិភាគស្ថានភាពអប់រំ និងបញ្ហាប្រឈម ការបង្កើតយុទ្ធសាស្ត្រ និងសកម្មភាព ដែលធ្វើឱ្យការរៀបចំនៅមិនទាន់គ្រប់ជ្រុងជ្រោយនៅឡើយទេ ដូច្នេះហើយដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ជាផែនការមួយមានគុណភាព គណៈគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវយល់ដឹងពីខ្លឹមសារគ្រប់ចំណុចទាំងអស់នៃទម្រង់ផែនការ។ ហើយបើយើងពិនិត្យមើលទៅលើសំណាកចំនួន១០០នាក់ ឃើញថាមានចំនួន៧០នាក់បានផ្តល់ចម្លើយថាខ្លឹមសារសំខាន់ៗគឺ គ្រប់ចំណុចទាំងអស់នៃទម្រង់ផែនការ យុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន។ ដូច្នេះហើយក្នុងនាមជាអ្នករៀបចំផែនការត្រូវយល់ឱ្យបានច្រើន និងត្រូវសិក្សាស្រាវជ្រាវអភិវឌ្ឍសមត្ថភាពបន្ថែមឱ្យបានយល់ច្បាស់ពីខ្លឹមសារទាំងនេះគ្រប់ៗគ្នានៃភាគីពាក់ព័ន្ធ។ ប្រសិនបើយើងពិនិត្យមើលទៅការយល់ដឹងស៊ីជម្រៅនៃការសរសេរខ្លឹមសារនីមួយៗ នៃទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនវិញរួមមាន៖ សេចក្តីផ្តើមប្រវត្តិសាលារៀន ចក្ខុវិស័យ បេសកកម្ម ការវិភាគស្ថានភាពបច្ចុប្បន្ន និងបញ្ហាប្រឈម ពីការសរសេរគោលបំណង សូចនាករ និងចំណុចដៅមានលក្ខណៈស្មាត ការបង្កើតយុទ្ធសាស្ត្រ និងសកម្មភាព ការវិភាគតម្រូវការហិរញ្ញប្បទាន ការបង្កើតយន្តការពិនិត្យតាមដាន និងវាយតម្លៃ និងការបញ្ចូលតារាងឧបសម្ព័ន្ធ។ដូច្នេះហើយអ្នករៀបចំផែនការត្រូវយល់ដឹងអំពីចរិកលក្ខណៈរបស់ផែនការឱ្យបានច្បាស់លាស់ និងត្រឹមត្រូវដោយផ្តោតលើប្រជាធិបតេយ្យ (មានការចូលរួម) វិទ្យាសាស្ត្រ និងច្បាប់ ជាពិសេសត្រូវមានការពិគ្រោះ

យោបល់ និងចូលរួមដំណើរការរៀបចំផែនការគ្រប់ ភាគីពាក់ព័ន្ធ( នាយក/នាយិកា នាយករង/នាយិការង លេខាធិកា គណនេយ្យ ប្រធានក្រុមបច្ចេកទេស អនុប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន សិស្សានុសិស្ស សហគមន៍ និងក្រុមប្រឹក្សា ឬគណៈគ្រប់គ្រងសាលារៀន ជាពិសេសត្រូវមានការលើកទឹកចិត្តដោយកត្តាខាងក្នុង និងកត្តាខាងក្រៅដល់អ្នកចូលរួមរៀបចំផែនការព្រមទាំងផ្តល់ការវាយតម្លៃដោយសមស្រមទៅតាមលទ្ធផលការងារ ព្រមទាំងបន្តបណ្តុះបណ្តាល ចែករំលែកចំណេះដឹងដល់អ្នកពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។ចំណែកឯការរៀបចំផែនការផ្សេងៗទៀតនៅតាមសាលារៀនដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ផែនការយុទ្ធសាស្ត្រថវិកា ផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការថវិកាប្រចាំឆ្នាំ ក៏ត្រូវអនុវត្តបែបនេះដែរ ដើម្បីឱ្យការអភិវឌ្ឍសាលារៀនទទួលបានលទ្ធផលល្អ និងឆ្លើយតបតាមកំណែទម្រង់ និងគោលនយោបាយរបស់ក្រសួងអប់រំ យុវជន និងកីឡា។

***សំណួរស្រាវជ្រាវទី២៖*** តើការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យនានាក្នុងខេត្តកំពង់ចាមមានបញ្ហាប្រឈមអ្វីខ្លះ?

តាមលទ្ធផលនៃការការស្រាវជ្រាវស្ថានភាពនៃការរៀបចំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនខណៈពេលដែលកំពុងតែរៀបចំនោះក៏មានបញ្ហាប្រឈមដែលជាកត្តារាំងស្ទះមួយចំនួនផងដែរ ធ្វើឱ្យការរៀបចំផែនការពុំទាន់បានល្អនៅឡើយទេ ដោយថាអ្នកដែលបានចូលរួមរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនគឺមានភាពលំបាកលើកត្តាប្រឈមសំខាន់ៗចំនួនបីដែលទាក់ទងទៅនឹង ១)ពុំទាន់យល់ច្បាស់ពីខ្លឹមសារនៃទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ២)មិនសូវយល់ច្បាស់ពីការគណនាសូចនាករអប់រំសំខាន់ៗ ៣)មិនសូវយល់ច្បាស់ពីការធ្វើចំណោលសិស្សចំណោលតម្រូវការហិរញ្ញប្បទាន និងចំណោលចំណុចដៅនៃសូចនាករ ដែលធ្វើឱ្យមានភាពស្មុកស្មាញនៃដំណើរការរៀបចំដូច្នេះហើយអ្នករៀបចំផែនការ និងអ្នកពាក់ព័ន្ធទាំងអស់ត្រូវស្រាវជ្រាវឯកសារ និងស្វែងរកការការអភិវឌ្ឍសមត្ថភាពបន្ថែមទៀតក្នុងការគណនា និងយកទិន្នន័យដើម្បីឱ្យការរៀបចំផែនការមានខ្លឹមសារ បានល្អ និងមានគុណ

ភាពដែលអាចឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែង មានប្រភពថវិកាច្បាស់លាស់សម្រាប់អភិវឌ្ឍសាលារៀន និងទទួលបានការគាំទ្រពីភាគីពាក់ព័ន្ធដែរឆ្លើយតបទៅនឹងគោលនយោបាយអប់រំ។

# ជំពូកទី៥
# សេចក្តីសន្និដ្ឋាន និងសំណូមពរ

## ៥.១.សេចក្តីសន្និដ្ឋាន

តាមរយៈលទ្ធផលនៃការស្រាវជ្រាវដែលរកទាក់ទងទៅនឹង ស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀននៅតាមវិទ្យាល័យគោលដៅទាំង១០ក្នុងខេត្តកំពង់ចាម យើងអាចសន្និដ្ឋានបានថា ស្ថានភាពក្នុងពេលដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនគណៈគ្រប់គ្រង និងអ្នកពាក់ព័ន្ធទាំងអស់គឺ ពុំទាន់បានធ្វើការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន តាមចរិកលក្ខណៈរបស់ផែនការឱ្យបានច្បាស់លាស់ និងត្រឹមត្រូវនៅឡើយទេ ដោយផ្តោតលើប្រជាធិបតេយ្យ (មានការចូលរួម) វិទ្យាសាស្ត្រ និងច្បាប់ ជាពិសេសត្រូវមានការពិគ្រោះយោបល់ និងចូលរួមដំណើរការរៀបចំផែនការគ្រប់ភាគីពាក់ព័ន្ធ(នាយក/នាយិកា នាយករង/នាយិការង លេខាធិកា គណនេយ្យ ប្រធានក្រុមបច្ចេកទេស អនុប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន សិស្សានុសិស្ស សហគមន៍ និងក្រុមប្រឹក្សា ឬគណៈគ្រប់គ្រងសាលារៀន តែលទ្ធផលដែលបានរកឃើញ គឺទទួលការពិគ្រោះយោបល់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន ពីភាគីពាក់ព័ន្ធបានមួយចំនួនតូចតែប៉ុណ្ណោះ។ ហើយម្យ៉ាងវិញទៀតទន្ទឹមនឹងការរៀបចំនេះក៏ធ្វើឱ្យជួបបញ្ហាប្រឈមចម្បងៗផងដែរ នូវបច្ចេកទេសក្នុងការរៀបចំលើខ្លឹមសារសំខាន់ៗនៃទម្រង់ផែនការ ដោយមានបញ្ហាត្រង់ថាមិនសូវយល់ច្បាស់ការធ្វើចំណោលសិស្ស ចំណោលតម្រូវការហិរញ្ញប្បទាន និងចំណោលចំណុចដៅនៃសូចនាករ មិនទាន់យល់ច្បាស់ពីខ្លឹមសារពាក្យគន្លឹះនៃទម្រង់របស់ផែនការបានច្បាស់លាស់ មិនសូវយល់ច្បាស់ក្នុងគណនាសូចនាករអប់រំសំខាន់ៗ។

តាមរយៈការសិក្សាស្រាវជ្រាវនេះ យើងរកឃើញថាស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនកំពុងជួបប្រទះនូវបញ្ហាប្រឈមច្រើនដែលយកចិត្តទុកដាក់ស្រាវជ្រាវ និងអនុវត្តបន្ថែមទៀត ហើយការសិក្សាលើប្រធានបទនេះបានបង្ហាញ និងធ្វើការសង្កេតឃើញថា ដំណើរការរៀបចំផែនការអភិវឌ្ឍសាលារៀនមិនបានរៀបចំតាមគោលការណែនាំតាមនិតិវិធីនៅឡើយទេ។ អាស្រ័យហេតុ

នេះហើយយើងខ្ញុំជាអ្នកស្រាវជ្រាវមានសំណូមពរមួយចំនួន ដល់ភាគីពាក់ព័ន្ធមេត្តាចូលរួមឱ្យបានសកម្ម និងដោះស្រាយបញ្ហាប្រឈមដែលសាលារៀនជួបប្រទះ ឬរាំងស្ទះដោយកត្តាណាមួយ ដើម្បីគាំទ្រដល់ការរៀបចំផែនការបានយ៉ាងល្អប្រសើរ។

## ៥.២. សំណូមពរ

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវ យើងបានរកឃើញថា មានតែគោលការណ៍ណែនាំរៀបចំផែនការយុទ្ធសស្ត្រអភិវឌ្ឍសាលារៀន ទម្រង់គំរូ និងការបំប៉នសមត្ថភាពទេ ដែលអាចតម្រង់ទិស និងការបង្ហាត់ដោយផ្ទាល់ដែលធ្វើឱ្យពួកគាត់មានសមត្ថភាពក្នុងការរៀបចំផែនការឱ្យមានគុណភាព និងប្រសិទ្ធិភាពដែលជាហេតុធ្វើឱ្យអ្នកស្រាវជ្រាវមានសំណូមពរដូចខាងក្រោម៖

**ក្រសួងអប់រំ យុវជន និងកីឡា៖** ថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាគួរតែបង្កើតគោលការណ៍ណែនាំ និងទម្រង់គំរូផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ជាឯកសារ និងជាវីដេអូ និងផ្តល់ការបំប៉នសមត្ថភាពបន្ថែមលើការកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនដល់ថ្នាក់សាលារៀន។

**មន្ទីរអប់រំ យុវជន និងកីឡា៖** ថ្នាក់ដឹកនាំមន្ទីរអប់រំ យុវជន និងកីឡា គួរតែប្រជុំផ្សព្វផ្សាយគោលការណ៍ណែនាំ និងតម្រង់ទិសពីទម្រង់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន ជាពិសេសចុះបង្វឹក និងបំប៉នផ្ទាល់ថ្នាក់សាលារៀន និងភាគីពាក់ព័ន្ធ។

**ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក៖** ថ្នាក់ដឹកនាំការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុកគួរតែផ្សព្វផ្សាយគោលការណ៍ណែនាំ និងចូលរួមសហការណ៍ក្នុងការអភិវឌ្ឍកសាងផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន។

**គណៈគ្រប់គ្រងវិទ្យាល័យ៖** គណៈគ្រប់គ្រងទាំងអស់គួរតែសិក្សាលម្អិតពីខ្លឹមសារសំខាន់ៗនៃទម្រង់របស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយដោយផ្តល់ឱកាសឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ បានចូលរួមក្នុងការរៀបចំផែការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន និងអនុវត្តឱ្យបានពេញលេញទៅតាមនិតិវិធីដែលក្រសួងបានកំណត់។

**ដៃគូអភិវឌ្ឍ និងភាគីពាក់ព័ន្ធ៖** ដៃគូអភិវឌ្ឍទាំងអស់គួរតែចូលរួមជួយបង្វឹកផ្ទាល់ និងធ្វើការគាំទ្រទាំងបច្ចេកទេស និងថវិកាដើម្បីពង្រឹងសមត្ថភាពដល់គណៈគ្រប់គ្រងសាលា និងភាគីពាក់ព័ន្ធក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន។

**អ្នកស្រាវជ្រាវបន្ត៖** អ្នកសិក្សាស្រាវជ្រាវក្រោយៗ គួរតែពង្រីកវិសាលភាពឱ្យបានទូលំទូលាយជាងនេះ និងស្រាវជ្រាវបន្ថែមទៀតលើដំណាក់កាលនៃការអនុវត្ត ការពិនិត្យតាមដាន និងវាយតម្លៃរបស់ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន។

# ឯកសារយោង

ក្រសួងអប់រំ យុវជន និងកីឡា. (១៩៩៨). ការពន្យល់អំពីការផ្ដើមផែនការកម្មសម្រាប់មន្ត្រីគ្រប់គ្រង. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (១៩៩៨). ការពន្យល់អំពីការផ្ដើមផែនការកម្មសំរាប់មន្ត្រីគ្រប់គ្រងអប់រំ. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (១៩៩៩). ផែនការកម្ម.

ក្រសួងអប់រំ យុវជន និងកីឡា. (១៩៩៩). ឯកសារបណ្ដុះបណ្ដាលផ្នែកផែនការកម្ម ការគ្រប់គ្រង និងរដ្ឋបាល. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០០៦). ឯកសារបំប៉ននាយកសាលាបឋមសិក្សា និងមធ្យមសិក្សាការគ្រប់គ្រងរដ្ឋបាល. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០០៩). ការគ្រប់គ្រងរដ្ឋបាល. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០០៩). ឯកសារបណ្ដុះបណ្ដាលផ្នែកផែនការកម្ម គ្រប់គ្រង និងរដ្ឋបាលអប់រំ. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១០). អភិក្រមជំនួយស្មារតីស្ដីពី គោលការណ៍នៃការគ្រប់គ្រង ការបំពេញការងារក្នុងវិស័យអប់រំ. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៥). វិស័យអប់រំឆ្នាំ២០៣០ក្របខ័ណ្ឌសម្រាប់សកម្មភាពឆ្ពោះទៅរកការអប់រំមានគុណភាព បរិយាប័ន្ន សមធម៌ និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា. ទីក្រុងIncheon: សេចក្ដីប្រកាសទីក្រុងIncheon.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៦). ប្រកាសលេខ៧៦១អយក.ប្រក. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). ក្របខ័ណ្ឌការងារស្ដីពីការរៀបចំផែនការយុទ្ធសាស្ត្រ. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៨). សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀនគម្រ ផងកែលម្អការអប់រំនៅមធ្យមសិក្សា.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). ការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនរយៈពេល៥ ឆ្នាំ. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). គម្រូផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩). ផែនការយុទ្ធសាស្ត្រវិស័យអប់រំ. រាជធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា. (២០១៩-២០២៣). ផែនការយុទ្ធសាស្ត្រវិស័យអប់រំ. រាជធានីភ្នំពេញ: ២០១៩.

ក្រសួងអប់រំ យុវជន និងកីឡា. (២០២០). ក្របខ័ណ្ឌការងារស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យ អប់រំនៃរដ្ឋបាលក្រុង/ស្រុក.

ក្រសួងអប់រំ យុវជន និងកីឡា. (២០២០). ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព. រាជ ធានីភ្នំពេញ: ក្រសួងអប់រំ.

ក្រសួងអប់រំ យុវជន និងកីឡា. (n.d.). សៀវភៅកម្មវិធីសិក្សាអភិវឌ្ឍន៍កម្មវិធីសិក្សា.

ក្រសួងអប់រំយុវជននិងកីឡា. (២០១៨). ក្របខ័ណ្ឌការងារស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រ. រាជធានី ភ្នំពេញ.

ក្រសួងអប់រំយុវជននិងកីឡា. (២០២០). ក្របខ័ណ្ឌការងារស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ នៃរដ្ឋបាលក្រុង/ស្រុក.

ក្រសួងអប់រំ យុវជន និងកីឡា, ក. យ. (២០២០). ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព . រាជាធានីភ្នំពេញ.

ក្រសួងអប់រំ យុវជន និងកីឡា, ក. យ. (២០២០). ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍប្រកបដោយចីរភាព . រាជធានីភ្នំពេញ: ក្រសួងអប់រំ យុវជន និងកីឡា.

បណ្ឌិតច័ន្ទសំណព្វ. (n.d.). សាលាភូមិនរដ្ឋបាល.

រាជរដ្ឋាភិបាល. (២០១៦). សៀវភៅសកម្មភាព និងថវិការបស់គណៈកម្មាធិការជាតិសម្រាប់អភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិគ.ជ.អ.ប. រាជធានីភ្នំពេញ.

រាជរដ្ឋាភិបាល. (២០១៨). អនុក្រឹតលេខ៥៤. រាជធានីភ្នំពេញ: រាជរដ្ឋាភិបាល.

រាជរដ្ឋាភិបាលកម្ពុជា. (២០១៩). រាជធានីភ្នំពេញ.

វិទ្យាស្ថានជាតិអប់រំ. (២០១៧). បញ្ញតិការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ.

វិទ្យាស្ថានជាតិអប់រំ. (២០១៧). បញ្ញត្តិទូទៅស្តីពីលំនាំការរៀបចំផែនការវិស័យអប់រំ. រាជាធានីភ្នំពេញ.

វិទ្យាស្ថានជាតិអប់រំ. (២០១៧). បញ្ញត្តិទូទៅស្តីពីលំនាំនៃការរៀបចំផែនការវិស័យអប់រំ.

វិទ្យាស្ថានជាតិអប់រំ. (២០១៧). បញ្ញាតិទូទៅនៃការរើបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ. រាជាធានីភ្នំពេញ.

វិទ្យាស្ថានជាតិអប់រំ. (២០១៧). បញ្ញាតិនៃការរៀបចំផែនការអប់រំ. រាជធានីភ្នំពេញ.

វិទ្យាស្ថានជាតិអប់រំ. (២០១៧). បញ្ញាតិនៃការរៀបចំផែនការអប់រំ. រាជធានីភ្នំពេញ.

វិទ្យាស្ថានជាតិអប់រំ. (២០១៧). មេរៀនការរៀបចំផែនការយុទ្ធសាស្ត្រវិស័យអប់រំ.

វិទ្យាស្ថានជាតិអប់រំ. (២០១៧). សាណាស្ថានភាពនៃការរៀបចំផែនការអភិវឌ្ឍសាលារៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិ. រាជធានីភ្នំពេញ.

Analyzing Devlopment Issue center. (n.d.).

BrainFidler. (2002). Strategic Managerment for school Development.

Dalin, P. (1998). (www.continuumbooks.com. Retrieved from Sdhool Development Theories and Strategies An International .

Economical Planning, n. (n.d.).

IDWF-ILO. (២០១៧).

Per Dalin. ( 1998 ). Retrieved from https://www.sid-israel.org/en/Development-Issues/What-is-Development.

Per Dalin. ( 1998 ). School development. New York.

PerDalin. ( 1998 ). School Development.

Planning, T. 1. ( n.d. ). mbaofficial.com and businessmanagmentideas.com.

# ឧបសម្ព័ន្ធ

## កម្រងសំណួរបំពេញសម្រាប់

## គណៈគ្រប់គ្រងសាលា លេខាធិការ គណនេយ្យ ប្រធាន/អនុប្រធានក្រុមបច្ចេកទេស និងលោកគ្រូ អ្នកគ្រូ

**ប្រធានបទ៖**

**ស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំ នៅខេត្តកំពង់ចាម**

ខ្ញុំបាទឈ្មោះ **យិន សម្បត្តិ** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៧ នៃវិទ្យាស្ថានជាតិអប់រំ បានរៀបចំការសិក្សាស្រាវជ្រាវលើប្រធានបទមួយស្តីពី «**ស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀនរយៈពេល៥ឆ្នាំនៅខេត្តកំពង់ចាម**» ស្របតាមលក្ខខណ្ឌដើម្បីបញ្ចប់ការសិក្សារបស់វិទ្យាស្ថាន។

ការស្រាវជ្រាវនេះមានគោលបំណងសំខាន់គឺ សិក្សាអំពីស្ថានភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន និងរកឱ្យឃើញបញ្ហាប្រឈមចម្បងៗក្នុងពេលរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀននៅកម្រិតវិទ្យាល័យនៅក្នុងខេត្តកំពង់ចាម។

អាស្រ័យដូចនេះ សូមគណៈគ្រប់គ្រង លេខាធិការ គណនេយ្យ លោកគ្រូ និងអ្នកគ្រូ មេត្តាជួយផ្តល់ព័ត៌មានដែលពិត និងដោយក្តីស្មោះត្រង់ ដើម្បីឲ្យលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះ មានភាពសុក្រិតដោយគ្រាន់តែ លោក លោកស្រីទាំងអស់ ចំណាយរយៈពេលប្រហែល២០ទៅ៣០នាទីដោយក្តីអនុគ្រោះដើម្បីបំពេញកិច្ចការនេះ។ ព័ត៌មានដែលលោក លោកស្រីបានផ្តល់ គឺពិតជាមានសារៈសំខាន់សម្រាប់ការស្រាវជ្រាវនេះ។ រាល់ចម្លើយឬព័ត៌មានរបស់លោក លោកស្រី ត្រូវបានយកមកប្រើសម្រាប់តែការសិក្សាស្រាវជ្រាវតែប៉ុណ្ណោះ។

សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះគណៈគ្រប់គ្រង លេខាធិការ គណនេយ្យ លោកគ្រូ និងអ្នកគ្រូ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបំពេញកម្រងសំណួរនេះ។

**កម្រងសំណួរស្រាវជ្រាវចែកចេញជា៣ផ្នែកដូចខាងក្រោម៖**

**ផ្នែកទី១៖** ព័ត៌មានទូទៅ

**ផ្នែកទី២៖** ការយល់ដឹងពីទម្រង់ ខ្លឹមសារនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

**ផ្នែកទី៣៖** ដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

**ផ្នែកទី១៖ ព័ត៌មានទូទៅ** (សូមគូសសញ្ញា(✓) ក្នុងប្រអប់ ដែលជាព័ត៌មានត្រឹមត្រូវ)៖

១.ភេទ៖ ☐ប្រុស ☐ស្រី

២.ទីតាំងសាលារៀន៖ ☐ទីក្រុង ☐ជនបទ

៣.តួនាទីអ្នកឆ្លើយសំណួរជា៖ ☐ នាយកសាលា/នាយិកាសាលា ☐ នាយករង/នាយិការង

☐ លេខាធិការ ☐ គណនេយ្យ

☐ ប្រធានក្រុមបច្ចេកទេស ☐ អនុប្រធានក្រុមបច្ចេកទេស

☐ គ្រូបង្រៀន ☐ ផ្សេងៗ............................

**ផ្នែកទី២៖ ការយល់ដឹងពីទម្រង់ ខ្លឹមសារនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន**

**សំគាល់៖សម្រាប់សំណួរទាក់ទងទៅនឹងកម្រិតយល់ដឹង**

- ក្រោមមធ្យម មានន័យថាលោក លោកស្រីយល់ដឹងពីខ្លឹមសារនោះតិចបំផុត
- មធ្យម មានន័យថាលោក លោកស្រីយល់ដឹងពីខ្លឹមសារនោះបានខ្លះដែរ
- ល្អបង្គួរ មានន័យថាលោក លោកស្រីយល់ដឹងពីខ្លឹមសារនោះបានច្រើនដែរ
- ល្អ មានន័យថាលោក លោកស្រីយល់ដឹងពីខ្លឹមសារនោះបានច្រើន
- ល្អណាស់ មានន័យថាលោក លោកស្រីយល់ដឹងពីខ្លឹមសារនោះបានច្រើន និងច្បាស់លាស់

៤.តើទម្រង់នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនមានខ្លឹមសារសំខាន់ៗអ្វីខ្លះ ?(អាចជ្រើសរើសលើសពីមួយ)

☐ សេចក្តីផ្តើម

☐ ប្រវត្តិសាលារៀន

☐ ចក្ខុវិស័យ

☐ បេសកកម្ម

☐ វិភាគស្ថានភាពអប់រំ និងបញ្ហាប្រឈមចម្បងៗ

☐ គោលបំណង

☐ សូចនាករ និងចំណុចដៅ

☐ យុទ្ធសាស្ត្រ នងសកម្មភាព

☐ តម្រូវការហិរញ្ញប្បទាន

☐ យន្តការពិនិត្យតាមដាន និងវាយតម្លៃ

☐ ឧបសម្ព័ន្ធ

☐ គ្រប់ចំណុចទាំងអស់ខាងលើ

៥.តើសាលារបស់លោក លោកស្រីមានរៀបចំផែនការអ្វីខ្លះ ? (អាចជ្រើសរើសលើសពីមួយ)

☐ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន

☐ ផែនការយុទ្ធសាស្ត្រថវិកា

☐ ផែនការប្រតិបត្តិប្រចាំឆ្នាំ

☐ ផែនការថវិកាប្រចាំឆ្នាំ

☐ ផែនការផ្សេងៗ..........................................................................................

៦.តើអ្នកយល់ដឹងពីការសរសេរសេចក្តីផ្តើមនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនបានកម្រិតណា ?

☐ ក្រោមមធ្យម ☐ មធ្យម ☐ ល្អបង្គួរ ☐ ល្អ ☐ ល្អណាស់

៧.តើអ្នកយល់ដឹងពីការសរសេរប្រវត្តិសាលានៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនបានកម្រិតណា ?

□ ក្រោមមធ្យម □ មធ្យម □ ល្អបង្គួរ □ ល្អ □ ល្អណាស់

៨.តើអ្នកយល់ដឹងពីការសរសេរចក្ខុវិស័យនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនបានកម្រិតណា?

□ ក្រោមមធ្យម □ មធ្យម □ ល្អបង្គួរ □ ល្អ □ ល្អណាស់

៩.តើអ្នកយល់ដឹងពីការសរសេរបេសកកម្មនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនបានកម្រិតណា?

□ ក្រោមមធ្យម □ មធ្យម □ ល្អបង្គួរ □ ល្អ □ ល្អណាស់

១០.តើអ្នកអាចវិភាគស្ថានភាពអប់រំ និងបញ្ហាប្រឈម(ការចូលរៀន គុណភាពសិក្សា ការគ្រប់គ្រង និងដឹកនាំ) នៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនបានកម្រិតណា?

□ ក្រោមមធ្យម □ មធ្យម □ ល្អបង្គួរ □ ល្អ □ ល្អណាស់

១១.តើអ្នកយល់ដឹងពីការសរសេរគោលបំណងនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនបានកម្រិតណា?

□ ក្រោមមធ្យម □ មធ្យម □ ល្អបង្គួរ □ ល្អ □ ល្អណាស់

១២.តើអ្នកយល់ដឹងពីការសរសេរសូចនាករនៃចំណុចដៅមានលក្ខណៈស្មាត(SMART)នៅក្នុងផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនបានកម្រិតណា?

□ ក្រោមមធ្យម □ មធ្យម □ ល្អបង្គួរ □ ល្អ □ ល្អណាស់

១៣.តើអ្នកយល់ដឹងពីការសរសេរយុទ្ធសាស្រ្តនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនបានកម្រិតណា?

□ ក្រោមមធ្យម □ មធ្យម □ ល្អបង្គួរ □ ល្អ □ ល្អណាស់

១៤.តើអ្នកអាចវិភាគតម្រូវការហិរញ្ញប្បទាននៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនបានកម្រិតណា?

□ ក្រោមមធ្យម □ មធ្យម □ ល្អបង្គួរ □ ល្អ □ ល្អណាស់

១៥.តើអ្នកយល់ដឹងពីការសរសេរយន្តការពិនិត្យតាមដាន និងវាយតម្លៃ នៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនបានកម្រិតណា?

□ ក្រោមមធ្យម □ មធ្យម □ ល្អបង្គួរ □ ល្អ □ ល្អណាស់

១៦.តើអ្នកយល់ដឹងពីការដាក់ទិន្នន័យបញ្ចូលក្នុងតារាងឧបសម្ព័ន្ធនៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនបានកម្រិតណា?

□ ក្រោមមធ្យម □ មធ្យម □ ល្អបង្គួរ □ ល្អ □ ល្អណាស់

**ផ្នែកទី៣៖ ដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀន**

១៧.តើអ្នកបានចូលរួមក្នុងការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនដែរឬទេ?

□ បានចូលរួម □ មិនបានចូលរួម

១៨.តើដំណើរការរៀបចំផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍សាលារៀនមានលក្ខណៈដូចម្ដេចខ្លះ? (អាចជ្រើសរើសចម្លើយលើសពីមួយ)

□ លទ្ធិប្រជាធិបតេយ្យ(មានការចូលរួម) □ មានលក្ខណៈវិទ្យាសាស្រ្ត □ មានលក្ខណៈច្បាប់

១៩.តើមានអ្នកណាខ្លះបានចូលរួមពិគ្រោះយោបល់ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន? (អាចជ្រើសរើសចម្លើយលើសពីមួយ)

☐ នាយក/នាយិកា ☐ នាយករង/នាយិការង

☐ លេខាធិការ ☐ គណនេយ្យ

☐ ប្រធានក្រុមបច្ចេកទេស ☐ អនុប្រធានក្រុមបច្ចេកទេស

☐ គ្រូបង្រៀន ☐ សិស្ស

☐ សហគមន៍ ☐ ក្រុមប្រឹក្សាឬគណៈគ្រប់គ្រងសាលារៀន

☐ អាជ្ញាធរមូលដ្ឋាន ☐ មាតាបិតាឬអាណាព្យាបាលសិស្ស

☐ ផ្សេងៗ............................

២០.តើដំណើរការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរបស់អ្នកអនុវត្តយ៉ាងដូចម្តេច? (អាចជ្រើសរើសចម្លើយលើសពីមួយ)

☐ រៀបចំដោយនាយក/នាយិកាជាអ្នករៀបចំទាំងស្រុង

☐ រៀបចំដោយនាយករង/នាយិការងជាអ្នករៀបចំទាំងស្រុង

☐ រៀបចំដោយលេខាធិការជាអ្នករៀបចំទាំងស្រុង

☐ រៀបចំដោយគណនេយ្យជាអ្នករៀបចំទាំងស្រុង

☐ រៀបចំដោយគណៈគ្រប់គ្រងសាលា(នាយក/នាយករង)ជាអ្នករៀបចំរួចប្រជុំផ្សព្វផ្សាយដល់គ្រូបង្រៀន

☐ រៀបចំដោយគណៈគ្រប់គ្រងសាលា (នាយក/នាយិកា) និងរដ្ឋបាលឃុំ/សង្កាត់

☐ រៀបចំដោយមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់ (នាយក/នាយិកា នាយករង/នាយិការង លេខាធិការ គណនេយ្យ គ្រូបង្រៀន មាតាបិតាសិស្ស អាណាព្យាបាលសិស្ស សហគមន៍ អាជ្ញាធរមូលដ្ឋាន សិស្សានុសិស្ស ...)

☐ រៀបចំដោយថ្នាក់មន្ទីរ អប់រំ យុវជន និងកីឡាខេត្ត

☐ រៀបចំដោយថ្នាក់ការិយាល័យអប់រំ យុវជន និងកីឡាក្រុង/ស្រុក

☐ រៀបចំដោយយកតាមគំរូវិទ្យាល័យផ្សេង

☐ រៀបចំដោយយកលំនាំតាមផែនការចាស់ដដែល

☐ ចម្លើយផ្សេងទៀត(បើមាន)...........................................................................

២១.ក្នុងពេលរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀន តើអ្នកជួបបញ្ហាប្រឈមអ្វីខ្លះ? (អាចជ្រើសរើសចម្លើយលើសពីមួយ)

☐ មិនយល់ពីគោលនយោបាយអប់រំនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ

☐ មិនសូវយល់ពីគោលនយោបាយអប់រំនៃផែនការយុទ្ធសាស្ត្រវិស័យអប់រំ

☐ មិនទាន់យល់ច្បាស់ពីខ្លឹមសារពាក្យគន្លឹះនៃទម្រង់របស់ផែនការ

☐ មិនអាចគណនាសូចនាករអប់រំសំខាន់ៗ

□ មិនសូវយល់ច្បាស់ក្នុងគណនាសូចនាករអប់រំសំខាន់ៗ

□ មិនអាចធ្វើចំណោលសិស្ស តម្រូវការហិរញ្ញប្បទាន និងចំណុចដៅនៃសូចនាករបាន

□ មិនសូវយល់ច្បាស់ការធ្វើចំណោលសិស្ស ចំណោលតម្រូវការហិរញ្ញប្បទាន និងចំណោលចំណុចដៅនៃសូចនាករបាន

□ មិនមានប្រភពថវិកាដៃគូអភិវឌ្ឍចូលរួមក្នុងការអភិវឌ្ឍសាលារៀន

□ មិនមានប្រភពថវិកាសប្បុរសជនចូលរួមក្នុងការអភិវឌ្ឍសាលារៀន

□ មិនមានប្រភពថវិកាអជ្ញាធរដែនដីនិងសហគមន៍ចូលរួមក្នុងការអភិវឌ្ឍសាលារៀន

□ មិនចុះសម្រុងគ្នាក្នុងពេលរៀបចំ

□ អ្នកចូលរួមមានសមត្ថភាពមិនទាន់គ្រប់គ្រាន់ក្នុងការរៀបចំ

□ សកម្មភាពដែលបានរៀបចំក្នុងផែនការការិយាល័យក្រុង/ស្រុក/មន្ទីរ មិនគាំទ្រ

□ មូលនិធិដំណើរការគ្រឹះស្ថានសាធារណៈទម្លាក់មិនទាន់

□ មូលនិធិដំណើរការគ្រឹះស្ថានសាធារណៈមានកម្រិតតិចតួចនៅឡើយ

□ គ្រោងសកម្មភាពក្នុងផែនការចាស់មិនបានដាក់បញ្ចូលក្នុងផែនការថ្មី

□ គ្រោងសកម្មភាពថ្មីមិនទាន់ឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់សាលា

□ កង្វះធនធានមនុស្សដែលមានសមត្ថភាពដើម្បីរៀបចំផែនការប្រកបដោយប្រសិទ្ធភាព

□ ការចូលរួម និងបញ្ចេញមតិយោបល់ពីអ្នកពាក់ព័ន្ធពុំទាន់បានពេញលេញ

□ បញ្ហាផ្សេងៗទៀតបើមាន..............................................................................

២២.តើក្រោយពីរៀបចំផែនការកន្លងមកសាលារៀនផ្សព្វផ្សាយបានកម្រិតណា?

□ មិនបានសោះ □ បានតិចតួច □ មធ្យម □ ច្រើន □ ច្រើនណាស់

២៣.តើលោក លោកស្រីមានការលើទឹកចិត្តក្នុងការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនដែរឬទេ?

□ បាទឬចាស □ ទេ

២៤.តើលោក លោកស្រីធ្លាប់ត្រូវបានលើកទឹកចិត្តក្នុងការរៀបចំផែនការពីអង្គភាពណាខ្លះ?

□ សាលារៀន □ ការិ.អយក ស្រុក/ក្រុង □ មន្ទីរអេយក.ខេត្ត □ ក្រសួងអយក

២៥.តើលោក លោកស្រី គិតថាការលើកទឹកចិត្តក្នុងការរៀបចំផែនការជារឿងសំខាន់ដែរឬទេ?

□ បាទឬចាស □ ទេ

២៦.តើលោក លោកស្រី ចង់ទទួលបានការលើកទឹកចិត្តក្នុងការរៀបចំផែនការជាអ្វី?

□ ប័ណ្ណសរសើរ □ ថវិកា □ សម្ភារៈ □ ការតម្លើងឋានៈ

២៧. តើការការវាយតម្លៃក្នុងការលើកទឹកចិត្តបុគ្គលិកដែលចូលរួមរៀបចំផែនការបានល្អផ្អែកលើអ្វីខ្លះ?

□ បក្សពួក □ កិច្ចព្រមព្រៀងការងារ □ លទ្ធផលការងារ □ របាយការណ៍សមិទ្ធកម្ម

២៨.តើលោក លោកស្រី ទទួលបានការអភិវឌ្ឍសមត្ថភាពលើការរៀបចំផែនការអភិវឌ្ឍន៍សាលារៀនដែរឬទេ?

□ បាទឬចាស □ ទេ

២៩.តើលោក លោកស្រី ទទួលបានការអភិវឌ្ឍសមត្ថភាពក្នុងការរៀបចំផែនការលើផ្នែកអ្វីខ្លះ ?

□ ពាក្យគន្លឹះផែនការ □ ការវិភាគបញ្ហា

□ ការគណនាសូចនាករ □ ការធ្វើចំណោល

□ ការគ្រោងចំណាយ □ ការវិភាគហិរញ្ញប្បទាន

□ ការជ្រើសរើសយុទ្ធសាស្ត្រ □ ការពិនិត្យតាមដាននិងវាយតម្លៃ

□ ការរៀបចំផែនការទាំងស្រុង □ ផ្សេងៗ........................................................................

**សំណូមពរ៖**

១. តើលោក លោកស្រីមានសំណូមពរអ្វីខ្លះ ដើម្បីឱ្យការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំមានដំណើរការល្អ ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

២. តើលោក លោកស្រីមានឧបសគ្គ ឬការលំបាកអ្វីខ្លះ ក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍សាលារៀនរយៈពេល៥ឆ្នាំ ?

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................